**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economic

# របាយការណ៍បញ្ចប់ការសិក្សា

## ការគ្រប់គ្រងសេវាដឹកជញ្ជូនសាធារណៈនៅរាជធានីភ្នំពេញ(រថយន្តក្រុងសាធារណៈ)

កម្មសិក្សា ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨

រៀបរៀងដោយ៖

និស្សិតឈ្មោះ៖ **កញ្ញា. ចាន់ បូរមី**

**កញ្ញា. ទី ចិន្តា**

សាស្ត្រាចារ្យណែនាំ

លោក **បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១១

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេររបាយការណ៍ ២០១៨

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំ ជានិស្សិតឈ្មោះ **ចាន់ មុំរមី** និង**ទី ចិន្តា** ផ្នែកបរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី១១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការអោនលំទង ក្រាបថ្វាយបង្គំទៅដល់៖

- លោកឪពុក និងអ្នកម្តាយ៖ លោក ចាន់ សារឿន និងលោកស្រី ហួយ ណាយ , និង លោក ទី ចន្ធី និង លោកស្រី មាស ភារម្យ ដែលបានផ្តល់កំណើតដល់រូបកូនទាំងពីរអ្នក ដោយលោកខិតខំចិញ្ចឹមបីបាច់ ថែរក្សា តាំងពីតូចរហូតដល់ធំដឹងក្តីដោយលោកបាននឿយ ហត់ទាំងរូបកាយ និងចិត្ត ហើយលោកបានជួយផ្គត់ផ្គង់ដល់រូបកូនទាំងចំណីអាហារ និង សម្ភារសិក្សាមិនអោយមានខ្វះចន្លោះឡើង។ កូនទាំងពីរមានតែប្រាមដៃដប់ សូមក្រាបថ្វាយ បង្គំដល់វត្ថុសក្តិសិទ្ធទាំងអស់ជួយតាមថែរក្សា អ្នកមានគុណទាំងបួន អោយជួបតែសំណាង ល្អ រកស៊ីមានបាន ជួបតែមនុស្សល្អដែលគេចូលចិត្ត និងស្រលាញ់រាប់អានជារៀងរហូត។
- ឯកឧត្តម **លុយ ចណ្ណា** ដែលជានាយកនៅសាកលវិទ្យាល័យ RULE លោកបាន ខិតខំប្រឹងប្រែង អស់ទាំងកំលាំងកាយ និងចិត្ត ព្រមទាំងថវិកាដើម្បីស្វែងរកនៅសាស្ត្រាចារ្យ ដែលមានបទពិសោធន៍ក្នុងការបង្រៀន ដើម្បីអោយនិស្សិត ពេលបញ្ចប់ការសិក្សាពួកគាត់ អាចក្លាយជាសសរទ្រូងដ៏រឹងមាំមួយសម្រាប់ប្រទេសជាតិ។
- លោកបណ្ឌិត **អ៊ុន សភក្តដា** ដែលលោកជាសាស្ត្រាចារ្យដឹកនាំផ្ទាល់របស់ក្រុម យើងខ្ញុំ សូមធ្វើការដឹងគុណដល់លោក ដែលលោកខិតខំតម្រង់ទិស ដែលធ្វើអោយសារ ណាថ្មីមួយនេះទទួលបានជោគជ័យ។
- សាស្ត្រាចារ្យគ្រប់លំដាប់ថ្នាក់ និងបុគ្គលិកទាំងអស់ ដែលបានយកចិត្តទុកដាក់ក្នុង ការខិតខំស្វែងរកឯកសារដើម្បីបង្រៀនដល់និស្សិតទាំងអស់នៅគ្រប់ជំនាន់។
- លោក **អ៊ាន សុឃីម** អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងដែល លោកបានអនុញ្ញាតអោយយើងខ្ញុំបានសម្ភាសជាមួយលោកប្រធានផ្នែករដ្ឋបាលហើយ លោកបានផ្តល់ពាក្យពេជ្រយ៉ាងក្បោះក្បាយនូវរាល់សំណួរទាំងអស់ ហើយថែមទាំងបាន ផ្តល់នូវឯកសារមួយចំនួនសម្រាប់ជំនួយដល់កិច្ចការរបស់យើងខ្ញុំ។

ជាចុងក្រោយក្រុមយើងខ្ញុំសូមបន្ទន់កាយក្រាបសំពះដោយក្តីគោរព សូមទេវតាដែលតាម រក្សាលោកយើងនេះ សូមមេត្តាជួយថែរក្សា លោកអ្នកមានគុណទាំងបួន ឯកឧត្តម លោកជំទាវ និង សាស្ត្រាចារ្យ ព្រមទាំងមិត្តអ្នកអានទាំងអស់អោយមានសុខភាពល្អប្រកបការងារអ្វីៗក៏បានសម្រេច ផងដែរ។

# អារម្ភកថា

ក្រុមយើងខ្ញុំ បានខិតខំធ្វើការសិក្សាស្រាវជ្រាវដើម្បីធ្វើជាសារណានេះឡើង ទុកសម្រាប់អ្នកជំនាន់ក្រោយឱ្យបានយល់កាន់តែច្បាស់អំពីសេវាដឹកជញ្ជូនសាធារណៈដែលរដ្ឋបានផ្តល់ជូនទៅដល់ប្រជាពលរដ្ឋឱ្យបានប្រើប្រាស់សេវាកម្មនេះ។

ដូចដែលបានឃើញទិដ្ឋភាពជាក់ស្តែង ក្រុមយើងខ្ញុំបានរើសយកប្រធានបទមួយស្តីអំពី "ការគ្រប់គ្រងសេវាដឹកជញ្ជូនសាធារណៈនៅរាជធានីភ្នំពេញ(រថយន្តក្រុងសាធារណៈ)" ដែលជាស្នាដៃមួយដោយយើងបានសិក្សាស្រាវជ្រាវ អំពីការវិវត្តរបស់អ្នកធ្វើដំណើរតាមឡានក្រុង។ ដោយយោងទៅតាមការសិក្សាស្រាវជ្រាវយើងបានសង្កេតឃើញថា ប្រទេសដទៃទៀតនៅលើពិភពលោកបានប្រើប្រាស់នូវសេវាកម្មនេះ អស់រយៈពេលជាច្រើនស.វមកហើយដែលបានធ្វើឱ្យប្រទេសរបស់គេកាត់បន្ថយគ្រោះថ្នាក់ និងការកកស្ទះចរាចរណ៍ ព្រមទាំងធ្វើឱ្យប្រទេសនោះមានការអភិវឌ្ឍបានប្រសើរឡើងជាងមុន ទៅលើវិស័យដឹកជញ្ជូននេះទៀតផង។ ដោយរដ្ឋាភិបាលរបស់យើងសម្លឹងឃើញ ការអភិវឌ្ឍយ៉ាងនេះហើយ ទើបធ្វើឱ្យគាត់មានគំនិតក្នុងការលើកកំពស់ទៅលើវិស័យដឹកជញ្ជូននេះឡើង ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់ស្រទាប់បានប្រើប្រាស់។

ក្នុងខ្លឹមសារនៃការសរសេរនេះដែរ ចង់បង្ហាញឱ្យអ្នកគ្រប់គ្នាបានយល់កាន់តែច្បាស់ទៅលើការប្រើប្រាស់សេវាសាធារណៈ កាន់តែមានភាពទូលំទូលាយជាងមុន ព្រមទាំងជួយជម្រុញឱ្យប្រជាពលរដ្ឋគ្រប់ប្រទាប់បានប្រើប្រាស់ដោយមានតម្លាភាព។

យើងខ្ញុំជឿជាក់ថា ស្នាដៃនេះប្រាកដជាមានកន្លែងណាមួយដែលខុសឆ្គងជាមិនខានពីព្រោះដោយសារតែនេះជាស្នាដៃដំបូងរបស់យើងខ្ញុំទាំងពីរ ដោយក្រោយពីបានបញ្ចប់ការសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ ជាថ្មីម្តងទៀត ក្នុងនាមយើងខ្ញុំជាអ្នករៀបរៀងផ្ទាល់នៅក្នុងសារណាមួយនេះ យើងខ្ញុំសូមទទួលយកនូវការរិះគន់ទាំងឡាយណាដែលមាននៅក្នុងអត្ថបទនេះ ពីប្រិយមិត្តអ្នកអានគ្រប់វិនាទី ដើម្បីជាការកែតំរូវស្នាដៃមួយនេះឱ្យកាន់តែល្អប្រសើរ និង ក្លាយជាចំណែកមួយសម្រាប់ជំនួយស្មារតីដល់និស្សិតជំនាន់ក្រោយៗទៀត ព្រមទាំងជួយបំពេញនូវសេចក្តីត្រូវការដល់អ្នកសិក្សាស្រាវជ្រាវ ដែលចង់ស្វែងយល់អំពីការវិវត្តនៃសេវាដឹកជញ្ជូនសាធារណៈមួយនេះឱ្យកាន់តែច្បាស់លាស់ជាងមុន។

សូមមិត្តអ្នកអានទាំងអស់មេត្តាអធ្យាស្រ័យ ទៅលើការសរសេរដែលមានកំហុសឆ្គងទៅលើអក្ខរាវិរុទ្ធ ឬពាក្យពេជ្រនៅក្នុងឃ្លាណាមួយដែលមិនសមគួរ ដែលបានកើតឡើងដោយអចេតនា និងសូមមេត្តាជួយ បំពេញកង្វះខាតទាំងអស់នោះដោយក្តីអនុគ្រោះ។

## បញ្ជីអក្សរកាត់

- រ.ដ.ស: រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)
- JICA: ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (Japan International Cooperation Agency)
- ADB : ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank)
- USAID: ទីភ្នាក់ងារសហរដ្ឋអាមេរិចដើម្បីអភិវឌ្ឍន៍អន្តរជាតិ (United States Agency for International Development)
- JR : Japan Railway
- JNR : Japanese National Railway
- TIBS: Trans Island Bus Services

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................ ០១

ជំពូកទី១.ទិដ្ឋភាពទូទៅ ........................................................ ០៥

១.១.ប្រវត្តិនៃការកកើតសេវាដឹកជញ្ជូនសាធារណៈ ........................................................ ០៦

១.១.១.និយមន័យ ........................................................ ០៩

១.១.២.ការហូរចូលសេវាដឹកជញ្ជូនសាធារណៈមកទ្វីបអាស៊ី ........................................................ ១១

១.២.ការហូរចូលសេវាដឹកជញ្ជូនសាធារណៈមកកម្ពុជា ........................................................ ១៥

១.២.១.ការចូលរួមសេវាដឹកជញ្ជូនរបស់ឯកជន ........................................................ ១៥

១.២.២.ការចូលរួមសេវាដឹកជញ្ជូនរបស់សាធារណៈ ........................................................ ១៧

១.៣.ការណែនាំស្តីពីការអនុវត្តសេវាដឹកជញ្ជូនសាធារណៈក្នុងរាជធានីភ្នំពេញ.. ១៩

១.៣.១.ការកែប្រែ និងការដាក់បញ្ចូលលើខ្សែរថយន្ត ........................................................ ២០

១.៣.២.ការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ ........................................................ ២២

ជំពូកទី២.ដំណើរការនៃសេវាដឹកជញ្ជូនសាធារណៈក្នុងរាជធានីភ្នំពេញ ........ ២៨

២.១.តួនាទី និងភារកិច្ចរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ...... ២៩

២.១.១.ភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងការិយាល័យ ............... ៣០

២.១.២.ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកបម្រើសេវា ........................ ៣៣

២.២.ប្រសិទ្ធភាពនៃការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ ........................ ៤១

២.២.១.ប្រៀបធៀបខ្សែរថយន្ត (២០១៤-២០១៧) ........................................................ ៤២

២.២.២.គុណសម្បត្តិ និងគុណវិបត្តិ ........................................................ ៥៣

២.៣.បញ្ហាប្រឈម និងដំណោះស្រាយ ........................................................ ៥៥

២.៣.១.បញ្ហាប្រឈម ........................................................ ៥៥

២.៣.២.ដំណោះស្រាយ ........................................................ ៥៦

សេចក្តីសន្និដ្ឋាន ........................................................ ៥៨

អនុសាសន៍ ........................................................ ៦០

ឯកសារយោង

តារាងឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅយើងដឹងហើយថា គ្រប់បណ្តាប្រទេសនៅលើពិភពលោកតែងតែមានការអភិវឌ្ឍន៍លើគ្រប់វិស័យទាំងអស់មិនថា វិស័យអប់រំ បច្ចេកវិទ្យា និង ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតដូចជា ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ។ល។ ជាពិសេសការសហការជាមួយប្រទេសជិតខាង ហើយរាល់ការទំនាក់ទំនងទាំងអស់នោះ ត្រូវការចាំបាច់ណាស់នូវមធ្យោបាយធ្វើដំណើរ។ គេច្រើនតែធ្វើដំណើរតាមមធ្យោបាយផ្សេងៗដូចជា ការប្រើប្រាស់យានជំនិះទៅតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ឬក៏ការធ្វើដំណើរដោយថ្មើរជើងជាដើម ដើម្បីទៅដល់ទីកន្លែងដែលពួកគេចង់ទៅ។ ទន្ទឹមនឹងនេះ កម្ពុជាជាប្រទេសមួយដែលបានឆ្លងកាត់សង្គ្រាមជាច្រើនលើកច្រើនសារ ហេតុដូច្នេះហើយ ទើបបណ្តាលឱ្យមានការបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធអស់ជាច្រើនលើកដែរ ជាក់ស្តែងនៅក្នុងសម័យ ប៉ុល ពត ហេ-ដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងអស់ត្រូវបានបំផ្លាញ។ ក្រោយពីបានជួបវិបត្តិនេះ រដ្ឋាភិបាលបានខិតខំសហការជាមួយដៃគូរអភិវឌ្ឍន៍ ពីប្រទេសជិតខាងដូចជា បារាំង ជប៉ុន (JICA) សហរដ្ឋអាមេរិច (USAID) ធានាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតនោះឡើងវិញជាបន្តបន្ទាប់។ រហូតមកដល់បច្ចុប្បន្នរដ្ឋាភិបាលកម្ពុជា បានបង្កើតគោលនយោបាយមួយសម្រាប់អភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធទាំងនោះ « ទី ៦ ការរៀបចំផែនការមេនៃការអភិវឌ្ឍន៍ហេដ្ឋារចនាស-ម្ព័ន្ធទីក្រុង ពិសេសប្រព័ន្ធគមនាគម៍នដឹកជញ្ជូនអ្នកដំណើរក្នុងទីក្រុង ព្រមទាំងការតភ្ជាប់រវាងតំបន់មូលដ្ឋានផលិតកម្មជុំវិញក្រុង, ប៉ូលសេដ្ឋកិច្ចសំខាន់ៗ, តំបន់ឧស្សាហកម្ម និង តំបន់សេដ្ឋកិច្ចពិសេសជាដើម ដែលនិងជួយកាត់បន្ថយការកកស្ទះចរាចរណ៍, លើកកម្ពស់ប្រសិទ្ធភាព និង ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងជួយលើកស្ទួយសុខុមាភាពប្រជាជន និង ធានាចីរភាពបរិស្ថាន ដោយធានាសង្គតិភាព[1]ជាមួយនិងក្របខ័ណ្ឌនៃការរៀបចំដែនដី និង នគរូបនីយកម្ម និងសំណង់, យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍន៍តំបន់ទីក្រុង និង ប្រជុំជន, ការរៀនចំប្រព័ន្ធគ្រប់គ្រងសំណល់រាវ និង សំណល់រឹង ព្រមទាំងប្រព័ន្ធការពារ និង ពន្លត់អគ្គីភ័យ[2] » ដោយអនុវត្តទៅតាមយុទ្ធសាស្ត្រដែលមានស្រាប់ រដ្ឋាភិបាលបានបង្កើតឱ្យមានសេវាដឹកជញ្ជូនតាមរថយន្តក្រុងជាសាធារណៈដើម្បីបម្រើជាប្រយោជន៍ទូទៅសម្រាប់សង្គម។

---

[1] សង្គតិភាព គឺជាភាពនៃការរាប់អានគ្នា,ភាពនៃការរាប់រកគ្នា,ភាពនៃការរួបរួមគំនិតគ្នា, ភាពនៃការរួមប្រសព្វគ្នា (តាមវចនានុក្រមខ្មែរ)។

[2] សៀវភៅ « យុទ្ធសាស្ត្រចតុកោណ » ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា នៅខែ កញ្ញា ឆ្នាំ ២០១៣ ត្រង់ចតុកោណទី ២ មុំទី ១ ទំព័រទី ៦២។

ដូចគ្នានេះដែរ ការបង្កើតឱ្យមានសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈមួយនេះ បានជួយកាត់បន្ថយការកកស្ទះចរាចរណ៍ និង គ្រោះថ្នាក់ចរាចរណ៍នៅក្នុងរាជធានីភ្នំពេញផងដែរ មិនត្រឹមតែប៉ុណ្ណោះសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈនេះក៏បានជួយសម្រួលដល់ជីវភាពប្រជាពលរដ្ឋក្នុងការចំណាយថវិកាច្រើនសម្រាប់មធ្យោបាយធ្វើដំណើររបស់ពួកគេមុនមុន។ ក្រោយពេលសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈបានកើតឡើងនោះ មនុស្សភាគច្រើនចូលចិត្តនិងប្រើប្រាស់សេវានេះខ្លាំងណាស់ ព្រោះវាធ្វើឱ្យមានភាពកក់ក្តៅជាជាងការប្រើប្រាស់យានយន្តខ្លួនឯងក្នុងការធ្វើដំណើរ ហើយជាពិសេសនោះគឺវាមានសុវត្ថិភាពខ្ពស់ និង មានផាសុខភាពទៀតផង។

ដោយផ្អែកទៅលើចំណុចខាងលើនេះ ឃើញថាសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈមួយនេះត្រូវបានគេទទួលស្គាល់ និង ប្រើប្រាស់ជាច្រើនហើយ ប៉ុន្តែវាមិនសូវជាមានភាពទូលំទូលាយប៉ុន្មាននោះទេ ដោយសារតែប្រព័ន្ធនៃការផ្សព្វផ្សាយនេះនៅមានកម្រិតនៅឡើយ។ តែទោះជាយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលនៅតែខិតខំធ្វើការផ្សព្វផ្សាយជាបន្តបន្ទាប់ដើម្បីឱ្យប្រជាពលរដ្ឋបានដឹង និង ប្រើប្រាស់សេវាដឹកជញ្ជូននេះកាន់តែច្រើនឡើងៗ ជាងនេះទៅទៀត រដ្ឋាភិបាលក៏បានផ្តល់នូវការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋងាកមកប្រើប្រាស់សេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈនេះថែមទៀត ដោយតម្រូវឱ្យមានការចំណាយថវិកាតិចតួចរាល់ការធ្វើដំណើរម្តងៗ របស់ប្រជាពលរដ្ឋទាំងអស់ដែលបានប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈមួយនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រធានបទដែលយើងខ្ញុំបានយកមកធ្វើការស្រាវជ្រាវនេះវាពិតជាមានសារៈសម្ខាន់ជាច្រើនដល់សាធារណៈជន ឱ្យពួកគាត់បានដឹងកាន់តែច្បាស់ពីសេវាដឹកជញ្ជូនដែលមានលក្ខណជាសាធារណៈមួយ ហើយជាពិសេសនោះគឺវាមានសារៈប្រយោជន៍ដល់ សិស្ស និស្សិត ក្នុងការស្វែងយល់អំពីសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈមួយនេះ ថាតើការបង្កើតឡើងមកក្នុងគោលបំណងអ្វី ដើម្បីអ្វី? ហេតុអ្វីបានជារដ្ឋាភិបាលសម្រាច់ចិត្តបង្កើតនូវសេវាមួយនេះ ហើយវាបានជួយអ្វីខ្លះដល់សង្គម? បានអនុវត្តបានដល់កម្រិតណា? និង មាននីតិវិធីអ្វីខ្លះក្នុងការប្រើប្រាស់សម្រាប់សាធារណៈជន? នៅពេលដែលចូលរួមប្រើប្រាស់សេវាកម្មនេះ តើពួកគាត់ទទួលបានផលប្រយោជន៍អ្វីខ្លះពីសេវាកម្មមួយនេះ? ហើយបញ្ហាទាំងអស់នេះក៏សុទ្ធតែជាកត្តាចំបាច់មួយដែលយើងគ្រប់គ្នា គួរតែធ្វើការសិក្សាស្វែងយល់ឱ្យបានលម្អិតនឹងច្បាស់លាស់ ដើម្បីឱ្យការសិក្សាក្នុងផ្នែកមួយនេះទទួលបាននូវចំណេះដឹងបន្ថែមទៀតទៅលើសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈ ដែលមាននៅក្នុងប្រទេសកម្ពុជាយើង។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវដ៏សំខាន់នៃប្រធានបទនេះ ដោយយើងសង្កេតឃើញថាមានប្រជាជនភាគច្រើន ពួកគាត់មិនទាន់បានយល់ច្បាស់នូវសេវាកម្មនេះនៅឡើយទេ ហេតុដូចនេះហើយទើបយើងត្រូវធ្វើយ៉ាងណាដើម្បីឱ្យពួកគាត់ទាំងអស់គ្នាបានដឹង ពីសេវាកម្មមួយនេះ ឱ្យកាន់តែច្បាស់លាស់ទៀតមិនថាអ្នករស់នៅទីប្រជុំជន ឬអ្នករស់នៅជនបទនោះទេ ពួកគេនឹងបានដឹងពីសេវាកម្មនេះព្រមទាំងទាញយកអត្ថប្រយោជន៍ផ្សេងៗពីសេវាដឹកជញ្ជូនសាធារណៈនេះដែរ ហើយវាក៏ជាការចូលរួមមួយ ក្នុងការជួយនូវការកាត់បន្ថយពីការកកស្ទះចរាចរណ៍នៅតាមដងផ្លូវផងដែរ។ ទោះជាយ៉ាងនេះក្តីយើងក៏ចង់ដឹងដែរថា តើការផ្សព្វផ្សាយរបស់សេវាកម្មនេះគេធ្វើតាមរបៀបណាខ្លះ? ហើយវាមានលក្ខណដល់កម្រិតណា? និងមានប្រសិទ្ធភាពដល់កម្រិតណា? ម្យ៉ាងវិញទៀតគោលបំណងនៃការសិក្សាស្រាវជ្រាវរបស់យើង គឺចង់ចងក្រងឯកសារដែលពាក់ព័ន្ធ និងសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងមួយនេះឡើង ដើម្បីទុកជាស្នាដៃមួយដែលមានអត្ថប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយឱ្យបានដឹងពីការវិវត្តនៃសេវាដឹកជញ្ជូនសាធារណៈដែលមាននៅក្នុងរាជធានីភ្នំពេញយើងនេះពីមួយដំណាក់កាលទៅមួយដំណាក់កាល តាំងពីចាប់ផ្តើមដំបូងរហូតទទួលបានជោគជ័យមួយកម្រិត ដែលត្រូវបានប្រជាពលរដ្ឋទទួលស្គាល់ និងបន្តប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈនេះកាន់តែច្រើនឡើងៗទៅទៀត។

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ដោយសារតែកំណើនប្រជាជន និងការកើនឡើងនៃយានយន្តចេះតែច្រើនឡើងៗក្នុងរាជធានីភ្នំពេញ ដែលជាហេតុមួយបង្កឱ្យមានការកកស្ទះចរាចរណ៍ក្នុងពេលកំពុងធ្វើដំណើរនៅតាមដងផ្លូវ និងមានការចំណាយថវិកាច្រើនក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋម្តងៗនោះ ទើបរដ្ឋាភិបាលសម្រេចចិត្តថានឹងបង្កើតឱ្យមានសេវាដឹកជញ្ជូនមួយដែលមានលក្ខណដឹកជញ្ជូនជាសាធារណៈឡើង សម្រាប់ឱ្យប្រជាជនធ្វើដំណើរ ហើយសេវាដឹកជញ្ជូននេះមានលក្ខណងាយស្រួល និងចំណាយថវិកាតិចផងដែលរាល់ការធ្វើដំណើរម្តងៗ។ ដោយឃើញថាសេវាកម្មដឹកជញ្ជូនរថយន្តក្រុងសាធារណៈមួយនេះទើបនឹងកើតឡើង យើងបានកំណត់យកពីឆ្នាំដែលបានកកើតឡើងបន្ទាប់ពីសេវាដឹកជញ្ជូននេះបានបរាជ័យម្តងរួចមកហើយ ដូចនេះទើបយើងកំណត់យកត្រឹមថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ រហូតមកដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ មកធ្វើការសិក្សាឱ្យមានភាពស៊ីជម្រៅ និងលម្អិត ដើម្បីមានភាពងាយស្រួលដល់អ្នកអានគ្រប់គ្នា ក្នុងការស្វែងយល់អំពីសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈដែលកំពុងតែមាន និងធ្វើចរាចរណ៍ក្នុងរាជធានីភ្នំពេញសព្វថ្ងៃនេះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ស្នាដៃនៃការសិក្សាស្រាវជ្រាវមួយនេះដែរគឺបានជួយដល់អ្នកសិក្សាទាំងអស់ឱ្យយល់កាន់តែច្បាស់ពីសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈព្រមទាំងនីតិវិធី និងសេចក្តីណែនាំនៃការប្រើប្រាស់នូវសេវាដឹកជញ្ជូនសាធារណៈមួយនេះឱ្យកាន់តែច្បាស់ទៅលើគោលបំណង និងការបង្កើតឡើងនៃសេវាដឹកជញ្ជូនសាធារណៈ។ បន្ទាប់ពីបានយល់ច្បាស់ទៅលើបញ្ហាដែលមាននៅខាងលើនេះហើយនោះ យើងខ្ញុំជឿជាក់ថាពួកគេ នឹងអាចទទួលបាននូវចំណេះដឹងមួយយ៉ាងជាក់ស្តែងស្តីពីសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈនេះ ហើយក៏បានយល់ពីអត្ថប្រយោជន៍ទាំងអស់ដែលមាននៅក្នុងសេវាដឹងជញ្ជូនរថយន្តក្រុងសាធារណៈមួយនេះដែរ។ មិនត្រឹមតែប៉ុណ្ណោះវាក៏ជាចំណែកមួយក្នុងការផ្សព្វផ្សាយដល់អ្នកទាំងអស់គ្នាបានយល់ដឹងពីអត្ថប្រយោជន៍ និងជួយគាំទ្រឱ្យសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈមួយនេះកាន់តែកើនឡើងៗ និង មានភាពរីកដុះដាលឱ្យកាន់តែច្រើនថែមទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវការស្រាវជ្រាវមួយនេះ យើងបានធ្វើការពិគ្រោះ និងពិភាក្សាគ្នា ក្នុងការស្វែករកឯកសារនានា និងសាស្ត្រាចារ្យ ដែលនៅក្នុងរួមមានឯកសារដូចជា៖ សៀវភៅ លិខិតបទដ្ឋាននានាដែលមាន ការសិក្សាតាមការចុះទៅប្រមូលរាល់ឯកសារដែលមាននៅតាមស្ថាប័នដែលមានសមត្ថកិច្ច ប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់សេវារថយន្តក្រុងសាធារណៈ បុគ្គលិកដែលបម្រើការនៅលើរថយន្តក្រុង (តាមការសម្ភាសផ្ទាល់) ព្រមទាំងការស្រាវជ្រាវពីប្រភពផ្សេងៗទៀតដូចជាតាមប្រព័ន្ធអ៊ីធឺណែក (Internet) ជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សម្រាប់ការសិក្សាស្រាវជ្រាវខាងក្រោមនេះ យើងបានធ្វើការស្វែងរក និងវែកញែកបានជា ២ជំពូកសំខាន់ៗ ដែលក្នុងនោះរួមមានជំពូកទី១ បានចាប់រៀបរាប់អំពីទិដ្ឋភាពទូទៅដែល រដ្ឋាភិ-បាលបានផ្តល់សេវាដឹកជញ្ជូនសាធារណៈដល់ប្រជាពលរដ្ឋសំរាប់ធ្វើដំណើរ និងដឹងពីប្រវត្តិតាំងពីដំបូងរហូតមកដល់សព្វថ្ងៃ ព្រមទាំងសរសេររៀបរាប់អំពីរបៀបនៃការប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិចផ្សេងៗដែលបំពាក់នៅលើរថយន្តក្រុង និងចំនួនខ្សែរត់របស់រថយន្តក្រុងដែលកំពុងចរាចរណ៍ក្នុងរាជធានីភ្នំពេញសព្វថ្ងៃនេះ។ ជំពូកទី២ និយាយអំពីដំណើរការ និងការគ្រប់គ្រងនៃសេវាដឹកជញ្ជូនសាធារណៈនេះ ថាតើទទួលបានលិទ្ធផលបែបណា? មិនតែប៉ុណ្ណោះយើងក៏បានធ្វើការប្រៀបធៀបគុណសម្បត្តិ និងគុណវិបត្តិព្រមទាំងសិក្សាអំពីបញ្ហា និងដំណោះស្រាយផងដែរ។

# ជំពូកទី ១

# ទិដ្ឋភាពទូទៅ

# ជំពូកទី១ ទិដ្ឋភាពទូទៅ

មនុស្សនៅក្នុងសាកលលោកយើងនេះតែងតែត្រូវការ ការដឹកជញ្ជូនជាចាំបាច់សម្រាប់ផ្គត់ផ្គង់ក្នុងជីវភាពគ្រួសាររបស់ពួកគេជាដើម មិនថារដ្ឋឬក៏ឯកជននោះទេ ប៉ុន្តែគ្រាន់តែពួកគេបានប្រើប្រាស់សេវាដឹកជញ្ជូនមានលក្ខណខុសៗពីគ្នា និងដំណើរការនៃសេវាដឹកជញ្ជូនមានភាពផ្សេងពីគ្នាតែប៉ុណ្ណោះ។ ទោះជាការដឹកជញ្ជូនមានច្រើនបែប និង ច្រើនទម្រង់ក៏ពិតមែន តែសេវាដឹកជញ្ជូននេះគឺសុទ្ធតែផ្តល់នៅផលប្រយោជន៍សម្រាប់រដ្ឋាភិបាល និងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់របស់ខ្លួន។

យោងទៅតាមការសង្កេតឃើញថាការជឿនលឿននៅក្នុងតំបន់មួយ ឬនៅក្នុងប្រទេសមួយដែលទទួលបានការរីកចម្រើនយឺតឬឆាប់ អ្វីដែលគេអាចសម្លឹងឬកត់សម្គាល់ឃើញនោះ គឺការដឹកជញ្ជូន ពីព្រោះការដឹកជញ្ជូនក៏ជារឿងមួយផ្នែកសម្រាប់អភិវឌ្ឍន៍នៅក្នុងប្រទេសនីមួយៗផងដែរ។ នៅក្នុងប្រទេសមួយដែលសេវាដឹកជញ្ជូនរបស់ពួកគេមានភាពល្អប្រសើរ មានភាពរហ័សរហួន មិនមានការយឺតយ៉ាវនោះ នោះមានន័យថាប្រទេសមួយនោះមានការអភិវឌ្ឍកាន់តែដើរទៅមុខនឹងជឿនលឿនរហូត។ ចំណែកឯប្រជាពលរដ្ឋរបស់ពួកគេ ក៏កាន់តែមានភាពងាយស្រួល និងមានភាពរីកចម្រើនទៅមុខរហូតផងដែរ។

ការដឹកជញ្ជូននៅក្នុងតំបន់របស់ពួកគេត្រូវបានផ្តល់ដោយរដ្ឋាភិបាលនៅក្នុងតំបន់ផ្ទាល់របស់ពួកគេជាអ្នកបង្កើតវាឡើងតែម្តង។ ដោយគ្រាន់តែមានសេវាដឹកជញ្ជូនសាធារណៈខ្លះគឺរដ្ឋបានផ្តល់សិទ្ធិទៅឱ្យក្រុមហ៊ុនឯកជនជាអ្នកកាន់កាប់ ឬក្រុមហ៊ុនឯកជនជាអ្នកជ្រើសរើសប្រភេទណាមួយនៃការដឹកជញ្ជូនដែលរដ្ឋាភិបាលបានបង្កើតឱ្យពួកគេរួចជាស្រេចតែប៉ុណ្ណោះ ដោយក្រុមហ៊ុនឯកជនណាដែលចង់បើកអាជីវកម្មសេវាដឹកជញ្ជូនសាធារណៈ តែទោះយ៉ាងណាក៏ដោយក៏រដ្ឋាភិបាលនៅតែជាអាណាព្យាបាលរបស់ក្រុមហ៊ុនឯកជននោះដ៏ដែរ។

ការដឹកជញ្ជូនមានលក្ខណខុសគ្នា និង ដំណើរការខុសគ្នា ប៉ុន្តែការចាប់ផ្តើមឱ្យប្រព័ន្ធសេវាដឹកជញ្ជូនដំណើរការទៅបាន តែងតែមានមូលហេតុ និងដើមហេតុអ្វីមួយទើបបានជាគេបង្កើតឱ្យមានសេវាកម្មដឹកជញ្ជូនដោយរបៀបនេះឡើង? និងកាបង្កើតឱ្យមានសេវាបែបនេះតើអ្នកណាជាអ្នកទទួលបានផលប្រយោជន៍? ហើយពួកគេទទួលបានផលប្រយោជន៍អ្វីខ្លះពីសេវាដឹកជញ្ជូនដែលពួកគេកំពុងតែប្រើប្រាស់នេះ? ហេតុដូច្នេះហើយទើបរដ្ឋាភិបាលតែងតែធ្វើការណែនាំឱ្យប្រជាជនប្រើប្រាស់នូវសេវាកម្មនេះឱ្យបានដឹងពីផលប្រយោជន៍ដែលពួកគាត់អាចនឹងទទួលបានបន្ទាប់ពីបានប្រើប្រាស់សេវាមួយនេះរួចហើយ។

## ១.១. ប្រវត្តិនៃការកកើតសេវាដឹកជញ្ជូនសាធារណៈ

មុនដំបូងការដឹកជញ្ជូនត្រូវបានគេចាប់ផ្តើមមុនគេបង្អស់ដោយមនុស្សបុរាណដោយពួកគាត់បានប្រើប្រាស់កប៉ាល់[3] សំរាប់ធ្វើពាណិជ្ជកម្មដឹកជញ្ជូនឬធ្វើសង្គ្រាម និងនេសាទ ដែលកប៉ាល់នីមួយៗមានប្រវែងសរុប២៤ ម៉ែត្រ និងកម្ពស់រហូតដល់១៨ ហ្វីត។ ការដឹកជញ្ជូនតាមកប៉ាល់នេះត្រូវបានកកើតឡើងតាំងពីសវត្សទី៥ មុនគ.ស ដោយប្រជាជនរស់នៅតាមតំបន់ឆ្នេរជាអ្នកប្រើប្រាស់ក្នុងការធ្វើដំណើរដើម្បីនេសាទនៅលើសមុទ្រ ពួកគេគឺជាជនជាតិដើមភាគតិច នៅតំបន់ប៉ាស៊ីហ្វិចភាគពាយ័ព្យ។

បន្ទាប់មកការដឹកជញ្ជូនក៏បានបង្កើតឡើងជាការដឹកជញ្ជូនតាមផ្លូវដែក ដែលមានឈ្មោះថា Diolkos ការដឹកជញ្ជូននេះត្រូវបានចាប់ផ្តើមនៅសតវត្សទី៦ ក្នុងប្រទេសក្រិច។ ដោយគេបានរកឃើញនឹងមានភស្តុតាងបានបញ្ជាក់ថាផ្លូវដែក Diolkos មានប្រវែងពី ៦ ទៅ ៨,៥ គីឡូម៉ែត្រដែលធ្វើឡើងសម្រាប់ដឹកជញ្ជូនទូកនៅទីក្រុង Isthmus។ ចំណែកឯរថភ្លើងត្រូវបានគេបង្កើតឡើងដោយឈើហើយរថភ្លើងនេះអាចដំណើរការទៅបានដោយសារម៉ាស៊ីនចំហាយទឹករបស់ថូម៉ាស ដែលឧបករណ៍នេះធ្លាប់បានគេយកទៅប្រើប្រាស់ដើម្បីបូមទឹកចេញពីមីន ម៉ាស៊ីនចំហាយទឹកនេះត្រូវបានរកឃើញដោយលោក James Watt ដែលលោកជាវិស្វករមេកានិចស្កុតឡេន[4]។

រហូតមកដល់ខែកក្កដា ឆ្នាំ១៩១៨ ក្នុងសង្គ្រាមលោកលើកទី១ ក៏បានលិចរូបរាងយន្តហោះចម្បាំងឡើង ការបង្កើតយន្តហោះចម្បាំងនេះគឺមកពីសហរដ្ឋអាមេរិច បង្កើតឡើងទុកសម្រាប់ធ្វើការប្រយុទ្ធជាមួយ HMS Furious (នាវាចម្បាំងរបស់ចក្រភពអង់គ្លេស) និងធ្វើការវាយឆ្មក់ឬវាយប្រហារនឹងឃ្លាំង Zeppelin នៅ ទីក្រុងTonder នៃភាគខាងត្បូងនៃប្រទេសដាណឺម៉ាក។

មនុស្សចេះតែកើនឡើង ការអភិវឌ្ឍន៍ក៏កើនឡើងផងដែរនោះ លោក Nicolas-Joseph Cugnot បានបង្កើតរថយន្តដើរដោយចំហាយទឹកក្នុងឆ្នាំ១៧៦៩ ដែលអាចដឹកអ្នកដំណើរបាន។ បន្ទាប់មកក្នុងឆ្នាំ១៨០៨ លោក Francois Isaac de Rivaz បានបង្កើតរថយន្តដែលបំពាក់ដោយម៉ាស៊ីនដុតភ្លើងខាងក្នុងដែលត្រូវបានបង្កដោយអ៊ីដ្រូសែន។ ក្នុងឆ្នាំ១៨៨៥ លោក Karl Benz បានបង្កើតរថយន្តដែលត្រូវបានប្រើសាំងឬម៉ាស៊ូត យានយន្តនេះត្រូវបានបំពាក់ម៉ាស៊ីន ៤ ដើម្បីធ្វើឱ្យរថយន្តអាចដំណើរការទៅបាន[5]។

[3] https://HMS-Furious.com

[4] https://History_of_rail_transport.

[5] https://en.wikipedia.org/wiki/car.History_of_the_car.

យោងទៅតាមការសង្កេតដែលគួរឱ្យកត់សម្គាល់បានរកឃើញថាសេវាដឹកជញ្ជូនត្រូវបានគេប្រើប្រាស់ជាច្រើនផ្នែក និងច្រើនទម្រង់ ដោយយោងទៅតាមការស្រាវជ្រាវយើងអាចសន្និដ្ឋានបានថាការដឹកជញ្ជូនត្រូវបានគេបែងចែកជាបួនមានដូចជា ការដឹកជញ្ជូនតាមផ្លូវទឹក , ផ្លូវដែក , ផ្លូវគោក នឹងផ្លូវអាកាស។ ទៅតាមទិដ្ឋភាពជាក់ស្តែងប្រជាជនទូទាំងសកលលោកបានជ្រើសរើសការដឹកជញ្ជូនតាមផ្លូវគោកច្រើនជាងគេ។ ដូច្នេះហើយទើបរដ្ឋាភិបាលបានបង្កើតសេវាដឹកជញ្ជូនមួយ ដែលអាចដឹកអ្នកដំណើរបានច្រើន ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ ,គ្រោះថ្នាក់ចរាចរណ៍ និងជួយឱ្យជីវភាពរបស់ប្រជាជនកាន់តែរីកចម្រើនដោយមិនបាច់ចំណាយថវិកាច្រើនទៅលើការទិញរថយន្ត និង ការចាក់សាំង ឬម៉ាស៊ូតសម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូនអីវ៉ាន់របស់ពួកគេនោះទេ។

ដោយយោងទៅតាមការស្រាវជ្រាវបានរកឃើញថា ការដឹកជញ្ជូនជាសាធារណៈត្រូវបានបង្កើតឡើងក្នុងប្រទេសអង់គ្លេស ដោយមើលឃើញការរីកចម្រើនក្នុងវិស័យមួយនេះនោះ ទើបធ្វើឱ្យប្រទេសដ៏ទៃទៀតបង្កើតសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈនេះឡើងជាបន្តបន្ទាប់ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋសម្រាប់ទទួលបានអត្ថប្រយោជន៍ផ្សេងៗនៅពេលដែលពួកគាត់ទទួលយកសេវាមួយនេះ ហើយខាងក្រោមនេះគឺជាប្រទេសដែលបានបង្កើតនូវសេវាដឹកជញ្ជូនរថយន្តសាធារណៈមុនគេបង្អស់នៅលើពិភពលោក៖

**ក. ប្រទេសអង់គ្លេស**

ការដឹកជញ្ជូនជាសាធារណៈត្រូវបានធ្វើការពិសោធន៍ នៅក្នុងទីក្រុងប៉ារីសនៅដើមឆ្នាំ ១៦៦២ ដោយលោក John Greenwood ដែលមានភស្តុតាងបង្ហាញពីផ្លូវរថយន្ត ដែលសេវានេះត្រូវបានធ្វើការគ្រោងទុកពី Market Street នៅក្នុងទីក្រុង Manchester ទៅកាន់ Pendleton ក្នុងទីក្រុង Salford នៃចក្រភពអង់គ្លេស។

លោក John Greenwood បានកើតនៅឆ្នាំ ១៧៨៨ ហើយបានស្លាប់ទៅវិញនៅឆ្នាំ ១៨៥១ លោកគឺជាសហគ្រិនម្នាក់នៅផ្នែកដឹកជញ្ជូន ហើយគាត់ក៏ជាមនុស្សដែលធ្វើការនៅច្រកទ្វារព្រលានយន្តហោះនៅប៉េឡេលតុននៅលើទឹកដី Manchester ទៅកាន់ Liverpool Turnpike។ ក្នុងឆ្នាំ១៨២៤ លោកបានទិញសេះ និង រទេះមួយដែលមានកៅអីជាច្រើនហើយលោកក៏មានគំនិតចាប់ផ្តើមបង្កើតសេវារថយន្តក្រុងឡើង ប៉ុន្តែពេលនោះលោកមិនទាន់បានហៅថារថយន្តក្រុងនៅឡើយទេ គឺលោកបានហៅថា«សេះដឹកកៅអីច្រើន»សម្រាប់ទុកឱ្យមនុស្សធ្វើដំណើរ។ គំនិតរបស់លោកមុនគេបង្អស់គឺលោកចង់ផ្តល់សេវាដឹកជញ្ជូនមួយដោយមិនបាច់មានការកក់ប្រាក់មុន ឬកក់កន្លែងទុកសម្រាប់អង្គុយនោះទេ ចំណែកឯអ្នកបើកបរវិញគឺបើកទៅគ្រប់ទីកន្លែងដែលអ្នកដំណើរចង់ទៅ។ ក្រោយមក

លោកបានបន្ថែមថា សេវាដឹកជញ្ជូនដែលកំពុងតែប្រើប្រាស់ប្រចាំថ្ងៃគួរតែដំណើរការនៅទីក្រុង Buxton, Chester នឹង Sheffield។

លោក John Greenwood រួមជាមួយនឹងដៃគូរប្រកួតប្រជែងរបស់លោក ក៏ចាប់ផ្តើមនាំគ្នាបង្កើតបណ្តាញសេវាផ្នែកឡានក្រុងមួយ និងមុនគេបង្អស់នៅ United kingdom នៅឯចក្រភពអង់គ្លេស។ ក្នុងឆ្នាំ១៨៥១ លោក John Greenwood បានស្លាប់ហើយលោកក៏បានផ្ទេរមុខជំនួញដែលមានភាពរីកចម្រើនរបស់លោកមួយនេះឱ្យទៅកូនប្រុសរបស់លោកដែលគាត់នេះក៏មានឈ្មោះថា John (II)[6]ដែរ។ ក្នុងឆ្នាំ១៨៨០ ក្រុមហ៊ុនដឹកជញ្ជូនរថយន្តក្រុងបានចាប់កំណើតឡើងក្នុងក្រុមហ៊ុន Manchester Carriage នឹង Tramways ដោយដឹកនាំដោយលោក John Greenwood (II)។ ប្រទេសអង់គ្លេសក៏បានបន្តសេវាកម្មដឹកជញ្ជូននោះរហូតមកដល់សព្វថ្ងៃ។ ដោយបានមើលឃើញនៃការជឿនលឿនពីសេវាដឹកជញ្ជូននេះរួច បន្ទាប់មកប្រទេសអាមេរិច និងទីក្រុងឡុង (London) ក៏បានបង្កើតឡើងនៅសេវាដឹកជញ្ជូននេះផងដែរ។

## ខ. សហរដ្ឋអាមេរិច

សេវារថយន្តក្រុងរបស់ប្រទេសអាមេរិចត្រូវបានបង្កើតឡើងនៅឆ្នាំ១៨២៩ ដោយលោក Abraham Brower ដែលលោកជាសហគ្រិនម្នាក់ដែលស្ម័គ្រចិត្តក្នុងការបង្កើតផ្លូវមួយសម្រាប់ទុកឱ្យឡានក្រុងធ្វើដំណើរ ការសាងសង់ផ្លូវនោះគឺនៅតាមបណ្តោយផ្លូវ Broadway ដល់ Bowling Green រហូតដល់ឆ្នាំ១៨៣១ ដល់ ១៨៣៥ បានពង្រីកដល់ Philadelphia និង ក្នុងឆ្នាំ១៨៤៤ ដល់ទីក្រុង Baltimore។ ដោយពេលនោះរដ្ឋាភិបាលបានផ្តល់សិទ្ធិទៅឱ្យក្រុមហ៊ុនឯកជនជាអ្នកធ្វើអាជីវកម្មរបស់គេផ្ទាល់ ហើយអាចដាក់ស្លាកយីហោផ្តាច់មុខរបស់ពួកគេផងដែរ ប៉ុន្តែរដ្ឋាភិបាលបានដាក់កម្រិតតម្លៃ និង ផ្លូវនីមួយៗសម្រាប់ឱ្យក្រុមហ៊ុនឯកជនផ្តាច់មុខតែម្តង។

នៅក្នុងឆ្នាំ១៨៣២ ទីក្រុង New York បានបង្កើតរថយន្តក្រុងដែលធ្វើដំណើរតាមផ្លូវដែកដែលមានល្បឿនលឿនជាងរថយន្តក្រុងដែលរត់នៅតាមផ្លូវថ្នល់ និងត្រូវបានប្រើប្រាស់ជាប្រព័ន្ធអគ្គីសនី។ រថយន្តនេះត្រូវបានបង្កើតឡើងដោយលោក John Mason ដែលលោកជាអ្នកមានស្តុកស្តម្ភម្នាក់ ហើយលោកបានឱ្យអ្នកមៅការម្នាក់ជាអ្នកសាងសង់ ដោយលោកមានឈ្មោះថា John Stephenson[7]។

---

[6] https://en.wikipedia.org/wiki/John_Greenwood_(bus_operator)

[7] https://en.m.wikipedia.org/wiki/public_transport_bus_service

សេវាដឹកជញ្ជូននេះត្រូវបានពង្រីកវិសាលភាពនៃទីក្រុងដែលកំពុងតែរីកចម្រើន ហើយក៏បានក្លាយជាបេះដូងពាណិជ្ជកម្មសម្រាប់ទីក្រុង និងជួយសម្រួលដល់ជីវភាពរបស់ប្រជាជនព្រមទាំងជួយឱ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសតទៅមុខទៀត ហើយផ្នែកថ្មីរបស់ទីក្រុងក៏បានឈានដល់ចំណុចកំពូលដែលមិនត្រូវមានការបែងចែកគ្នារវាងអ្នកគ្មាន និង អ្នកមានរថយន្តផ្ទាល់ខ្លួននោះទេ។ ម៉្យាងវិញទៀត សេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈគឺបានផ្តល់ជូនប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដោយអ្នកណាក៏មានសិទ្ធិប្រើប្រាស់វាបានដែរ។

**១.១.១. និយមន័យ**

ដើម្បីយល់ពីអត្ថន័យក្នុងប្រធានបទឱ្យបានកាន់តែច្បាស់ យើងបានរៀបរាប់ពីប្រវត្តិនៃការកកើតនៃសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈរួចមកហើយនោះ ឥឡូវនេះយើងនិងធ្វើការពន្យល់បន្ថែមទៀតដើម្បីឱ្យមិត្តអ្នកអានយល់ពីអត្ថន័យកាន់តែច្បាស់លើពាក្យថា «សេវាដឹកជញ្ជូនសាធារណៈ»នេះផងដែរ៖

ជាទូទៅសេវាសាធារណៈ គឺជាសេវាកម្មដែលបានផ្តល់ដោយរដ្ឋាភិបាល ទៅកាន់ប្រជាជនដែលរស់នៅក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួនដោយផ្ទាល់ តាមរយៈវិស័យសាធារណៈ ឬដោយការផ្តល់ជាហិរញ្ញវត្ថុដល់ផ្នែកឯកជនក្នុង ការផ្គត់ផ្គង់សេវានោះជំនួសវិញ។ សេវាសាធារណៈរួមមាន ការអប់រំ ការការពារបរិស្ថាន អគ្គិសនី សុខាភិបាល ការអនុវត្តច្បាប់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការផ្គត់ផ្គង់ទឹក ប្រៃសនីយ៍ ទូរគមនាគមន៍ និងការគ្រប់គ្រងសម្រាប់សេវាការពារជាតិ ...[8]។

តាមបណ្ឌិត សាយ បូរី បានបញ្ជាក់ថាសេវាសាធារណៈមានន័យ ៣ យ៉ាង៖

១. សេវាសាធារណៈ គឺជាអង្គការដែលមានបុគ្គលិក ភ្នាក់ងារធ្វើការ និងជាមធ្យោបាយសម្រាប់បម្រើផលប្រយោជន៍សាធារណៈ។ រដ្ឋ និងសមូហភាពវិជ្ជការ អាចបង្កើតសេវាសាធារណៈបានដោយខ្លួនឯង។

២. សេវាសាធារណៈ គឺជាសកម្មភាពដែលបម្រើផលប្រយោជន៍ទូទៅរបស់រដ្ឋ។ សកម្មភាពទាំងនេះ ជួនកាលកាន់កាប់ដោយរដ្ឋខ្លួនឯងផ្ទាល់ ហៅថា «រដ្ឋាករ» ជួនកាលរដ្ឋប្រគល់ឱ្យឯកជនកាន់កាប់ ប៉ុន្តែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ហៅថា « សម្បទានសេវាសាធារណៈ »។

៣. សេវាសាធារណៈ គឺជាអត្ថន័យសំខាន់មួយនៃនីតិរដ្ឋបាល ដែលសំដៅលើសកម្មភាពរបស់រដ្ឋក្នុងរបបគតិយុត្តពិសេស ឬ របបគតិយុត្តបដិប្បញ្ញត្តិពីគតិរួម។

[8] https://en.m.wikipedia.org/wiki

តាមវចនានុក្រមខ្មែរពាក្យថា សេវាសាធារណៈគឺជាសកម្មភាពទាំងឡាយណាដែលមានលក្ខណជានិរន្តរភាព ក្នុងគោលដៅបំពេញសំណូមពររបស់ប្រយោជន៍រួម ហើយដែលត្រូវរ៉ាប់រង ឬត្រូវត្រួតពិនិត្យដោយរដ្ឋបាលសាធារណៈ[9]។

ចំណែកឯពាក្យថាដឹកជញ្ជូនវិញគឺមានន័យថា

ដឹក + ជញ្ជូន

- ដឹក មានន័យថា នាំយកទៅមកដោយព្រាងផ្ទុកមានរទេះទូកជាដើម (ដឹកឈើ ដឹកឧស ដឹកស្រូវ) ឬ ចំនួន ទម្ងន់ ដែលល្មមដឹកនាំយកទៅមកបាន[10]។
- ជញ្ជូន មានន័យថា នាំយកអ្វីៗពីទីមួយទៅទីមួយ (ចំពោះតែរបស់ច្រើន)[11]។

ដូច្នេះពាក្យ ដឹកជញ្ជូន មានន័យថា គឺជាវត្ថុម្យ៉ាងដែលអាចផ្ទុក ចំនួន ទម្ងន់ ដែលសមល្មមពីកន្លែងមួយទៅកន្លែងមួយបាន។

សរុបមក សេវាដឹកជញ្ជូនសាធារណៈ គឺជាប្រព័ន្ធដឹកជញ្ជូនសាធារណៈមួយដែលរដ្ឋជាអ្នកបង្កើតឡើងសម្រាប់ឱ្យប្រជាជនប្រើប្រាស់ និង ធ្វើដំណើរបានជាសាធារណៈ ឬ ជាការដឹកជញ្ជូនអ្នកដំណើរ ដោយប្រព័ន្ធដឹកជញ្ជូនជាក្រុមដែលអាចប្រើប្រាស់បានដោយសាធារណៈជនទូទៅ ដោយគ្រប់គ្រងតាមកាលវិភាគនៃដំណើរការនៅលើផ្លូវដែលបានបង្កើតឡើង។

ការដឹកជញ្ជូនជាសាធារណៈត្រូវបានគេបែងចែកជា ៣ ធំៗគឺ ៖

១. ការដឹកជញ្ជូនតាមទីក្រុងដែលត្រូវបានគេបែងចែកជា ៥ សេវាទៀតមានដូចជា៖

- សេវាទីប្រជុំជន ឬតំបន់ទីក្រុង គឺជាប្រភេទសេវាដឹកជញ្ជូនសាធារណៈទូទៅបំផុតហើយត្រូវបានប្រើប្រាស់ដើម្បីដឹកជញ្ជូនមនុស្សយ៉ានច្រើននៅក្នុងតំបន់ទីក្រុង ទៅតំបន់ជាយក្រុង។
- សេវាឡានក្រុង Express គឺជាសេវាកម្មដែលមានល្បឿនលឿនជាងសេវាកម្មរថយន្តក្រុងធម្មតា ដោយដំណើរការជា «សេវាកម្មមានកំណត់» ដែលបានធ្វើដំណើរក្នុងផ្លូវលឿន «ផ្លូវហាយវេ» ខុសពីយានយន្តក្នុងស្រុកដែលធ្វើដំណើរតាមផ្លូវធម្មតា។
- ឧទ្យានក្រុង ត្រូវបានគេបង្កើតឡើងដើម្បីផ្តល់ជូននៅកន្លែងអ្នកធ្វើដំណើររង់ចាំ។

---

[9] វចនានុក្រមខ្មែរ ព.ស. ២៥៥៥ គ.ស.២០១១។

[10] វចនានុក្រមខ្មែរ ព.ស. ២៥១១ គ.ស. ១៩៦៧។

[11] វចនានុក្រមខ្មែរ ព.ស. ២៥១១ គ.ស. ១៩៦៧។

- សេវាកម្មឡានដឹកទំនិញ ត្រូវបានគេរៀបចំឡើង ដើម្បីដឹកអ្នកដំណើរនៅតាមតំបន់ជាក់លាក់ហើយយកទៅកន្លែងមួយទៀតដែលពួកគេធ្វើដំណើរទៅមក (សេវារថយន្តក្រុង)។ ឡានដឹកទំនិញអាចដើរតួរជាផ្នែកមួយនៃបណ្តាញក្នុងស្រុកដ៏ទូលំទូលាយ សម្រាប់ដឹកទំនិញ។
- ការដឹកជញ្ជូនតាមរថយន្តក្រុង (BRT) គឺជាការអនុវត្តនូវហេដ្ឋារចនាសម្ព័ន្ធ និង វិធានការទីផ្សារដើម្បីបង្កើតសេវារថយន្តដឹកជញ្ជូនសាធារណៈ ដែលទាក់ទងនិងលក្ខណប្រតិបត្តិការ និង សមត្ថភាពនៃប្រព័ន្ធដឹកជញ្ជូនយ៉ាងលឿន។

២. ការដឹកជញ្ជូនចម្ងាយឆ្ងាយ គឺជាសេវាកម្មឡានក្រុងដែលអាចបង្កើតបានជាបណ្តាញទេសចរណ៍នៅក្នុងប្រទេសដែលមានហេដ្ឋារចនាសម្ព័ន្ធ។ សេវាកម្មរថយន្តក្រុងមានគោលបំណងតភ្ជាប់មជ្ឈមណ្ឌលទីក្រុងមួយ ឬច្រើនទៅទីក្រុងមួយទៀត ហើយជាញឹកញាប់ត្រូវបានដំណើរការជាសេវារហ័សខណៈពេលដែលធ្វើដំណើរនៅតំបន់ជនបទ គឺគ្រាន់តែហៅទូរស័ព្ទទៅចំណុចចំណត ឡានក្រុងនិងមកដល់កន្លែងយ៉ាងឆាប់រហ័សដោយមិនមានការដឹកជញ្ជូនអ្នកដំណើរយឺតយ៉ាវនោះទេ។

៣. សេវាកម្មអ្នកឯកទេស ត្រូវបានគេចែកជា ៣ ចំណុចមាន៖

- ឡានក្រុងសាលា ដឹកកុមារទៅនិងមកពីសាលារៀន ខណៈពេលដែលសាលារៀននៅឆ្ងាយពីពួកគេ ការអនុវត្តនៃសេវាកម្មនេះពិសេសនៅត្រង់តារាងពេលវេលាសាធារណៈ ជាទូទៅត្រូវបានកំណត់ពេលវេលាជាក់លាក់ទៅតាមម៉ោងចូលនិងចេញរបស់កណ្តឹងសាលា។
- ឡានក្រុងដឹកទំនិញ គឺជាសេវាកម្មឡានក្រុងដែលសម្រាប់ដឹកអ្នកដំណើរក្នុងយន្តហោះរវាងចំណុចថេរពី។
- សេវាកម្មរថយន្តក្រុង គឺជាសេវាកម្មដែលដឹកជញ្ជូនតាមអ៊ីម៉ែល (Email) ជាញឹកញាប់តាមជនបទ។

### ១.១.២ ការហូរចូលសេវាដឹកជញ្ជូនសាធារណៈមកទ្វីបអាស៊ី

មិនមែនតែក្នុងទ្វីបអឺរ៉ុបនោះទេដែលមានសេវាដឹកជញ្ជូនជាសាធារណៈ ចំណែកឯនៅក្នុងទ្វីបអាស៊ីយើងនេះក៏មានការបង្កើតនូវសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងផងដែរ ហើយការបង្កើតនេះគឺជាការផ្តល់ឱ្យប្រជាពលរដ្ឋប្រើប្រាស់នៅសេវាកម្មសាធារណៈជាបន្តបន្ទាប់ផងដែរ។ យើងឃើញថាបណ្តាប្រទេសនៃអាស៊ីមួយចំនួនបានរៀបចំ ប្រព័ន្ធនៃសេវារថយន្តក្រុងសាធារណៈ

បានល្អប្រសើរហើយដូចជា ប្រទេសចិន ជប៉ុន សិង្ហបុរី ឥណ្ឌា...ជាដើម ហើយប្រទេសមួយចំនួនក៏កំពុងតែធ្វើការអភិវឌ្ឍន៍ជាបន្តបន្ទាប់ដែរ លើសេវាកម្មមួយនេះ។

**ក.ប្រទេសចិន**

ប្រទេសចិនគឺជាប្រទេសមួយដែលយើងអាចនិយាយបានថាជាប្រទេសដែលអភិវឌ្ឍលើគ្រប់វិស័យ ដូចជាវិស័យដឹកជញ្ជូនជាដើម ហើយប្រទេសចិនក៏ជាប្រទេសមួយដែលបង្កើតសេវាដឹកជញ្ជូនសម្រាប់ដឹកអ្នកដំណើរមុនគេបង្អស់ក្នុងទ្វីបអាស៊ីនេះដែរ។ ទីក្រុងប៉េកាំងគឺជាទីក្រុងដ៏ធំមួយដែលមានភាពចាំបាច់ឱ្យប្រទេសនោះអភិវឌ្ឍន៍លើវិស័យដឹកជញ្ជូនសាធារណៈបានយ៉ាងឆាប់រហ័ស និង មានប្រសិទ្ធភាព។ ឆ្នាំ១៩២១ សេវាឡានក្រុងសាធារណៈ បានចាប់ផ្តើមដោយមានអ្នកបើកបរចំនួន ពីរនាក់ (ព្រឹក និង ល្ងាច) រថយន្តដឹកជញ្ជូនសាធារណៈសំខាន់បំផុតសម្រាប់ក្រុងប៉េ-កាំងដែលក្រុមហ៊ុនដឹកជញ្ជូនសាធារណៈរបស់ប៉េកាំងបានគ្រប់គ្រងដោយរដ្ឋនឹងមានប្រតិបត្តិការស្ទើរតែគ្រប់ផ្លូវថ្នល់ តាមតម្លៃសំបុត្ររថយន្តរបស់ក្រុមហ៊ុនចាប់ផ្តើមពី RMB (លុយចិន) ¥¥២.០០ (២៤០០រៀល) ក្នុងការធ្វើដំណើរម្តង។ សេវាកម្មឡានក្រុងចាប់ផ្តើមដំណើរការពីចន្លោះម៉ោង ៥:០០-៦:០០ព្រឹក និងបញ្ចប់នៅចន្លោះម៉ោង ២០:០០-២៣:០០យប់ សម្រាប់វេនព្រឹក និង វេនយប់ចាប់ផ្តើមពីម៉ោង ២៣:២០ នាទី ដល់ ៤:៣០ នាទី។ តម្លៃទូទៅគឺ ¥¥២.០០ ប៉ុន្តែសម្រាប់អ្នកមាន IC Card ត្រូវបានបញ្ចុះតម្លៃ ៥០ភាគរយ (¥១.០០) សម្រាប់អ្នកជិះរទេះរុញមានប័ណ្ណ Metro និងសិស្សទទួលបានការបញ្ចុះតម្លៃ ៧០ភាគរយ ចំណែកក្មេងដែលមានកម្ពស់ក្រោម ១.២ម៉ែត្រ ,អ្នកទទួលប័ណ្ណសរសើរកិត្តិយស និង ជនពិការ ត្រូវបានជិះដោយឥតគិតថ្លៃ[12]។ ចំណតរថយន្តក្រុងត្រូវបានសម្គាល់ដោយបង្ហាញពីឈ្មោះកន្លែងរង់ចាំ, លេខផ្លូវ, ម៉ោងប្រតិបត្តិការ, ផ្លាកសញ្ញារថយន្តក្រុងដែលមានអក្សរជាភាសាចិន។ បច្ចុប្បន្នក្រុងប៉េកាំងមានប្រព័ន្ធដឹកជញ្ជូនដែលមានលក្ខណល្អប្រសើរ ដែលរួមមានឡានក្រុងប្រភេទផ្សេងៗដែលធ្វើដំណើរតាមបណ្តោយផ្លូវចម្រុះ។

**ខ.ប្រទេសជប៉ុន**

ប្រជាពលរដ្ឋនៅក្នុងប្រទេសជប៉ុនភាគច្រើនបានជ្រើសរើសប្រើប្រាស់នូវសេវាដឹកជញ្ជូនរថយន្តក្រុងដើម្បីធ្វើដំណើរជុំវិញទីក្រុងឬទៅទិសដៅរបស់ពួកគេចង់ទៅ។ ការប្រើប្រាស់ឡានក្រុងក្នុងតំបន់មានប្រយោជន៍ណាស់ជាពិសេសនៅក្នុងទីក្រុងធំៗ ដូចជាទីក្រុងគីអូតូជាដើម។ លើសពីនេះទៅទៀតរថយន្តក្រុងនៅតាមដងផ្លូវគឺជាមធ្យោបាយតែមួយគត់ដើម្បីទទួលបាននូវអាថ៌កំបាំងក្នុង

[12] https://en.wikipedia.org/wiki/Beijingbus

អំឡុងពេលដែលកំពុងប្រើប្រាស់សេវាមួយនេះរបស់ប្រទេសជប៉ុនដែលជាដំណើរកម្សាន្តទៅកាន់ទីក្រុងតូចៗដែលស្ថិតនៅជ្រលងភ្នំ[13]។

រថយន្តក្រុងត្រូវបានប្រទេសជប៉ុនហៅថា រថយន្ត «R Bus» សំដៅទៅលើប្រតិបត្តិការរថយន្តរបស់ក្រុមហ៊ុនផ្លូវដែកជប៉ុន (JR Group) នៅក្នុងប្រទេសជប៉ុន។ JR Bus ត្រូវបានដំណើរការដោយក្រុមហ៊ុនក្នុងតំបន់ចំនួន ៨ ដែលគ្រប់គ្រងដោយក្រុមហ៊ុនផ្លូវដែក JR ក្រុមហ៊ុនរថយន្តក្រុង JR ផ្តល់នូវសេវាដឹកជញ្ជូនតាមរថយន្តក្រុងដែលមានរយៈចម្ងាយឆ្ងាយនិងសេវាដឹកជញ្ជូន។ រថយន្តក្រុង R Bus ត្រូវបានចាប់ផ្តើមប្រតិបត្តិការរថយន្តក្រុងលើកដំបូងរបស់ខ្លួននៅខេត្តអាគីជីក្នុងឆ្នាំ១៩៣០ ក្រុមហ៊ុនផ្លូវដែកជាតិជប៉ុន (JNR) ដែលជាអាជីវកម្មសាធារណៈដែលបានបង្កើតឡើងនៅឆ្នាំ១៩៤៩ បានទទួលជោគជ័យលើប្រតិបត្តិការឡានក្រុងបន្ទាប់មកហៅថារថយន្តក្រុង Kokutetsu ឬ JNR Bus ។ នៅឆ្នាំ១៩៨៧ JNR ត្រូវបានបែងចែកទៅជាក្រុមហ៊ុនផ្លូវដែកតាមតំបន់រួមជាមួយនឹងប្រតិបត្តិការឡានក្រុង ក្រោយមកក្រុមហ៊ុន JR បានបំបែកប្រតិបត្តិការរថយន្តក្រុងរបស់ខ្លួនទៅកាន់ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅឆ្នាំ ១៩៨៨ (JR East, JR Central, JR West) ឆ្នាំ ២០០០ (JR Hokkaido) ឆ្នាំ២០០១ (JR Kyushu) និងឆ្នាំ ២០០៤ (JR Shikoku)[14]។

របៀបនៃការធ្វើដំណើររបស់រថយន្តក្រុងនៅក្នុងប្រទេសជប៉ុន៖

១.អ្នកដំណើរត្រូវឆ្លងកាត់តាមទ្វាដែលនៅខាងក្រោយឡានក្រុង

២.នៅពេលចូលឡានក្រុងសូមយកសំបុត្រពីម៉ាស៊ីនដែលស្ថិតនៅជិតទ្វា

៣.រកកន្លែងអង្គុយដោយខ្លួនអ្នកផ្ទាល់

៤.រកមើលម៉ាស៊ីនអេឡិចត្រូនិចដែលនៅក្បែរអ្នកបើកបរ ព្រោះម៉ាស៊ីនេះវានឹងបង្ហាញពីចំណតបន្ទាប់ដែលត្រូវឈប់។ ចំណែកឡានក្រុងនៅក្នុងតំបន់ទេសចរណ៍ដ៏ពេញនិយមនៅក្នុងប្រទេសជប៉ុនឡានក្រុងនោះមានជាការដាក់បង្ហាញពីការបកប្រែជាភាសាអង់គ្លេស ប៉ុន្តែសម្រាប់រថយន្តក្រុងណាដែលមិនស្ថិតនៅក្នុងតំបន់ទេសចរណ៍វិញនោះគឺមិនមាននោះទេ

៥.នៅពេលដែលអ្នកចង់ឈប់អ្នកដំណើរត្រូវតែស្វែងរក ប៊ូតុងដែលមានពណ៌លឿង ឬស្វាយនៅលើជញ្ជាំងដែលមានជាភាសាជប៉ុនហៅថា "Tomarimasu" ដែលមានន័យថា "នឹងបញ្ឈប់" រួចចុចប៊ូតុងនោះដើម្បីជាសញ្ញាដល់អ្នកបើកបរបានដឹងថាអ្នកដំណើរចង់ឈប់នៅចំណតខាងមុខ

[13] https://www.jrailpass.com/blog/how-to-use-the-local-bus

[14] https://en.wikipedia.org/wiki/JH_Bus

៦.អ្នកត្រូវបង់ថ្លៃសំបុត្ររថយន្តក្រុងនៅពេលអ្នកចាកចេញ ប្រសិនបើអ្នកមានកាត JR Pass អ្នកគ្រាន់តែបង្ហាញកាតរបស់អ្នកទៅកាន់បើកបរជាការស្រេចដោយមិនចាំបាច់បង់ថវិកានោះទេ។ ប៉ុន្តែប្រសិនជាអ្នកមិនមានកាតនោះទេអ្នកត្រូវបង់ប្រាក់ ដោយដាក់ប្រាក់នោះចូលទៅក្នុងប្រអប់មួយដែលនៅក្បែរអ្នកបើកបរ ដោយអ្នកគ្រាន់តែវាយលេខទូរស័ព្ទរបស់អ្នកនៅលើអេក្រង់អេឡិចត្រូនិចមួយនោះជាការស្រេច ហើយម៉ាស៊ីននេះនឹងបង្ហាញអ្នកនូវថ្លៃឈ្នួលរបស់អ្នក។ ប្រសិនបើអ្នកត្រូវការផ្លាស់ប្តូរជាវិក័យបត្រវិញ ម៉ាស៊ីននឹងធ្វើការផ្លាស់ប្តូរមានទីតាំងនៅជិតអ្នកបើកបរ បន្ទាប់មកអ្នកត្រូវទម្លាក់សំបុត្ររថយន្តរួមជាមួយនឹងសំបុត្ររបស់អ្នកចូលទៅក្នុងប្រអប់មានតម្លាភាពមួយនៅក្បែរអ្នកបើកបរ បន្ទាប់ពីទម្លាក់សំបុត្ររួចហើយនោះអ្នកអាចចាកចេញពីឡានក្រុងបាន។

**គ.ប្រទេសសិង្ហបុរី**

រដ្ឋាភិបាលរបស់ប្រទេសសិង្ហបុរីបានចាប់ផ្តើមមានគំនិតឱ្យមានការបង្កើតនូវក្រុមហ៊ុនឡានក្រុងនៅដើមទសវត្សឆ្នាំ១៩៨០។ ដូច្នេះសេវាកម្មដឹកជញ្ជូនតាមរថយន្តក្រុង Trans-Island (TIBS) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៨២ ដោយក្រុមហ៊ុនដឹកជញ្ជូនសាធារណៈ Trans-Island ដែលបានចាប់ផ្តើមប្រតិបត្តិការនៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ១៩៨៣[15]។

ការដឹកជញ្ជូនតាមរថយន្តក្រុងគឺជាផ្នែកមួយដ៏សំខាន់នៃការដឹកជញ្ជូនសាធារណៈនៅប្រទេសសឹង្ហបុរីដោយមានប្រជាពលរដ្ឋបានប្រើប្រាស់នៅសេវាមួយនេះលើសពី ៣,៩ លាននាក់ក្នុងមួយថ្ងៃដោយគិតជាមធ្យមគិតត្រឹមឆ្នាំ២០១៦ ដែលបានដំណើរការដោយក្រុមហ៊ុន SBS Transit, SMRT Buses, Transit Singapore និង Go-Ahead Singapore។ ប្រតិបត្តិការរថយន្តថ្មីបំផុត Go-Ahead ប្រទេសសិង្ហបុរីបានចាប់ផ្តើមប្រតិបត្តិការចាប់ពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៦ បច្ចុប្បន្នមានឡានក្រុងប្រមាណ ៤,៦០០គ្រឿង កំពុងប្រតិបត្តិការ។

របៀបនៃការធ្វើដំណើររបស់រថយន្តក្រុងនៅក្នុងប្រទេសសិង្ហបុរីៈ

១.អ្នកដំណើរត្រូវឆ្លងកាត់តាមទ្វាដែលនៅខាងមុខឡានក្រុង

២.ពេលចូលត្រូវទៅក្នុងឡានក្រុងអ្នកដំណើរត្រូវយកកាតដែលហៅថា «EZ Link Card » ទៅដាក់ជិតម៉ាស៊ីនអេឡិចត្រូនិចដើម្បីបង្ហាញពីទឹកប្រាក់ដែលអ្នកមាននៅក្នុងកាតនោះ

៣.រកកន្លែងអង្គុយដោយខ្លួនឯង

៤.នៅពេលដែលជិតដល់ចំណតត្រូវស្វែងរកប៊ូតុងសម្រាប់ចុចដើម្បីឱ្យអ្នកបើកបរបានដឹងជាមុនថាអ្នកចង់ឈប់នៅចំណតខាងមុខ

[15] https://en.wikipedia.org/wiki/Bus_transport_in_Singapore

៥.មុនចាកចេញត្រូវយកកាតទៅដាក់ជិតម៉ាស៊ីនតូចមួយដែលនៅជិតទ្វាចេញនៅខាងក្រោយ នៅពេលអ្នកធ្វើការដាក់កាតនោះនៅជិតម៉ាស៊ីន ម៉ាស៊ីននឹងទូទាត់ពីចម្ងាយដែលអ្នកបានជិះ និងថវិកាដែលអ្នកនៅសល់

៦.ចេញតាមច្រកទ្វាខាងក្រោយ

## ១.២ ការហូរចូលសេវាដឹកជញ្ជូនសាធារណៈមកកម្ពុជា

សេវាដឹកជញ្ជូនបានកើតឡើងតាំងពីសម័យសង្គមរាស្ត្រនិយមមកម្លេះ ប៉ុន្តែការដឹកជញ្ជូននេះមានលក្ខណជាការដឹកជញ្ជូនរបស់ក្រុមហ៊ុនឯកជន និង ជាការដឹកជញ្ជូនរបស់ប្រជាពលរដ្ឋដែលប្រើប្រាស់យានយន្តផ្ទាល់ខ្លួនរបស់ពូកគេសម្រាប់ប្រកបមុខរបរដើម្បីចិញ្ចឹមជីវភាពសព្វថ្ងៃរបស់ពួកគេតែប៉ុណ្ណោះ។ ឆ្នាំ១៦៧០ ដោយមានរបបប្រល័យពូជសាសន៍ប៉ុល ពត បានកើតឡើងដែលធ្វើឱ្យសេវាដឹកជញ្ជូនទាំងអស់ត្រូវបានបំផ្លាញ ហើយថែមទាំងបានធ្វើឱ្យប្រជាពលរដ្ឋពិបាកក្នុងការរស់នៅ និង ប្រកបរបរចិញ្ចឹមជីវិត។ រហូតមកដល់ថ្ងៃ ៧ មករា ឆ្នាំ១៩៩៣ កម្ពុជាបានស្តាររាល់អ្វីៗដែលត្រូវបានបំផ្លាញរួមទាំងសេវាដឹកជញ្ជូនផងដែរ។ ការអភិវឌ្ឍន៍លើវិស័យផ្សេងៗរួមទាំងហេដ្ឋារចនាសម្ព័ន្ធបានធ្វើឱ្យប្រទេសយើងរីកលូតលាស់ជាលំដាប់លំដោយនៃសោភ័ណភាពនៅទីក្រុង តំបន់ទេសចរណ៍ និងវិស័យផ្សេងៗទៀត ពិសេសសេវាសាធារណៈ។

### ១.២.១ ការចូលរួមសេវាដឹកជញ្ជូនរបស់ឯកជន

ជាទូទៅប្រជាពលរដ្ឋតែងតែប្រើប្រាស់មធ្យោបាយធ្វើដំណើរពីទីកន្លែងមួយទៅទីកន្លែងមួយតាមរបៀបផ្សេងៗគ្នា ដូចជាការធ្វើដំណើរតាមក្រុមហ៊ុនឯកជន តាមយាន្តជំនិះផ្ទាល់ខ្លួនជាដើម ហើយការប្រើប្រាស់យាន្តជំនិះក៏មានលក្ខណខុសៗគ្នាដែរដូចជា៖

+ស៊ីក្លូ

ស៊ីក្លូបានកើតមាននៅកម្ពុជា កាលពីអំឡុងពាក់កណ្តាលឆ្នាំ ១៨៨០ ទៅ ១៩០០ និយាយរួមក្នុងពេលបារាំងមកធ្វើអាណានិគម ហើយអ្នកធាក់ស៊ីក្លូគឺជាអ្នកដែលប្រកបមុខរបរមួយប្រើដោយកម្លាំងបាយ សុទ្ធសាធហើយភាគច្រើនជាអ្នកទីទាល់ក្រីក្រ និង គ្មានជម្រើសដើម្បីខិតខំរកប្រាក់បន្តិចបន្តួចសម្រាប់ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារជាប្រចាំថ្ងៃ ដោយឡែកនៅក្នុងសម័យទំនើបនេះចំនួនអ្នកធាក់ស៊ីក្លូមានការថយចុះជាខ្លាំងស្ទើរតែបាត់បង់រូបរាងទៅហើយ ដោយសារតែមានមធ្យោបាយធ្វើដំណើរតាមយានយន្តកាន់តែទំនើបទៅៗហើយណាមួយអតិថិជន បានបោះបង់ការគាំទ្រជាបន្តបន្ទាប់ទៀត។ ជាក់ស្តែងចំនួនអ្នកធាក់ស៊ីក្លូនៅក្នុងរាជធានីភ្នំពេញមានការធ្លាក់ចុះជាខ្លាំង បើប្រៀបធៀបទៅនឹងជិត ១០ ឆ្នាំមុន គឺពីមុនមានស៊ីក្លូជិត ១,៥០០ គ្រឿងតែមកដល់សព្វថ្ងៃមានស៊ីក្លូចរាចរណ៍នៅត្រឹមតែ ៤៤៧ គ្រឿងតែប៉ុណ្ណោះ ដែលសមាគម៍អភិរក្សស៊ីក្លូបាននឹងកំពុងធ្វើការអភិ

វក្ស និង ការពារបន្ទប់ពីមានការលើកឡើងរបស់សម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** កាលពីឆ្នាំ ២០១២ កន្លងមកនោះ។

+កង់ឌុប

កង់គឺជាឧបករណ៍ម្យ៉ាងដែលគេអាចយកមកប្រើប្រាស់ជាឧបករណ៍សម្រាប់ធ្វើជាមុខរបរអាជីវកម្មផ្គត់ផ្គង់ជីវភាពបានដែរ។ ភាគច្រើនគេមើលឃើញអាជីវកម្មមួយនេះនៅក្នុងតំបន់ទីប្រជុំជន ឬ នៅផ្សារ ដែលអ្នករត់កង់ឌុបនេះប្រើប្រាស់កម្លាំងរបស់ខ្លួនគាត់ផ្ទាល់ដើម្បីឱ្យកង់អាចដំណើរការទៅបាន។ ឧបករណ៍មួយនេះអាចផ្ទុកមនុស្សចំនួនម្នាក់ ឬពីរអ្នក និងអាចដាក់អីវ៉ាន់ផងដែរ កង់ឌុបអាចធ្វើដំណើរទៅបានដោយកម្លាំងផ្ទាល់របស់អ្នកបើកបរ។

+រទេះរុញ

រទេះរុញត្រូវបានប្រើប្រាស់ដោយកម្លាំងផ្ទាល់របស់អ្នកដែលរុញរទេះនោះ រទេះរុញត្រូវបានមើលឃើញថាមាននៅក្នុងផ្សារ ដោយអ្នកប្រកបមុខរបរមួយនេះគេអាចចិញ្ចឹមជីវិតរបស់ពួកគេដោយរុញអីវ៉ាន់ពីផ្នែកម្ខាងទៅផ្នែកម្ខាងមួយទៀត។ ចំណែកតម្លៃពួកគេជាអ្នកកំណត់ដោយខ្លួនឯងដោយមើលទៅលើចំនួនអីវ៉ាន់ ឬទម្ងន់របស់អីវ៉ាន់ និងចម្ងាយដែលពួកគេត្រូវរុញទៅដល់។

+ត្រីចក្រយានយន្ត (រម៉ក)

គឺជាទម្រង់នៃការដឹកជញ្ជូនសាធារណៈដែលប្រើប្រាស់នៅប្រទេសថៃ កម្ពុជា វៀតណាម និង ឡាវ។ ការកំណត់រចនាសម្ព័ន្ធតុកតុកមាន កាប៊ីនមួយតភ្ជាប់ទៅនិងម៉ូតូ ដែលប្រជាជនអាចជិះនៅក្នុងនោះបានចំនួន ៦ (ប្រាំមួយ) នាក់។ បច្ចុប្បន្នមនុស្សភាគច្រើនចូលចិត្តប្រើប្រាស់វាណាស់ព្រោះថាវាអាចផ្ទុកមនុស្សបានច្រើន និងមានភាពងាយស្រួលក្នុងការជិះ។

+រថយន្តតាក់ស៊ី (Taxi)

គឺជារថយន្តមួយគ្រឿងដែលអាចដឹកអ្នកដំណើរទៅកាន់ទីឆ្ងាយនិងទទួលបានសុវត្ថិភាពប្រជាជនដែលចង់ធ្វើដំណើរទៅទីឆ្ងាយភាគច្រើនពួកគេប្រើប្រាស់សេវាកម្មដឹកជញ្ជូននេះដោយសារតែពួកគេអាចជិះបានច្រើននាក់, ដាក់អីវ៉ាន់បានច្រើន, មិនក្តៅ, មានម៉ាស៊ីនត្រជាក់ដែលធ្វើឱ្យពួកគេមានអារម្មណ៍ថាស្រស់ថ្លា និងមានផាសុខភាព។ ចំពោះតម្លៃនៃការធ្វើដំណើរវិញចាប់ពី ២,០០០រៀល ឡើងទៅដោយគិតតាមចម្ងាយផ្លូវឆ្ងាយឬជិត។

ក្នុងឆ្នាំ ២០១៦ ក្រុមហ៊ុនបណ្តាញដឹកជញ្ជូនយក្ស Uber បានបង្កើតកម្មវិធី (App) ថ្មីមួយដែលផ្តល់នូវសេវាដឹកជញ្ជូនអ្នកដំណើរដែលចង់ទៅកន្លែងផ្សេងៗក្នុងតំបន់ ដោយគ្រាន់តែធ្វើការបញ្ជាហៅតាមកម្មវិធីលើទូរស័ព្ទជាការស្រេច។ ឡានដែលមានកម្មវិធីមួយនេះគេបានហៅថា«តាក់ស៊ីម៉ែត្រ» ចំពោះអ្នកដំណើរដែលបានប្រើប្រាស់នៅសេវានេះគឺមានភាពងាយស្រួលវិញព្រោះយើង

អាច មើលឃើញតម្លៃនឹងភ្នែក និងមិនបាច់តថ្លៃ ហើយវាបានធ្វើឱ្យអ្នកដំណើរមានទំនុកចិត្តខ្ពស់ក្នុងពេលជិះ។ សេវាកម្មនេះ គឺពេលឡើងជិះភ្លាម ដឹងតែគិតលុយភ្លាម គឺគិតជាគីឡូម៉ែត្រ ហើយតម្លៃសេវាកម្មក្រុមហ៊ុននោះជាអ្នកកំណត់តម្លៃដោយគិតចាប់ពី ៣,០០០ រៀល ក្នុង ១គីឡូម៉ែត្រ។

+ឡានឈ្នួល

គឺជារថយន្តមួយដែលដឹកអ្នកដំណើរទៅតាមតំបន់ផ្សេងៗ ដូចជាពីរាជធានីភ្នំពេញ ទៅតាមបណ្ដាខេត្តផ្សេងៗនៃប្រទេស ឡានឈ្នួលអាចផ្ទុកអ្នកដំណើរបានពី ២០-២៥ នាក់ ជាទូទៅតម្លៃនៃឡានឈ្នួលគឺយកទៅតាមចម្ងាយដែលអ្នកធ្វើដំណើរចង់ទៅ ប៉ុន្តែការយកថ្លៃសេវាគឺមិនមានលក្ខណៈថេរនោះទេ ដោយអ្នកបើកបរគឺជាអ្នកកំណត់តម្លៃខ្លួនឯង។ ចំពោះពេលបុណ្យទានធំៗដូចជា បុណ្យចូលឆ្នាំ បុណ្យអុំទូក បុណ្យភ្ជុំបិណ្ឌ តម្លៃនៃសេវាត្រូវបានឡើងថ្លៃទ្វេដង ឧទាហរណ៍ ភ្នំពេញ-កំពង់សោម តម្លៃធម្មតា ២០,០០០រៀល ប៉ុន្តែពេលដល់រដូវបុណ្យទានចូលមកដល់កើនរហូតដល់ ៥០,០០០រៀល។

+ម៉ូតូឌុប

គឺជាសេវាដឹកជញ្ជូនមួយដែលប្រជាពលរដ្ឋចូលចិត្តប្រើប្រាស់នៅពេលធ្វើដំណើរទៅកន្លែងណាដែលជិតៗដូចជា ទៅផ្សារ សាលា មន្ទីរពេទ្យ វត្តអារាម...តម្លៃនៃសេវាគឺគិតទៅតាមតំបន់ និងចម្ងាយ ដែលកំណត់ដោយអ្នកបើកបរយានយន្តជាអ្នកកំណត់ផ្ទាល់តែម្តង។ អ្នកដែលជ្រើសរើសការធ្វើដំណើរដោយប្រើប្រាស់មធ្យោបាយមួយនេះគឺអាចធ្វើដំណើរបានតែមួយម្នាក់ ឬពីរអ្នកតែប៉ុណ្ណោះក្នុងពេលធ្វើដំណើរម្តង។

+ម៉ូតូ និង រថយន្ត (ផ្ទាល់ខ្លួន)

គឺជាមធ្យោបាយមួយដែលជាលក្ខណៈឯកជន ដោយពួកគេបានប្រើប្រាស់លុយផ្ទាល់ខ្លួនសម្រាប់ទិញយានយន្តដែលខ្លួនស្រលាញ់ ឬរថយន្តដែលខ្លួនប្រាថ្នាចង់បានពីមុនមក មកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ពួកគេអាចធ្វើដំណើរបានដោយខ្លួនឯងដោយមិនចាំបាច់ពឹងពាក់អ្នកដំទៃ (ឯករាជ) ឬឱ្យកម្រៃទៅអ្នកដំទៃដើម្បីឱ្យអ្នកនោះបើកបរជូនអ្នកទៅដល់គោលដៅនោះទេ ពួកគេគ្រាន់តែចំណាយថវិកាផ្ទាល់ខ្លួនសម្រាប់ចាក់សាំង ឬប្រេងក្នុងយានយន្តរបស់ខ្លួនដើម្បីឱ្យម៉ាស៊ីនអាចដំណើរការទៅមុខបានតែប៉ុណ្ណោះ។

**១.២.២ ការចូលរួមសេវាដឹកជញ្ជូនរបស់សាធារណៈ**

ដំបូងឡើយកម្ពុជាប្រើសេវាដឹកជញ្ជូនតាមប្រព័ន្ធផ្លូវដែក ដែលយើងតែងតែស្គាល់ថាជារថភ្លើង ហើយផ្លូវដែកត្រូវបានកសាងឡើងដោយរដ្ឋអំណាចអាណានិគមបារាំងនៅទសវត្សឆ្នាំ១៩៣០ ដែលមានឈ្មោះថា «រាជាយស្ម័យយានកម្ពុជា» ផ្លូវដែកនេះដើរតួរយ៉ាងសំខាន់ក្នុងការដឹកជញ្ជូន

ទំនិញ និង អ្នកដំណើរដើម្បីបម្រើឱ្យសេដ្ឋកិច្ចជាតិនិងសង្គម ផ្លូវដែកនេះមានផ្លូវចំនួនពីរខ្សែ ដោយខ្សែទី ១ មានប្រវែង ៣៨៦ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញទៅបាត់ដំបង និង ខ្សែទី ២ មានប្រវែង ២៦៦ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញទៅកំពង់ផែព្រះសីហនុ។ ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៧ ដោយប្រទេសកម្ពុ-ជាបានធ្លាក់ចូលក្នុងសង្គ្រាមរ៉ាំរ៉ៃហេតុដូច្នេះហើយទើបធ្វើឱ្យផ្លូវដែករងការបំផ្លាញ និង ទ្រុឌទ្រោមពីពួកខ្មែរក្រហម។ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ផ្លូវដែកកម្ពុជាបានទទួលជំនួយតិចតួចពីធានាគារអភិវឌ្ឍន៍អាស៊ី Asian Development Bank (ADB) និងរដ្ឋាភិបាលបារាំង នៅពេលនោះរថភ្លើងអាចរត់បានក្នុងល្បឿនពី ២០ ទៅ ៣០ គីឡូម៉ែត្រក្នុងមួយម៉ោង (20-30km/h)។ ឆ្នាំ២០០៩ រថភ្លើងត្រូវបានផ្អាកជាបណ្ដោះអាសន្នដើម្បីធ្វើការជុសជុល ហើយក្រោយមកត្រូវបានដំណើរការឡើងវិញក្នុងល្បឿន ៥០ គីឡូម៉ែត្រក្នុងមួយម៉ោង (50km/h) ជាចុងក្រោយរដ្ឋាភិបាលកម្ពុជាបានធ្វើកិច្ចព្រមព្រៀងសម្បទានឱ្យទៅក្រុមហ៊ុន រ៉ូយ៉ាល់រៀលវ៉េ (Royal Rail Way) ដែលជាក្រុមហ៊ុនរបស់លោកឧកញ៉ាគិត ម៉េង ដើម្បីធ្វើការអភិវឌ្ឍន៍ខ្សែរថភ្លើងនេះឡើងវិញ ប្រកបដោយគុណភាពខ្ពស់។ ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន ក៏បានធ្វើការស្នើរឱ្យក្រុមហ៊ុន វាយតម្លៃលទ្ធភាពនៃការបង្កើនល្បឿនមានសុវត្ថិភាពដើម្បីកាត់បន្ថយពេលវេលានៃការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ប្រតិបត្តិការនេះត្រូវបានដំណើរការ នៅថ្ងៃសុក្រ សៅរ៍ និង អាទិត្យ ដោយចេញដំណើរពីភ្នំពេញនៅម៉ោង ៧:០០ ព្រឹក ហើយត្រូវឈប់នៅស្ថានីយ៍ពីរកន្លែងគឺនៅក្នុងខេត្ត តាកែវ និង កំពត បន្ទាប់មកក៏ចេញដំណើរទៅខេត្តព្រះសីហនុតែម្តង ក្នុងតម្លៃសំបុត្រ ៦ ដុល្លា (6$) ហើយក្នុងរថភ្លើងមួយអាចផ្ទុកមនុស្សបានចំនួន ២០០ នាក់។ ក្នុងពេលថ្មីៗនេះរដ្ឋាភិបាលបានប្រកាសឱ្យបើកដំណើរការសាកល្បងលើខ្សែរថភ្លើងដែលរត់ចាប់ពីទីក្រុងភ្នំពេញដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋតាមផ្លូវ (ការធ្វើដំណើរតាមរថយន្ត) ហើយការដាក់សាកល្បងនេះរដ្ឋាភិបាលបានប្រកាសឱ្យប្រជាពលរដ្ឋធ្វើដំណើរបានដោយឥតគិតថ្លៃ សម្រាប់ការប្រើប្រាស់ដែលមានរយៈពេល ៣ខែ ដោយគិតចាប់ពីថ្ងៃទី១០ ខែមេសា រហូតដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ[16]។

ក្រៅពីមធ្យោបាយដឹកជញ្ជូនតាមរថភ្លើង រដ្ឋាភិបាលក៏បានបង្កើតឱ្យមានសេវាដឹកជញ្ជូនតាមរថយន្តក្រុងផងដែលសម្រាប់រាជធានីភ្នំពេញ ការដាក់ឱ្យដំណើរការសាកល្បងដំបូងគឺចាប់តាំងពីឆ្នាំ ២០០១ ប៉ុន្តែសេវាដឹកជញ្ជូនក្នុងផ្នែកនេះដំណើរការមិនបានប៉ុន្មានក៏ត្រូវបញ្ចប់ទៅវិញ តែរដ្ឋាភិបាលក៏មិនបានបញ្ឈប់ដំណើរការនៃសេវាដឹកជញ្ជូនមួយនេះទេ លោកបានសម្រាច់ចិត្តចាប់ផ្តើមឱ្យ

[16] តាមប្រសាសន៍របស់ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន (https://khmer.cambodiadaity.com)។

មានសេវាដឹកជញ្ជូននេះសាជាថ្មីម្តងទៀតក្នុងឆ្នាំ២០១៤ សេវាក្នុងផ្នែកដឹកជញ្ជូនមួយនេះក៏នៅតែបន្តដំណើរការក្នុងពេលឥឡូវនេះដែរ ហើយលោកក៏បានប្រកាសថានឹងបង្កើតឱ្យមានចំណត និងខ្សែឱ្យបានច្រើនក្នុងពេលឆាប់ៗនេះដែរ[17]។

## ១.៣ ការណែនាំស្តីពីការអនុវត្តសេវាដឹកជញ្ជូនសាធារណៈក្នុងរាជធានីភ្នំពេញ

សេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈ សម្រាប់សាធារណៈជនដែលពួកគាត់ចូលរួមចំណែកក្នុងការប្រើប្រាស់សេវាដឹកជញ្ជូន ពីព្រោះថាសេវាដឹកជញ្ជូនមួយនេះអាចដំណើរការទៅបានលុះត្រាតែមានការចូលរួមពីប្រជាពលរដ្ឋ ដូច្នេះដើម្បីឱ្យប្រជាពលរដ្ឋប្រើប្រាស់សេវាមួយនេះកាន់តែច្រើនរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង គួរគប្បីជូនដំណឹងដល់សាធារណៈជនអំពីដំណើរការនៃសេវាដឹកជញ្ជូនរបស់ខ្លួនដូចជា ការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ បិទស្លាកជូនដំណឹង និងតាមប្រព័ន្ធអ៊ីនធឺណែត (Internet) ឬតាមបណ្តាញសង្គមផ្សេងៗ។ ស្វពថ្ងៃនេះយើងឃើញថាមានការផ្សព្វផ្សាយនៅលើកញ្ចក់ទូរទស្សន៍នៅតាមប៉ុស្តិ៍ផ្សេងៗជាក់ស្តែងដូចជាប៉ុស្តិ៍ TV3, BTV ដែលចាក់ផ្សាយរៀងរាល់ថ្ងៃពី ច័ន្ទ ដល់ អាទិត្យដោយការចាក់ផ្សាយនេះបន្ទាប់ពីការចាក់ផ្សាយខ្សែភាពយន្ត និង ការផ្សាយព័ត៌មាន។

នៅក្នុងឆ្នាំ ២០១៤ សេវារថយន្តក្រុងក៏បានកើតឡើងម្តងទៀត ដោយបានបង្កើតចំណតចំនួន៣ ខ្សែ គឺ[18] ៖

- ខ្សែទី ១ : ចាប់ផ្តើមនៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ដោយចេញដំណើរពីចំណតគីឡូម៉ែត្រលេខ ៩ តាមផ្លូវជាតិលេខ ៥ រង្វង់មូលស្ពានចាស់ មហាវិថីព្រះមុនីវង្ស ស្ពានព្រះមុនីវង្សឆ្ពោះទៅផ្លូវជាតិលេខ ១ រហូតដល់ចំណតបឹងឈូក រួចត្រឡប់មកវិញ។ ខ្សែនេះបានកំណត់ចំណតរថយន្តក្រុងឈប់ (bus stop) ចំនួន ៦៧ ចំណត។
- ខ្សែទី ២ : ចាប់ផ្តើមនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៤ ដោយចេញដំណើរពីចំណតផ្សាររាត្រី វិថីព្រះស៊ីសុវត្ថិ ស្ពានជ្រោយចង្វា រង្វង់មូលស្ពានចាស់ ផ្លូវលេខ ៧០ ផ្លូវលេខ២៧៣ អង់តែនទួលគោក មហាវិថីគីមអ៊ីលស៊ុង មហាវិថីម៉ៅសេងទុង ភ្លើងស្តុបបូកគោ មហាវិថីព្រះមុនីវង្សឆ្ពោះទៅផ្លូវជាតិលេខ២ រហូតដល់រង្វង់មូលតាខ្មៅរួចត្រឡប់មកវិញ។ ខ្សែទី២ នេះបានកំណត់ចំណតរថយន្តក្រុងឈប់ (Bus Stop) ចំនួន ៤៩ ចំណត។

[17] សេចក្តីជូនដំណឹង សាលារាជធានីភ្នំពេញចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤។

[18] សេចក្តីជូនដំណឹង សាលារាជធានីភ្នំពេញចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤។

- ខ្សែទី ៣ : ចាប់ផ្តើមនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ដោយចេញដំណើរពីចំណតផ្សាររាត្រី ផ្លូវលេខ១០៦ មហាវិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី មហាវិថីកម្ពុជាក្រោម ក្រោមស្ពានអាកាស៧មករា មហាវិថីសហព័ន្ធរុស្ស៊ី ព្រលានយន្តហោះអន្តរជាតិភ្នំពេញ រហូតដល់រង្វង់មូលចោមចៅ រួចត្រលប់មកវិញ។ នៅខ្សែទី ៣ នេះបានកំណត់ចំណតរថយន្តក្រុងឈប់ (Bus Stop) ចំនួន ៤៩ ចំណត។

នៅក្នុងឆ្នាំ២០១៤ មានរថយន្តក្រុងចំនួន៥៧ គ្រឿងដែលរដ្ឋគឺជាអ្នកទិញខ្លួនឯងផ្ទាល់ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដោយដំបូងឡើយគម្រោងនេះគឺជប៉ុនជាអ្នកដាក់ឱ្យសាកល្បងដំណើរការរយៈពេល៣ខែ ហើយរថយន្តទាំងនោះគឺប្រើដោយហ្គាស និងមានចំណតឈប់សរុបចំនួន ១៦៥ ចំណត។

សេវាដឹកអ្នកដំណើរនឹងចាប់ផ្តើមពីម៉ោង ៥:៣០ នាទីព្រឹក ដល់ម៉ោង៨:៣០នាទីយប់ ហើយសេវាដឹកជញ្ជូននៃការធ្វើដំណើរនេះក៏មានការកំណត់ម៉ោងក្នុងការធ្វើដំណើរដូចខាងក្រោម ៖

- ម៉ោង ០៥:៣០-០៦:០០ ត្រូវរង់ចាំប្រហែល ១៥ នាទី
- ម៉ោង ០៦:០០-០៩:០០ ត្រូវរង់ចាំប្រហែល ១០ នាទី
- ម៉ោង ០៩:០០-១៦:៣០ ត្រូវរង់ចាំប្រហែល ១៥ នាទី
- ម៉ោង ១៦:៣០-១៩:៣០ ត្រូវរង់ចាំប្រហែល ១០ នាទី
- ម៉ោង ១៩:៣០-២០:៣០ ត្រូវរង់ចាំប្រហែល ១៥ នាទី

### ១.៣.១ ការកែប្រែ និង ការដាក់បញ្ចូលលើខ្សែរថយន្ត

ដើម្បីឱ្យមានភាពងាយស្រួលជាងមុនសម្រាប់ប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់ខ្សែរថយន្តក្រុងនៅក្នុងរាជធានីភ្នំពេញនេះ សាលារាជធានីភ្នំពេញបានធ្វើការកែសម្រួលលើផ្លូវចំនួន ២ខ្សែ នៃខ្សែរត់ចាស់នៅក្នុងថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៧នេះមាន[19]ដូចតទៅ ៖

- ខ្សែរត់ទី ០២ : ចេញពីចំណតរថយន្តផ្សារអ៊ីអនពីរ តាមផ្លូវឧកញ៉ាម៉ុងឫទ្ធី រង្វង់មូលកាំងកូលស៊ីតធី រង្វង់មូលអង់តែនទួលគោក ផ្លូវលេខ៧០ រង្វង់មូលក្បួចកាណុង ផ្លូវលេខ ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ស្ពានអាកាសក្បាលថ្នល់ ផ្លូវជាតិលេខ០២ ដល់ក្រុងតាខ្មៅខេត្តកណ្តាល។
- ខ្សែរត់ទី ០៣ : ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ០៥ រង្វង់មូលក្បួចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្ត ផ្លូវលេខ១៣០ ផ្សារធំថ្មី មហាវិថីកម្ពុជាក្រោម ស្ពានអាកាស ៧

[19] សេចក្តីជូនដំណឹងលេខ ០៥០/១៧ សជណ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧។

មករា មហាវិថីសហព័ន្ធរ៉ូស៊ី រង្វង់មូលចោមចៅ ផ្លូវជាតិលេខ០៣ ដល់ ចំណតបុរីសន្តិភាពពីរ ។

ជាងនេះទៅទៀតសាលារាជធានីក៏បានដាក់ពង្រាយខ្សែរត់បន្ថែមទៀតនៅក្នុងរាជធានីភ្នំពេញ ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ ហើយខ្សែដែលដាក់បន្ថែមនោះមានចំនួន ០៥ ខ្សែគឺ[20] ៖

+ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៧

- ខ្សែរត់ទី ០៤A : ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ ០៥ រង្វង់មូលក្បួចកាណុង ផ្លូវលេខ ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិច វិថីព្រះមុនីវ៉េត កាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ស្តុបវេងស្រេង ស្តុបអាងទឹកកាណាឌីយ៉ា ផ្សារទួលពង្រដល់ចំណតបុរីសន្តិភាពពីរ។
- ខ្សែរត់ទី ០៤B : ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ ០៥ រង្វង់មូលក្បួចកាណុង ផ្លូវលេខ ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិច វិថីព្រះមុនីវ៉េត កាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ស្តុបវេងស្រេង រង្វង់មូលចោមចៅ ផ្លូវជាតិលេខ០៤ ដល់តំបន់សេដ្ឋកិច្ចពិសេស។
- ខ្សែរត់ទី ០៥ : ចេញពីចំណតផ្សារអ៊ីអនពីរតាម ផ្លូវ១០០៣ បត់ឆ្វេងតាមផ្លូវលេខ ១៩៦៦ ឆ្ពោះទៅផ្លូវលេខ៥៩៨ ផ្លូវលេខ ៣៣៧ បត់ស្តាំតាមផ្លូវលេខ ៥៦៦ សាលាបឋមសិក្សាពៅអ៊ុំទួលគោក វិថីគីមអ៊ីលស៊ុង កាត់ក្រោមស្ពានអាកាស ៥មករា មហាវិថីម៉ៅសេងតុង ស្តុបបូកគោ ស្តុបជលផល វិថីសុជារស់ដល់ចំណតផ្សារអ៊ីអនមួយ។

+ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៧

- ខ្សែរត់ទី ០៦ : ចេញពីចំណតផ្សារបុរីរុងរឿង ផ្លូវជាតិលេខ៦ ស្ពានជ្រោយចង្វារ រង្វង់មូលក្បួចកាណុង ផ្លូវលេខ៧០ រង្វង់មូលអង់តែនទួលគោក រង្វង់មូលកាំកូស៊ីធី ផ្លូវឧកញ៉ាម៉ុងឫទ្ធី ផ្លូវសម្តេចជា ស៊ីម បត់ឆ្វេងតាមផ្លូវឧកញ៉ា ទ្រី ហេង ដល់មហាវិថីសហព័ន្ធរុស្ស៊ី បត់ឆ្វេងឆ្ពោះទៅដល់ចំណតផ្សារសេនជូវីថ្លាហ្សា។

[20] សេចក្តីជូនដំណឹងលេខ ០៥០/១៧ សជណ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧។

- ខ្សែរត់ទី ០៧A : ចេញពីចំណតគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ផ្លូវលេខ៥៩៨ ស្ពានអាកាសព្រែកពា ផ្លូវលេខ២៧១ បត់តាមស្ពានអាកាសស្ទឹងមានជ័យ វិថីព្រះមុនីរ៉េត វិថីព្រះសីហនុ វិថីព្រះសុធារស ដល់ចំណតផ្សារអ៊ីអនមួយ។
- ខ្សែរត់ទី ០៧B : ចេញពីចំណតគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ផ្លូវលេខ៥៩៨ ស្ពានអាកាសព្រែកពា ផ្លូវលេខ២៧១ កាត់ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវលេខ២៧១ ស្តុបក្បាលថ្នល់ ឆ្លងកាត់ស្ពានព្រះមុនីវង្ស ដល់ចំណតច្បារអំពៅ។
- ខ្សែរត់ទី ០៨ : ចេញពីចំណតគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ កាត់ស្ពានព្រែកព្នៅ ផ្លូវឧកញ៉ាលី យ៉ុងផាត់ ផ្លូវជាតិលេខ០៦អា (06A) ដល់ចំណតផ្សារបុរីរុងរឿង។

### ១.៣.២ ការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ

ដើម្បីឱ្យងាយស្រួលជាងនេះទៅទៀត សាលារាជធានីភ្នំពេញបានខិតខំស្វែងរកមធ្យោបាយផ្សេងៗដើម្បីឱ្យប្រជាពលរដ្ឋយល់កាន់តែច្រើនពីសេវារថយន្តក្រុងសាធារណៈនេះ មិនត្រឹមតែប៉ុណ្ណោះសាលារាជធានីភ្នំពេញក៏បានផ្សព្វផ្សាយពីរបៀបនៃការប្រើប្រាស់សេវា និង របៀបផ្សេងៗទៀតដើម្បីទទួលបានសេវាដឹកជញ្ជូនរថយន្តក្រុងមួយនេះ ហើយរបៀបទាំងនេះមានជា ៖

+របៀបជិះរថយន្តក្រុង

ពេលជិះរថយន្តក្រុងត្រូវឡើងតាមទ្វាមុខ ពេលចូលទៅដល់ត្រូវដាក់លុយ ១,៥០០រៀលក្នុងប្រអប់លុយ ឬ ប្រើប្រាស់កាតរថយន្តក្រុង ហើយបើសិនជាយើងចង់ឈប់ត្រូវចុកកន្លឹងពណ៌ក្រហមដែលមានឈ្មោះថា «ឈប់ (Stop)» រួចហើយដើរចុះតាមទ្វាខាងក្រោយ[21]។

+ការរង់ចាំ

អ្នកដែលមកទទួលសេវាកម្មរថយន្តក្រុងសាធារណៈទាំងអស់ត្រូវរង់ចាំនៅកន្លែងចំណតរថយន្តដែលមានស្លាកសញ្ញាសម្គាល់លេខរថយន្តដែលរត់លើផ្លូវ នៅកន្លែងរង់ចាំក៏មានជាកន្លែងអង្គុយដើម្បីងាយស្រួលក្នុងការរង់ចាំ ហើយការរង់ចាំនេះគឺប្រហែល ១៥ នាទី។

+ការចំណាយថ្លៃសេវា

រាល់ការជិះរថយន្តក្រុងម្តងគឺត្រូវចំណាយ ១,៥០០រៀល សម្រាប់ជនទូទៅ ប៉ុន្តែសម្រាប់មនុស្សចាស់អាយុ ៦០ឆ្នាំឡើង ក្មេងដែលមានកម្ពស់ក្រោម ១ម៉ែត្រ ជនពិការ ព្រះសង្ឃ សិស្ស និស្សិត (មានកាតសម្គាល់ខ្លួន) មិនតម្រូវឱ្យបង់ប្រាក់ឡើយពោលគឺអាចទទួលយកសេវារថយន្តក្រុងនេះបានដោយឥតគិតថ្លៃ មិនត្រឹមតែប៉ុណ្ណោះកម្មករ កម្មការនីរោងចក្រក៏ត្រូវបានប្រើប្រាស់សេវារថ

[21] Video ពីហ្វេសប៊ុករដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង។

យន្តក្រុងឥតគិតថ្លៃក្នុងរយៈពេលពីរឆ្នាំគឺដោយគិតពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩[22] ដោយគ្រាន់តែបង្ហាញកាត ឬបណ្ណ័សម្គាល់ខ្លួនទៅអ្នកត្រួតពិនិត្យជាការស្រេច។

+វិធីប្រើប្រាស់កាតវីង[23] (Wing)

កាតរថយន្តក្រុងសាធារណៈបង្កើតឡើងសម្រាប់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបានសេវារថយន្តក្រុងសាធារណៈ កាតរថយន្តក្រុងសាធារណៈនេះសហការដោយវីង (Wing) ដោយមានលក្ខណសម្គាល់ចំនួនពីរពណ៌គឺពណ៌បៃតង និង ពណ៌ខៀវ ដែលសាកសមបំផុតសម្រាប់តម្រូវការនិងសកម្មភាពរបស់អ្នកប្រើប្រាស់ទាំងអស់។

- កាតពណ៌បៃតង គឺជាកាតស្តង់ដារសម្រាប់អតិថិជនទូទៅដែលមិនចូលចិត្តក្នុងប្រភេទកាតខៀវនោះទេ ហើយកាតពណ៌បៃតងនេះវាក៏មានលក្ខណប្រសើរជាងមុនសម្រាប់ដែលអ្នកប្រើប្រាស់ទាំងអស់ដូចជា បញ្ចូលទឹកប្រាក់តាមទូរស័ព្ទដៃ ការទូទាត់វិក្កយបត្រ ការទូទាត់តាម Internet (អ៊ីនធឺណែត)។

1. ការបញ្ចូរទឹកប្រាក់តាមទូរស័ព្ទដៃ
   - អ្នកអាចបញ្ចូលទឹកលើប្រាក់ទូរស័ព្ទ ទៅកាន់លេខទូរស័ព្ទរបស់អ្នក ឬមិត្តភក្តិរបស់អ្នកត្រឹមតែ ២ដំណាក់កាលប៉ុណ្ណោះ
   - ទិញកាតទូរស័ព្ទដែលអាចផ្ញើរទៅកាន់នរណាក៏បាន ឬទុកសម្រាប់ប្រើខ្លួនឯងពេលក្រោយ។ ហើយអាចប្រើបានគ្រប់ប្រព័ន្ធទូរស័ព្ទនៅ ក្នុងប្រទេសកម្ពុជាដែលមានដូចជា Cellcard ,Smart, Metfone , QB , Seatel , Cootel។
2. ការទូទាត់វិក្កយបត្រ
   - បង់វិក្កយបត្រទឹក ភ្លើងតាមប្រព័ន្ធInternet ឬវិក្កយបត្រតាមទូរទស្សន៍ជាមួយគណនីវីងរបស់អ្នក
   - អ្នកអាចផ្ញើរប្រាក់ទៅកាន់ធនាគារដើម្បីបង់ប្រាក់សេវាកម្ចី
   - បរិច្ចាកប្រាក់ទៅកាន់មូលនិធិសប្បុសរធមិដែលអ្នកពេញចិត្ត
3. ការទូទាត់ Internet (អ៊ីនធឺណែត)
   - ផ្ញើរប្រាក់បានភ្លាមៗទៅកាន់គណនីវីងមួយផ្សេងទៀត (wing to wing)

[22] សេចក្តីជូនដំណឹងលេខ ០៥០/១៧ សជណ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧។

[23] www.wingmoney.com

- ផ្ញើរប្រាក់ទៅកាន់ទូរស័ព្ទដៃរបស់អ្នកទទួលបានភ្លាមៗទូទាំងប្រទេស (wing weiluy)
- ទទួលប្រាក់ងាយស្រួលពីអ្នកណាក៏បាន ទាំងក្នុង និងក្រៅប្រទេស (តាមរយៈដៃគូរផ្ញើរប្រាក់ក្រៅប្រទេសរបស់វីង)។

- កាតពណ៌ខៀវ កាតនេះត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ព្រះសង្ឃ សិស្ស និស្សិត ជនពិការ ក្មេងដែលមានកម្ពស់ក្រោម ១ម៉ែត្រ និង មនុស្សចាស់ មិនត្រឹមតែប៉ុណ្ណោះកាតនេះអនុញ្ញាតឱ្យអ្នកជិះរថយន្តក្រុងបានចំនួន ១៨០ ដង។

ដើម្បីទទួលបានកាតរថយន្តក្រុងសាធារណៈអ្នកគ្រាន់តែអនុវត្តតាម ៣ ជំហានងាយៗមាន៖

1. ទៅកាន់ចំណតរថយន្តក្រុងសាធារណៈ
2. ដើម្បីដាក់ឱ្យកាតខៀវដំណើរការ សូមបង្ហាញអត្តសញ្ញាប័ណ្ណ សិស្ស/ព្រះសង្ឃ និងលេខទូរស័ព្ទរបស់អ្នក
3. បង់ថ្លៃកាតនឹងទទួលបានកាតនោះភ្លាម

បន្ទាប់ពីទទួលបានកាតរថយន្តក្រុងសាធារណៈ ឬចង់ដាក់កាតវីងរបស់អ្នកឱ្យដំណើរការ អ្នកអាចប្រើភ្លាមៗ សម្រាប់ការធ្វើដំណើរតាមរថយន្តក្រុងរបស់អ្នក។ ដោយគ្រាន់តែដាក់កាតរថយន្តក្រុងសាធារណៈ ឬកាតវីងរបស់អ្នកនៅលើប្រអប់ឆូតកាតតាមរថយន្តក្រុងរាល់ពេលដែលអ្នកឡើងជិះ និងចាកចេញពីឡានក្រុង ហើយការកាត់ទឹកប្រាក់នឹងត្រូវបានអនុវត្តដោយស្វ័យប្រវត្តិសម្រាប់ការធ្វើដំណើររបស់លោកអ្នក។ ត្រូវប្រាកដថាលោកអ្នកបានដាក់ប្រាក់ក្នុងកាតរថយន្តក្រុងសាធារណៈរបស់អ្នកនៅមុនពេលទឹកប្រាក់របស់អ្នកផុតកំណត់ ឬពន្យារសុពលភាពកាតរបស់អ្នក។ កាតរថយន្តក្រុងនេះដែលវាក៏មានលក្ខណចំបងនិងអត្ថប្រយោជន៍មួយចំនួនផងដែរដូចជា ៖

1. ទូទាត់ដ៏ងាយស្រួល ដោយមិនចាំបាច់បារម្មណ៍លើការទូទាត់តម្លៃ មិនត្រឹមត្រូវ ឬការអាប់លុយទៀតឡើយ ពោលគឺរីករាយជាមួយភាពងាយស្រួលនៃការទូទាត់ដោយមិនចាំបាច់ប្រើសាច់ប្រាក់សុទ្ធ
2. ការតាមដាន និងការគ្រប់គ្រង អ្នកអាចទទួលបានបច្ចុប្បន្នភាពអំពីការធ្វើដំណើរការចំណាយ និងទឹកប្រាក់របស់អ្នកជាមួយមុខងារ USSD និងកម្មវិធី Smart phone wing
3. វិធីសាស្ត្រដាក់ប្រាក់ ឬ បញ្ចូលកាត វីងវាបានផ្តល់ឱ្យអ្នកនូវវិធី ៤យ៉ាង ដែលសាមញ្ញដើម្បីដាក់ប្រាក់ ឬបញ្ចូលកាតរថយន្តក្រុងសាធារណៈរបស់អ្នកមានដូចខាងក្រោម៖

a) កាតពណ៌ខៀវ និងពណ៌បៃតងអាចបញ្ចូលទឹកប្រាក់បាននៅតាមស្ថាននីយ៍រថយន្តក្រុងសាធារណៈ
b) ដាក់ប្រាក់ទៅក្នុងកាតពណ៌បៃតងជាមួយភ្នាក់ងារវីងណាមួយក៏បានដែលមានភ្នាក់ងារវីងទាំង ៥,០០០ កន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
c) កាតពណ៌បៃតងមានលក្ខណពិសេសអាចធ្វើការផ្ញើរទឹកប្រាក់ពីគណនីមួយទៅគណនីមួយបានជាមួយវីង
d) ទទួលយកបទពិសោធន៍នៃការផ្ញើរប្រាក់ដ៏ងាយស្រួល និងឆាប់រហ័សពីការផ្ទេរទឹកប្រាក់ពីធនាគារFTB ទៅវីង ហើយការផ្ទេរនេះមានសម្រាប់តែកាតពណ៌បៃតងប៉ុណ្ណោះ។

+ ការស្វែងរកចំណតតាមប្រព័ន្ធអ៊ីនធឺណែត[24] ( Stop near me )

កម្មវិធីចំណតរថយន្តក្រុងសាធារណៈដែលមានឈ្មោះថា Stop near me បានបង្កើតឡើងដោយសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រ Computer កញ្ញា ប្លុង ម៉ាលីពណ៌ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ កម្មវិធីនេះមានមុខងារ Share location ដែលជាមុខងារមួយជួយឱ្យអ្នកដឹងពីចលនារបស់ឡានក្រុងសាធារណៈចល័តទៅទិសខាងណា ខ្សែទីប៉ុន្មាន ហើយថែមទាំងអាចចែករំលែកព័ត៌មានទាំងនោះទៅកាន់អ្នកបានទៀតផង។ កម្មវិធីនេះជួយអ្នកសន្សំសំចៃពេលវេលា ដើម្បីធ្វើដំណើរទៅកាន់ទីតាំងរបស់អ្នក។ តាមរយៈកម្មវិធីនេះអ្នកក៏អាចមើលទីតាំងរបស់ឡានក្រុងនៅក្នុងពេលវេលាជាក់លាក់ពិតប្រាកដមួយ។ ដោយសារតែមុខងារនេះអ្នកអាចប៉ាន់ស្មានបាននៅពេលដែលរថយន្តរបស់អ្នកនឹងមកដល់កាន់តែងាយស្រួល លើសពីនេះទៅទៀត , កម្មវិធីនេះអនុញ្ញាតឱ្យអ្នកកំណត់ការដាស់តឿនសម្រាប់ឈប់ឡានក្រុងណាមួយ។ អ្នកនឹងត្រូវបានជូនដំណឹង ២០០ម៉ែត្រ មុនពេលមកដល់ ដោយគ្រាន់តែប្រាកដថាទូរស័ព្ទដៃរបស់អ្នកមាន GPS។

គម្រោងធ្វើដំណើររបស់អ្នកតាមរយៈកម្មវិធីនេះដោយប្រើផែនទីទិដ្ឋភាពទូទៅនៃឡានក្រុង ហើយវា មានពីរភាសាគឺ ភាសាខ្មែរ និង ភាសាអង់គ្លេស។ អ្នកអាចប្រើចំណតដែលជាចំណូលចិត្តផ្ទាល់ខ្លួនរបស់អ្នក។ ការឈប់នៅជិតខ្ញុំគឺជាកម្មវិធីទូរស័ព្ទចល័តនៅកម្មវិធីបណ្ដាញសង្គមមួយដែលលោកអ្នកអាចរកបានតាមរយៈ App Store និង Google Play ដោយឥតគិតថ្លៃ។

[24] News.sabay.com.kh/article

បន្ទាប់ពីអ្នកបានទាញយកវាពីហាង (App) របស់អ្នករួចនោះអ្នកអាចចាប់ផ្តើមប្រើវាបានតែម្តង។ ដោយគ្រាន់តែចុចលើកម្មវិធីអ្នកអាចឃើញរថយន្តក្រុងដែលកំពុងដំណើរការយ៉ាងច្បាស់ៗ ហើយនៅផ្នែកខាងក្រោមនៃកម្មវិធីមានមុខងារ ៣ ផ្សេងទៀតគឺ ៖

1. ដំបូងជ្រើសភាសាដែលអ្នកចង់ប្រើ ចុចលើរូបតំណាងអនុគមន៍ដើម្បីឱ្យអ្នកជ្រើសរើសភាសាខ្មែរ ឬភាសាអង់គ្លេស
2. រូបតំណាងទីពីរគឺជាមុខងារចែករំលែកដែលអ្នកអាចប្រើដើម្បីចែករំលែកទីតាំងបច្ចុប្បន្នរបស់អ្នកជាមួយអ្នកប្រើប្រាស់កម្មវិធីផ្សេងទៀត រូបតំណាងចុងក្រោយគឺជាទីតាំងដែលបានផ្តល់
3. ជ្រើសមុខងារនេះដើម្បីកំណត់ទីតាំងបច្ចុប្បន្នរបស់អ្នក អ្នកនិងទទួលបានព័ត៌មានថាតើមានរថយន្តក្រុងមួយនៅក្បែរនោះដែរឬទេ?

+ របៀបក្នុងការផ្តល់ព័ត៌មានទីតាំង គឺមាន ៤ ទម្រង់ខុសៗគ្នាដូចជា៖

1. ទោះជាអ្នកនៅផ្ទះក៏ដោយក៏អ្នកអាចទទួលបានការជូនដំណឹងពីការមកដល់នៃរថយន្តក្រុង ដោយគ្រាន់តែអ្នកកំណត់ទីតាំងឈប់ឡានរបស់អ្នកហើយកម្មវិធីនេះ និងប្រាប់អ្នកនៅពេលដែលរថយន្តក្រុងមកដល់ វាមិនមានការរង់ចាំទេហើយអ្នកអាចសន្សំសំចៃពេលធ្វើការ ឬ ភារកិច្ចផ្សេងៗដោយប្រើមុខងារនេះ
2. ហើយនៅពេលអ្នកបានកំណត់ការឈប់រួច កម្មវិធីនេះនិងការជូនដំណឹងអ្នកនឹងទទួលបានព័ត៌មានទាំងអស់ដែលទាក់ទងទៅនឹងចំណតឡានក្រុងដែលនៅជិត
3. សម្រាប់ការបន្ថែមអំពីចំណតរថយន្ត គឺនៅក្នុងកម្មវិធីនេះមានព័ត៌មាននៃការឈប់ឡានក្រុងនៅភ្នំពេញដែលត្រូវបានធ្វើបច្ចុប្បន្នភាព
4. ការធ្វើដំណើររបស់អ្នកទាំងអស់ត្រូវបានកត់ត្រានៅពេលដែលអ្នកប្រើកម្មវិធីនេះដើម្បីធ្វើដំណើរ។

កម្មវិធីចំណតក្បែរខ្ញុំ ឬហៅថា Stop Near Me ត្រូវបានបង្កើតឡើងតាំងពីខែមីនា ឆ្នាំមុនមកម្លេះ (២០១៧) មានព័ត៌មានគ្រប់ខ្សែ និង ចំណតរថយន្តក្រុងទាំងអស់ ពោលគឺមាន ៣ ខ្សែ និង ១៨០ ចំណតដែលខ្សែទី១ រត់ពីគីឡូម៉ែត្រលេខ ៩ ដល់ស្ពានច្បារអំពៅ ខ្សែទី២ រត់ពីផ្សាររាត្រី ដល់ក្រុងតាខ្មៅ និងខ្សែទី៣ រត់ពី ផ្សាររាត្រី ដល់រង្វង់មូលចោមចៅតែម្តង ដែលអ្នកទាំងអស់គ្នាអាចដោនឡូត (Download) ប្រើបានដោយមិនគិតថ្លៃ ប៉ុន្តែឥឡូវកម្មវិធីមួយនេះបានបង្កើតឱ្យមានគ្រប់ខ្សែដែលរថយន្តក្រុងយើងបានឆ្លងកាត់ សម្រាប់ងាយស្រួលឱ្យអ្នកដំណើរដឹងពីពេលវេលាច្បាស់លាស់ដែលរថយន្តក្រុងមកដល់។

គោលបំណងដែលបង្កើតកម្មវិធីនេះឡើង គឺដើម្បីជួយដោះស្រាយបញ្ហាដែលពិបាកស្វែងរកចំណតឡានក្រុង និងសម្រួលដល់អ្នកដែលចូលចិត្តធ្វើដំណើរតាមរថយន្តក្រុងអាចស្វែងរកចំណតបានកាន់តែងាយស្រួលដូចនៅនឹងប្រទេសដែលគេជឿនលឿនដូចជានៅខាងប៉ែកអឺរ៉ុបជាដើម។ ស្របពេលដែលសាលាក្រុងភ្នំពេញ កំពុងរៀបចំគម្រោងបង្កើតឱ្យមានកម្មវិធី (APP) ដែលអាចឱ្យប្រជាពលរដ្ឋមើលប្រព័ន្ធឡានក្រុងតាមរយៈទូរស័ព្ទដៃចល័ត។ ឆ្លើយតបនឹងបញ្ហានេះដែរ កញ្ញាបានលើកឡើងថានាងក៏ចង់សហការជាមួយសាលារាជធានីភ្នំពេញដើម្បីបន្ថែមមុខងារ GPS និងមុខងារផ្សេងទៀតលើរថយន្តក្រុងទាំងនោះដែរ ដើម្បីឱ្យកាន់តែទំនើបជាងមុន។

លក្ខណពិសេសរបស់កម្មវិធីចំណតរថយន្តក្រុង (Stop Near Me) មាន

- ជួយផ្តល់ជាសម្លេងញ័រក្រើនរំលឹកនៅពេលដែលអ្នកធ្វើដំណើរជិតដល់ចំណតដែលត្រូវចុះ
- មានផែនទីងាយស្រួលមើល ទីតាំងរបស់ចំណតឡានក្រុងគ្រប់ខ្សែទាំងអស់ដែលមានក្នុងទីក្រុង
- រាល់ពេលបើកកម្មវិធី វានឹងលោតប្រាប់អ្នកពីចំណតដែលនៅជិតបំផុត
- បង្ហាញចំណតឡានក្រុងទាំងអស់ដែលនៅក្បែរទីតាំងរបស់អ្នកទាំងអស់គ្នា
- មានបង្ហាញទិសដៅសម្រាប់ដើរទៅរកគោលដៅចំណតឡានក្រុងណាមួយ
- មានពីរភាសាសម្រាប់ជ្រើសរើសគឺ ភាសាខ្មែរ និង ភាសាអង់គ្លេស។

# ជំពូកទី ២

# ដំណើរការនៃសេវាដឹកជញ្ជូនសាធារណៈ

## ជំពូកទី ២ ដំណើរការនៃសេវាដឹកជញ្ជូនសាធារណៈនៅរាជធានីភ្នំពេញ

សេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈនេះ អាចដំណើរការទៅបានដោយមានការគ្រប់គ្រង និងចាត់ចែងពីរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងដែល យើងអាចហៅជាភាសាអង់គ្លេសថា «City Bus» ហើយរដ្ឋាករនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ ពោលសាលារាជធានីភ្នំពេញគឺដើរតួរជាអាណាព្យាបាល។ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងត្រូវបង្កើតឡើងដោយរដ្ឋបាលរាជធានីភ្នំពេញដោយយោងទៅតាមលិខិតបទដ្ឋានមួយចំនួនដូចខាងក្រោមៈ

- អនុក្រិតលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាល ហិរញ្ញវត្ថុ និង ការប្រព្រឹត្តិទៅនៃរដ្ឋាករខេត្ត
- លិខិតលេខ ៧៤៤ សជណ.ផក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១៦៧៣ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៣៥៩១ សហវ.អទច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដីការលេខ ០៤ ដក.ផរិ.ប្រករ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ របស់រដ្ឋបាលរាជធានីភ្នំពេញ
- លក្ខន្តិកៈ និង សៀវភៅបន្ទុករបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦

ការបង្កើតរដ្ឋាករស្វយ័តដឹកជញ្ជូនរថយន្តក្រុងសាធារណៈនេះឡើងក្នុងគោលបំណង បង្ករភាពងាយស្រួលក្នុងការធ្វើដំណើរ ធានាសុវត្ថិភាព ផាសុខភាព សន្សំសំចៃពេលវេលា ប្រាក់កាស កាត់បន្ថយការកកស្ទះចរាចរណ៍ គ្រោះថ្នាក់ចរាចរណ៍ ការប្រើប្រាស់ថាមពលខ្ជះខ្ជាយ ឧស្ម័នបំពុលបរិស្ថាន និងផលប៉ះពាល់សុខុមាលភាពប្រជាពលរដ្ឋក្នុងរាជធានី[25] ដោយត្រូវបានបង្កើតឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០១៤ ហើយបានចាប់ផ្តើមដំណើរការដំបូងមានចំនួន ៣ ខ្សែ។ ដើម្បីបង្ករភាពងាយស្រួលក្នុងការស្វែងរកព័ត៌មានថ្មីៗពីរដ្ឋាករមួយនេះ រដ្ឋបាលរាជធានីភ្នំពេញបានប្រកាសឱ្យប្រើប្រាស់គេហទំព័រជាផ្លូវការមួយដែលមានឈ្មោះថា «www.phnompenhcitybus.gov.kh»[26]។ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងមានបេសកម្មធ្វើការផ្លាស់ប្តូរឥរិយាបទរបស់ប្រជាពលរដ្ឋ

[25] ដីកាលេខ ០៤ ដក.ផរិ.ក្របរ ស្តីពីការបង្កើតរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងនៅរាជធានីភ្នំពេញ។

[26] សេចក្តីជូនដំណឹងលេខ ០១០/១៨ សជណ ស្តីពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការគេហទំព័ររបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង រាជធានីភ្នំពេញថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០១៨។

ពីការប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនមកប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ ដើម្បីចូលរួមក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍ គ្រោះថ្នាក់ចរាចរណ៍ និងការបំពុលបរិស្ថានក្នុងរាជធានីភ្នំពេញ[27]។ អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីសេវាដឹកជញ្ជូនសាធារណៈ និងចូលរួមសហការ ដើម្បីធ្វើឱ្យសេវានេះដំណើរការទៅដោយរលូន និងទទួលបានជោគជ័យថែមទាំងផ្តល់សេវាដឹកជញ្ជូនសាធារណៈជូនប្រជាពលរដ្ឋឱ្យបានល្អ និងទាន់ពេលវេលាសំដៅធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋមានការពេញចិត្ត[28]។

## ២.១ តួនាទី និងភារកិច្ចរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង

គណៈកម្មាធិការរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៅរាជធានីភ្នំពេញបានបង្កើត និងតែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ដោយពួកគាត់មានតួនាទីដូចតទៅ៖

- កំណត់គម្រោងអភិវឌ្ឍន៍តាមសំណើររបស់ អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) ដោយអនុលោមតាមទិសដៅកំណត់ របស់សាលារាជធានីភ្នំពេញ
- កំណត់គម្រោងថវិកាប្រចាំឆ្នាំ និងកម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបម្រុង សម្រាប់សម្រេចកម្មវិធីវិនិយោគ
- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ
- កំណត់នូវរចនាសម្ព័ន្ធចាត់តាំង ចំនួនក្របខ័ណ្ឌ ការបែងចែកមុខងារទូទៅ និងប្រាក់បៀវត្សរបស់និយោជិតតាមសំណើររបស់អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)
- អនុញ្ញាតឱ្យទិញអចលនវត្ថុគ្រប់ប្រភេទ ដោយគោរពតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈ
- សម្រេចយល់ព្រមលើកិច្ចសន្យា និងអនុស្សារណៈផ្សេងៗដោយមានការយល់ព្រមពីសាលារាជធានីភ្នំពេញ
- ធ្វើការត្រួតពិនិត្យក្នុងចន្លោះពេលទៀងទាត់មួយលើទិសដៅដែលបានកំណត់ និងលើកឡើងនូវបណ្តាវិធានការកែសម្រួល
- លើកសំណើរសុំកែប្រែគម្រោង ឬវិធានការដែលលើកដោយរដ្ឋាករ

រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) មានភារកិច្ចដូចជា៖

[27] www.phnompenhcitybus.gov.kh

[28] www.phnompenhcitybus.gov.kh

- ធ្វើអាជីវកម្មសេវាដឹកជញ្ជូនសាធារណៈដោយរថយន្តក្រុង (City Bus ) និងមធ្យោបាយសាធារណៈផ្សេងៗទៀតនៅរាជធានីភ្នំពេញ
- គ្រប់គ្រងយានយន្ត បណ្តាញខ្សែរត់ ចំណតរង់ចាំ ថ្លៃសំបុត្រជិះរថយន្ត ម៉ោងប្រតិបត្តិការដឹកជញ្ជូន និងចំណតរថយន្តដឹកជញ្ជូនសាធារណៈ (City Bus) ។ល។
- គ្រប់គ្រងកិច្ចប្រតិបត្តិការដឹកជញ្ជូនសាធារណៈ សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពអ្នកដំណើរ
- រៀបចំបទប្បញ្ញត្តិផ្សេងៗ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៅរាជធានីភ្នំពេញ
- ជួសជុល ថែទាំយានយន្ត អនាម័យ បរិស្ថាន យានដ្ឋាន និងការងារថែទាំសំណង់អគារជាដើម។ល។
- ប្រមូលប្រាក់កម្រៃបម្រើសេវាដឹកជញ្ជូន និងការងារផ្សេងៗទៀតពាក់ព័ន្ធទៅនឹងការងារដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)។

### ២.១.១ ភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងការិយាល័យ

ដើម្បីធានាដល់ការដឹកនាំមួយមានប្រសិទ្ធភាព និងការទទួលខុសត្រូវ តាមភារកិច្ចរៀងៗខ្លួន អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង បានដាក់ចេញនូវកំណត់បែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងការិយាល័យនីមួយៗ ដូចខាងក្រោម៖

- អភិបាលរដ្ឋាករ

  អភិបាលរដ្ឋាករ គឺជាថ្នាក់ដឹកនាំរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងត្រូវដឹកនាំ និងគ្រប់គ្រង និងមានភារកិច្ចដូចខាងក្រោម[29]៖

  - រៀបចំការប្រជុំគណៈកម្មាធិការអាជីវកម្ម និងទទួលការងារជាលេខាធិការ រាល់ការប្រជុំរបស់គណៈកម្មាធិការអាជីវកម្ម
  - ទទួលបន្ទុកអនុវត្តសេចក្តីសម្រេច និងគោលការណ៍របស់គណៈកម្មាធិការអាជីវកម្ម និងសាលារាជធានីភ្នំពេញ
  - ទទួលខុសត្រូវលើចំណូល-ចំណាយទាំងអស់របស់រដ្ឋាករ និងការចុះហត្ថលេខាដកថវិកាពីធនាគារ សម្រាប់ចាត់ចែង និងប្រើប្រាស់ក្នុងរដ្ឋាករ

[29] អនុក្រឹតលេខ ៣០ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុនិងការប្រព្រឹត្តិទៅនៃរដ្ឋាករខេត្ត។

- រៀបចំគម្រោងការងារ គម្រោងថវិកាប្រចាំឆ្នាំ អំពីសកម្មភាព និងតុល្យការហិរញ្ញវត្ថុការងារ ដើម្បីដាក់ជូនគណៈកម្មាធិការអាជីវកម្មពិនិត្យ និងអនុម័ត
- ទទួលបន្ទុកដឹកនាំបុគ្គលិក រដ្ឋបាល បច្ចេកទេស ហិរញ្ញវត្ថុ និងគ្រប់គ្រងអាជីវកម្ម
- ទទួលខុសត្រូវលើទ្រព្យសម្បត្តិរបស់រដ្ឋាករ ចលនទ្រព្យ និងអចនទ្រព្យ
- សំណើរជ្រើសរើស តែងតាំង ដកហូតអំណាច ឬ បញ្ឈប់ការងារបុគ្គលិកគ្រប់រូបដែលជានិយោជិត «**រ.ជ.ស**» ដោយផ្អែកលើបទបញ្ជាផ្ទៃក្នុង និងច្បាប់ជាធរមាន ព្រមទាំងការសម្រេចរបស់គណៈកម្មាធិការអាជីវកម្ម និងសាលារាជធានីភ្នំពេញ
- ផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅឱ្យអភិបាលរង ឬមន្ត្រីនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយគណៈកម្មាធិការអាជីវកម្ម
- រៀបចំ និងចុះហត្ថលេខាលើកិច្ចសន្យា ឬ អនុស្សារណៈផ្សេងៗ ស្របតាមការសម្រេចរបស់គណៈកម្មាធិការអាជីវកម្ម ក្រោយពីមានការផ្ទេរសិទ្ធិពីអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- អភិបាលអាចលាលែងពីតំណែងរបស់ខ្លួនបាន តែត្រូវជូនដំណឹងយ៉ាងតិច ៣ ខែមុន ដោយមានការយល់ព្រមពីគណៈកម្មាធិការអាជីវកម្ម និងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- ដឹកនាំអង្គប្រជុំ និងធ្វើរបាយការណ៍ស្តីពី ស្ថានភាពចំណូល-ចំណាយថវិកា និងសកម្មភាពការងាររបស់រដ្ឋាករប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ ជូនគណៈកម្មការអាជីវកម្មបានជ្រាប និងសុំមតិដឹកនាំបន្ត

• អភិបាលរងរដ្ឋាករ

អភិបាលរងរដ្ឋាករ គឺជាជំនួយការរបស់អភិបាលរដ្ឋាករ មានភារកិច្ចជួយការងារអភិបាលរដ្ឋាករក្នុងការពិនិត្យ និងផ្តល់យោបល់ចំពោះឯកសារនានា មុនដាក់ជូនអភិបាលរដ្ឋាករពិនិត្យ និងសម្រេច[30]។

• ការិយាល័យរដ្ឋបាល

[30] លេខ ១០៧ ក.ប.ភ រដស កំណត់បែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំនិងការិយាល័យនីមួយៗ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង។

ការិយាល័យរដ្ឋបាល មានពីរផ្នែក គឺផ្នែករដ្ឋបាល និង ទំនាក់ទំនងសាធារណៈនឹងផ្នែកគ្រប់គ្រងធនធានមនុស្សហើយផ្នែកទាំងពីរនេះ មានភារកិច្ចដូចតទៅ ៖

- ទទួលលិខិតរដ្ឋបាលផ្លូវការចេញ-ចូលគ្រប់ប្រភេទ និងចាត់ចែងលិខិតទៅតាមការិយាល័យជំនាញនីមួយៗ
- ទទួលបដិសណ្ឋារកិច្ចភ្ញៀវ និងអតិថិជន ដែលមកទំនាក់ទំនងការងារជាមួយរដ្ឋាករ និងការរៀបចំពិធីផ្សេងៗ
- រៀបចំទុកដាក់ឯកសារគ្រប់ប្រភេទ ដែលពាក់ព័ន្ធនឹងរដ្ឋាករឱ្យបានត្រឹមត្រូវ និងមានរបៀបរៀបរយល្អ
- ធ្វើរបាយការណ៍ ស្តីពី សកម្មភាពការងាររបស់រដ្ឋាករប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំជូនអភិបាលរដ្ឋាករ និងគណៈកម្មាធិការអាជីវកម្មជ្រាប
- ធ្វើសេចក្តីផ្សព្វផ្សាយព័ត៌មានផ្សេងៗ ដែលមានផលប្រយោជន៍ដល់រដ្ឋាករ
- រក្សាអនាម័យ និងបរិស្ថានល្អ នៅកន្លែងធ្វើការក្នុងរដ្ឋាករ និងជុំវិញបរិវេណ
- បែងចែកវេនប្រចាំការ ២៤ម៉ោង លើ២៤ម៉ោង ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយល្អនៅក្នុងរដ្ឋាករ
- នីតិវិធី នៃការបញ្ចូលប្រាក់ នៅក្នុងគណនីធនាគារ និងការដកប្រាក់ចេញពីធនាគារ ត្រូវមានការឯកភាពពីអភិបាលរដ្ឋាករ
- រៀបចំគម្រោងថែទាំ ការជួសជុល ការសាងសង់ទីស្នាក់ការ មធ្យោបាយដឹកជញ្ជូន និងសម្ភារប្រើប្រាស់ផ្សេងៗ
- ថែរក្សា និងទុកដាក់សម្ភារប្រើប្រាស់របស់រដ្ឋាករដូចជា ឯកសណ្ឋានបុគ្គលិក អាយកូមនិងបរិក្ខាបំពាក់ផ្សេងៗ ឱ្យបានល្អ
- ធ្វើរបាយការណ៍ ស្តីពី ស្ថានភាពហិរញ្ញវត្ថុ តារាងតុល្យាភាពគណនេយ្យចំណូល-ចំណាយដោយមានសក្ខីប័ត្រ ឬឯកសារសំអាងផ្សេងៗ ប្រចាំខែ ត្រីមាស ឆមាស ៩ ខែ និងឆ្នាំជូនគណៈកម្មាធិការអាជីវកម្មជ្រាប
- និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលរដ្ឋាករ។

- ការិយាល័យបច្ចេកទេស
  - គ្រប់គ្រងយានយន្ត ជួសជុល និងថែទាំរថយន្ត នៅតាមយានដ្ឋាន និងនៅតាមខ្សែនីមួយៗ
  - ធ្វើការតាមដាន និងត្រួតពិនិត្យអំពីការជួសជុល និងថែទាំរថយន្ត

- ធ្វើការបែងចែកម៉ោងពេលចេញ-ចូលរថយន្ត តាមលំដាប់ និងវេន
- គ្រប់គ្រងស្ថានីយ៍ចំណតរថយន្តដើមទី ចុងទី យានដ្ឋានជួសជុលរថយន្ត កន្លែងលាងរថយន្ត និងចំណតរង់ចាំតាមខ្សែនីមួយៗ
- សិក្សាគម្រោងប្តូរខ្សែរត់ និងធ្វើចំណតរង់ចាំ សម្រាប់ខ្សែរត់រថយន្តក្រុងថ្មី
- រៀបចំកាលវិភាគកំណត់ម៉ោងពេលចេញដំណើរ ឬមកដល់នៃរថយន្តនីមួយៗនៅតាមបណ្តាស្ថានីយ៍ ឬចំណតរង់ចាំ ឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែង គឺយ៉ាងច្រើន ១០នាទី ទៅ ១៥នាទី ក្នុងមួយវេន ក្នុងម៉ោងមមាញឹក និង១៥នាទី ទៅ ២០នាទី ក្នុងមួយវេន ក្នុងម៉ោងធម្មតា
- គ្រប់គ្រងការផ្សព្វផ្សាយពាណិជ្ជកម្មតាមរថយន្ត និងតាមចំណតរង់ចាំទាំងអស់
- និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលរដ្ឋាករ។

• ការិយាល័យអធិការកិច្ច និងដោះស្រាយវិវាទ

ការិយាល័យអធិការកិច្ច និងដោះស្រាយវិវាទ មានភារកិច្ចដូចតទៅៈ

- ធ្វើការតាមដាន ត្រួតពិនិត្យម៉ោងពេលការងាររបស់បុគ្គលិកនៅតាមគោលដៅនីមួយៗ និងនៅតាមរថយន្ត ដើម្បីពង្រឹងការងារឱ្យមានប្រសិទ្ធភាព
- ត្រួតពិនិត្យ និងតាមដានរាល់កំហុសខុសឆ្គងរបស់បុគ្គលិកទាំងអស់ និងធ្វើការអប់រំណែនាំដោយត្រូវធ្វើកិច្ចសន្យាព្រមាន
- ចុះអន្តរាគមន៍បន្ទាន់ និងសហការជាមួយកំលាំងមានសមត្ថកិច្ច ករណីមានបាតុភាពគ្រោះថ្នាក់ចរាចរណ៍ និងវិវាទកើតឡើងនៅតាមគោលដៅ និងខ្សែរត់រថយន្តក្រុង
- ត្រួតពិនិត្យ និងតាមដានការកេញប្រវាញ់ប្រាក់របស់បុគ្គលិកអ្នកលក់សំបុត្រ
- សម្របសម្រួល និងដោះស្រាយបញ្ហាវិវាទគ្រប់ប្រភេទ ទាំងវិវាទការងាររដ្ឋាករ និងបុគ្គលិក និងវិវាទកិច្ចសន្យារវាងរដ្ឋាករ ជាមួយអតិថិជន
- ធ្វើបទបញ្ជា សេចក្តីសម្រេច លិខិតបទដ្ឋាននិងអនុស្សារណៈសម្រាប់ប្រើប្រាស់នៅក្នុងរដ្ឋាករ
- និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលរដ្ឋាករ និងគណៈកម្មការអាជីវកម្ម។

### ២.១.២ ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកបម្រើសេវា

ដើម្បីឱ្យដំណើរការ នៃការបម្រើសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងជូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញឱ្យបានរលូន និងមានប្រសិទ្ធភាព អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថ

យន្តក្រុង បានដាក់ចេញនូវកំណត់បែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកបម្រើសេវាតាមផ្នែកនីមួយៗ ដូចខាងក្រោមៈ

- ប្រធានខ្សែ
  - ដឹកនាំ និងគ្រប់គ្រងការងាររួម នៅតាមខ្សែរត់រថយន្តក្រុង
  - ធ្វើការបូកសរុបសភាពការណ៍ដែលកើតមានឡើងនៅក្នុងខ្សែរបស់ខ្លួន និងបូកសរុបស្ថិតិអតិថិជនដែលជិះរថយន្តប្រចាំថ្ងៃ រួចរាយការណ៍មករដ្ឋាករជាប្រចាំ
  - ដោះស្រាយបឋមនូវករណីវិវាទបុគ្គលិក និងបុគ្គលិក និងករណីគ្រោះថ្នាក់ចរាចរណ៍
  - ធ្វើការវាយតម្លៃ និងពិនិត្យលក្ខណសម្បត្តិរបស់បុគ្គលិក ដើម្បីស្នើរសុំការលើកទឹកចិត្តពីរដ្ឋាករ (លិខិតសរសើរ បណ្ណសរសើរ និងប្រាក់ឧបត្ថម្ភលើកទឹកចិត្ត)
  - ត្រូវចូលរួមប្រជុំប្រចាំខែ ឆមាស និងឆ្នាំ តាមការអញ្ជើញរបស់រដ្ឋាករ
  - និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលរដ្ឋាករ។
- ប្រធានក្រុមអ្នកបើកបរ
  - គ្រប់គ្រង និងបណ្តុះបណ្តាលជំនាញបច្ចេកទេសបើកបរបន្ថែម ដល់អ្នកបើកបរ
  - គ្រប់គ្រង និងថែទាំរថយន្ត នៅតាមខ្សែដែលខ្លួនទទួលខុសត្រូវ
  - ផ្តល់ព័ត៌មានអំពីរថយន្តខូច ទៅដល់ការិយាល័យបច្ចេកទេស ដើម្បីធ្វើការជួសជុល
  - ធ្វើរបាយការណ៍អំពីស្ថានភាពរថយន្ត (រថយន្តខូច រថយន្តត្រូវប្តូរប្រេងម៉ាស៊ីន និងគ្រឿងបន្លាស់ផ្សេងៗ) ជាប្រចាំថ្ងៃ ដល់ប្រធានខ្សែ
  - បើករថយន្តជំនួស អ្នកបើកបរដែលបានសុំច្បាប់ និងត្រូវ DAY OFF
  - សហការជាមួយក្រុមជាង និងបុគ្គលិកបច្ចេកទេស ក្នុងការជួសជុលរថយន្តខូច និងថែទាំរថយន្ត
  - ចូលរួមសហការជាមួយអ្នកបើកបរក្នុងការដោះស្រាយវិវាទផ្សេងៗ។
- អ្នកបញ្ជារថយន្ត
  - ធ្វើការស្រង់អវត្តមាន បុគ្គលិកទាំងអស់នៅតាមទិសដៅ និងវេនរបស់ខ្លួន
  - ធ្វើការចាត់ចែងបញ្ជារថយន្តឱ្យចេញដំណើរ ក្នុងរយៈពេល ១០-១៥ នាទីម្តង តាមស្ថានភាពជាក់ស្តែង
  - ធ្វើការកត់ត្រាម៉ោងពេលនៃការ ចេញ-ចូល រថយន្ត ឱ្យបានហ្មត់ចត់
  - ប្រមូលកម្រៃសេវា ពីអ្នកលក់សំបុត្រ រួចប្រគល់ជូនដល់បុគ្គលិកប្រមូលកម្រៃសេវា
  - ផ្តល់សំបុត្រដល់អ្នកលក់សំបុត្រ និងកត់ត្រាពីចំនួនសំបុត្រឱ្យបានច្បាស់លាស់

- ➢ ធ្វើការបូកសរុបស្ថិតិអតិថិជនដែលជិះរថយន្តតាមគោលដៅរបស់ខ្លួន រួចផ្ញើរទៅប្រធានខ្សែ ដើម្បីធ្វើការបូកសរុបរួម។

- អ្នកបើកបរ
  - ➢ មកដល់កន្លែងឱ្យបានមុន ១៥នាទី រួចត្រួតពិនិត្យរថយន្តមុនពេលចេញដំណើរ ដូចជាម៉ាស៊ីនរថយន្ត ប្រព័ន្ធទឹក ប្រព័ន្ធបង្ហិល ប្រព័ន្ធចង្កូត និងតួររថយន្ត
  - ➢ មុនពេលចេញដំណើរត្រូវបញ្ឆេះម៉ាស៊ីន ៥នាទី ដើម្បីធានាថា រថយន្តអាចដំណើរការបាន
  - ➢ ត្រូវបើកបរចូលចំណតរង់ចាំនីមួយៗដោយរក្សាល្បឿនក្រោម ៥kmនិង ត្រូវផ្ដល់ភ្លើងសញ្ញាមុនចូលចំណត
  - ➢ បើកទ្វាររថយន្តរង់ចាំអ្នកដំណើរឡើងជិះ ៣នាទី មុនពេលចេញពីស្ថានីយ៍ចំណត
  - ➢ បើកបរត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ជានិច្ច និងការយោគយល់គ្នាទៅវិញទៅមក
  - ➢ បើកបរត្រូវគោរពច្បាប់ចរាចរណ៍ និងធានាសុវត្ថិភាពដល់អ្នកដំណើរ ទាំងពេលឡើងជិះ ពេលធ្វើដំណើរ និងពេលចុះពីរថយន្ត
  - ➢ ធ្វើការសម្របសម្រួលដោះស្រាយរាល់បាតុភូតភាពដែលកើតមាននៅក្នុងរថយន្ត រួមទាំងករណីគ្រោះថ្នាក់ចរាចរណ៍ផង។

អ្នកបើកបរនៅពេលដែលពួកគាត់កំពុងបំពេញភារកិច្ច ត្រូវតែគោរពតាមច្បាប់ចរាចណ៍ផ្លូវគោកផងដែរ ដែលមានដូចជា ៖

១. ការប្រកាន់ស្តាំ[31]

- អ្នកបើកបរយានជំនិះគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ស្តាំជានិច្ច។
- គ្រប់យានជំនិះដែលមានចលនានៅលើផ្លូវថ្នល់ត្រូវតែមានអ្នកបើកបរ។

២. ការកំណត់និយមន័យនៃពាក្យដែលប្រើក្នុងច្បាប់ចរាចរណ៍[32]

ដើម្បីអនុវត្តច្បាប់ចរាចរណ៍នេះ ពាក្យខាងក្រោមត្រូវកំណត់និយមន័យ ដូចតទៅ៖

- ▪ ពាក្យថា **ផ្លូវថ្នល់** ហៅកាត់ថា ផ្លូវគឺជាទំហំទាំងមូលនៃទ្រូងផ្លូវ រួមជាមួយជាយផ្លូវឬចិញ្ចើមផ្លូវ
- ▪ ពាក្យថា **ទ្រូងផ្លូវ** គឺជាផ្នែកមួយនៃផ្លូវ ទុកសម្រាប់យានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍

[31] មាត្រា ៤ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧។

[32] មាត្រា ៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧។

- ពាក្យថា **ជាយផ្លូវ** គឺជាផ្នែកសងខាងនៃទ្រូងផ្លូវដែលនៅក្រៅទីប្រជុំជនហើយអាចចតយានជំនិះនៅទីនោះបានក្នុងករណីចាំបាច់
- ពាក្យថា **ចិញ្ចើមផ្លូវ** គឺជាជាយផ្លូវនៅក្នុងទីប្រជុំជនដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ប៉ុន្តែមិនអាចចតយានជំនិះនៅទីនោះបានទេ
- ពាក្យថា **គន្លងផ្លូវ** គឺជាចំណែកមួយនៃទ្រូងផ្លូវខ័ណ្ឌដោយគំនូសដាច់ៗ ឬគំនូសបង្អួតតាមបណ្តោយទ្រូងផ្លូវដែលមានទទឹងគ្រប់គ្រាន់អាចឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ
- ពាក្យថា **ទីប្រជុំជន** គឺជាទីកន្លែងដែលមានអគារ ឬគេហដ្ឋានសង់ជិតៗគ្នាហើយផ្លូវចេញ ឬចូលនៅទីនោះមានដាក់ផ្លាកសញ្ញាឈ្មោះទីប្រជុំជនសម្គាល់ការចូល ឬឈ្មោះទីប្រជុំជនដែលមានគំនូសបន្ទាត់ទ្រូងពណ៌ក្រហមសម្គាល់ការចេញពីទីប្រជុំជនតាមដងផ្លូវនិងមានមនុស្សធ្វើចរាចរណ៍ឆ្លងកាត់ទៅមកច្រើន
- ពាក្យថា **ផ្លូវប្រសព្វ** គឺជាទីកន្លែងប្រសព្វនៃផ្លូវពីរឬច្រើនដែលមានផ្ទៃរាបតែមួយ និងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ ផ្លូវប្រសព្វអាចមានរាងជា +, X, T, Y ឬរង្វង់មូលជាដើម
- ពាក្យថា **ផ្លូវរង្វង់មូល** គឺជាទីកន្លែងប្រសព្វនៃផ្លូវពីរ ឬច្រើនហើយដែលនៅចំកណ្តាលមានខឿន រូបសំណាក ឬវិមានផ្សេងៗនិងមានទ្រូងផ្លូវឯកទិសព័ទ្ធជុំវិញដោយមានសញ្ញាព្រួញប្រាប់ទិសចរាចរណ៍
- ពាក្យថា **ផ្លូវសាធារណៈ** គឺជាផ្លូវសម្រាប់បើកឱ្យធ្វើចរាចរណ៍ទូទៅជាសាធារណៈ
- ពាក្យថា **ផ្លូវឯកជន** គឺជាផ្លូវកសាងដោយឯកជន ដែលចែកចេញជាពីរប្រភេទដូចខាងក្រោម ៖
  1. ផ្លូវឯកជនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈ គឺជាផ្លូវបើកឱ្យធ្វើចរាចរណ៍ទូទៅ ដែលបានសាងសង់ ឬជួសជុលដោយឯកជនតាមកិច្ចសន្យាជាមួយរដ្ឋ
  2. ផ្លូវឯកជនមិនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈគឺជាច្រកផ្លូវសម្រាប់បម្រុងទុកបម្រើការងារក្នុងទីបរិវេណណាមួយ ដូចជាច្រកគេហដ្ឋាន រោងចក្រសហគ្រាស អគារ ឬទីលានបរិវេណផ្សេងៗ
- ពាក្យថា **ផ្លូវលំ** គឺជាផ្លូវដីដែលតភ្ជាប់ពីផ្លូវជាតិ ឬ ផ្លូវខេត្ត ឆ្ពោះទៅភូមិ ឬឃុំនៅជនបទ

- ពាក្យថា **ឈប់** គឺជាការនៅស្ងៀមនៃយានជំនិះលើទ្រូងផ្លូវមួយរយៈ ពេលចាំបាច់ដែលមានអ្នកបើកបរស្ថិតនៅជាប់នឹងចង្កូត ឬក្បែរយានជំនិះខ្លួនដើម្បីឱ្យអ្នកដំណើរ ឬយានជំនិះដ៏ទៃទៀតឆ្លងកាត់ ឬដើម្បីអែបខាងដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ
- ពាក្យថា **ចត** គឺការទុកឱ្យយានជំនិះនៅស្ងៀមក្នុងរយៈពេលយូរ ឬឆាប់ដែលអ្នកបើកបរអាចដើរចោលយានជំនិះរបស់ខ្លួនបាន
- ពាក្យថា **អ្នកបើកបរ** គឺជាអ្នកបញ្ជាយានជំនិះគិតទាំងអ្នកជិះ សត្វ អ្នកដឹកសត្វ និងអ្នកបរសត្វនៅលើផ្លូវ
- ពាក្យថា **យានជំនិះ** គឺជាយានសម្រាប់ដឹកមនុស្ស ឬទំនិញនៅលើផ្លូវ ឬសម្រាប់សណ្តោង ឬត្រូវគេសណ្តោង
- ពាក្យថា **យានយន្ត** គឺជាយានដែលធ្វើចរាចរណ៍ ដោយម៉ាស៊ីននៅលើផ្លូវ ដូចជាទោចក្រយានយន្ត ត្រីចក្រយានយន្ត រថយន្ត ត្រាក់ទ័រ និងយានយន្តប្បករណ៍
- ពាក្យថា **យានយន្តុប្បករណ៍** គឺជាយានយន្តពិសេសដែលមានឧបករណ៍ គ្រឿងចក្របំពាក់បន្ថែមដោយគ្មានផ្ទុកមនុស្ស ឬគ្មានផ្ទុកទំនិញនៅក្រៅកាប៊ីន ដូចជារថយន្តលាយស៊ីម៉ង់ត៍ ឬរថយន្តសម្រាប់បម្រើការងារសាងសង់ ផ្លូវ ស្ពាន ជាដើម
- ពាក្យថា **អ្នកប្រើប្រាស់ផ្លូវ** គឺជាអ្នកបើកបរយាន និងអ្នកថ្មើរជើង ដែលធ្វើដំណើរនៅលើផ្លូវ
- ពាក្យថា **ទម្ងន់ទទេរបស់យាន** គឺជាទម្ងន់របស់យានដែលគ្មានមនុស្ស ឬគ្មានទំនិញ ប៉ុន្តែមានប្រេងឥន្ធនៈសម្រាប់ផ្តល់ឱ្យយានមានឧបករណ៍ជួសជុល និងកង់បម្រុង
- ពាក្យថា **ទម្ងន់ផ្ទុកអតិបរមារបស់យាន** គឺជាផលបូកទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញដែលកំណត់ដោយរោងចក្រផលិតយាន
- ពាក្យថា **ទម្ងន់សរុបអតិបរមារបស់យាន** គឺជាផលបូកសរុបទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកអតិបរមារបស់យាន។ បើសិនជាយានមានសណ្តោង ទម្ងន់សរុបអតិបរមារបស់យាន គឺជាផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ
- ពាក្យថា **ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន** គឺជាផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញ បើសិនជាយានមានសណ្តោងទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន គឺជាផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ
- ពាក្យថា **ទម្ងន់សរុបជាក់ស្តែងរបស់យាន** គឺជាផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញជាក់ស្តែង

៣. ល័ក្ខខ័ណ្ឌនៃអ្នកបើកបរ គ្រប់អ្នកបើកយានយន្តគ្រប់ប្រភេទត្រូវអនុវត្តនូវវិធានការដូចខាងក្រោម[33]៖

1) អ្នកបើកបរយានយន្តដែលមានទំហំស៊ីឡាំងចាប់ពី ៤៩សង់ទីម៉ែត្រគូបឡើងទៅ ត្រូវមានបណ្ណបើកបរតាមប្រភេទយានយន្ត
2) នៅពេលបើកបរយានជំនិះអ្នកបើកបរត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ហើយស្ថិតក្នុងស្ថានភាព ដែលអាចធ្វើសកម្មភាពបើកបរបានយ៉ាងស្រួលនិងឆាប់រហ័សជាពិសេសលទ្ធភាពនៃការធ្វើចលនាមិនត្រូវឱ្យមានការរំខានឡើយ។
3) ហាមធ្វើឱ្យរំខានដល់អ្នករស់នៅជាប់តាមដងផ្លូវ និងអ្នកប្រើប្រាស់ផ្លូវ
4) ហាមពិសារជាតិស្រវឹងដែលបណ្តាលឱ្យមានអត្រាជាតិអាកុល ចាប់ពី ០,២៥ មីលីក្រាមក្នុងមួយលីត្រខ្យល់ចាប់ពី ០,៥ ក្រាមក្នុងមួយលីត្រឈានឡើងទៅ។
5) ហាមបើកបរយានជំនិះដែលមានកង់ច្រវ៉ាក់ដែក ផ្ទាល់លើទ្រូងផ្លូវ។ យានជំនិះប្រភេទនេះត្រូវដឹកតាមយានដែល មានប្រភេទកង់កៅស៊ូ។
6) ហាមប្រើទូរស័ព្ទនៅពេលកំពុងបើកបរយានជំនិះ ដោយគ្មានឧបករណ៍សំឡេងភ្ជាប់ទំនាក់ទំនង។
7) ហាមផ្ទុកអ្នកដំណើរ ទំនិញ ឬ វត្ថុផ្សេងៗដែលនាំឱ្យបាំងភ្នែកអ្នកបើកបរ។
8) ទោចក្រយានយន្តអាចផ្ទុកមនុស្សពីរនាក់ និងអាចបន្ថែមបានកុមារមួយនាក់។ អ្នកបើកបរទោចក្រយានយន្ត និងអ្នកដំណើរ ព្រមទាំងកុមារដែលមានអាយុចាប់ពី ៣ (បី) ឆ្នាំឡើងទៅ ត្រូវពាក់មួកសុវត្ថិភាពឱ្យបានត្រឹមត្រូវ។ អ្នកបើកបរត្រីចក្រយានយន្ត និងអ្នកបើកបរទោចក្រយានយន្ត និងអ្នកបើកបរទោចក្រយានយន្តសណ្តោងរម៉កត្រូវពាក់មួកសុវត្ថិភាពឱ្យបានត្រឹមត្រូវ។
9) នៅក្នុងទីប្រជុំជនអ្នកបើកបរ និងអ្នកដំណើរដែលជិះនៅកៅអីខាងមុខនៃរថយន្ត ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព។
10) នៅក្រៅទីប្រជុំជនអ្នកបើកបរ និងអ្នករួមដំណើរទាំងអស់តាមរថយន្ត ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព ស្របតាមបទបញ្ញាត្តិដូចមានចែងក្នុងមាត្រា៩០នៃច្បាប់នេះ។
11) កុមារអាយុតិចជាង ១០ខែ ត្រូវដាក់ក្នុងកៅអីសម្រាប់កុមារដេក និងមានខ្សែក្រវ៉ាត់សុវត្ថិភាពចងផ្អែកកៅអីនេះឱ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត។

[33] មាត្រា ៩ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧។

12) កុមារមានអាយុចាប់ពី ១០ខែ ទៅ៤ឆ្នាំត្រូវអង្គុយ ក្នុងកៅអីសម្រាប់កុមារដែលមានខ្សែក្រវ៉ាត់សុវត្ថិភាពចងផ្អែកកៅអីនេះឱ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត។

13) ហាមក្មេងអាយុក្រោម ១០ឆ្នាំ អង្គុយនៅកៅអីខាងមុខនៃរថយន្ត។

៤. ការប្រើប្រាស់ទ្រូងផ្លូវ[34]

- នៅលើទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរ ហើយដែលគ្មានគំនូសសញ្ញាបែងចែកទិសចរាចរណ៍អ្នកបើកបរត្រូវប្រើប្រាស់ពាក់កណ្តាលទ្រូងផ្លូវផ្នែកខាងស្តាំ ដោយបើកបរកៀកទៅខាងស្តាំ។
- នៅលើទ្រូងផ្លូវឯកទិស ដែលគ្មានគំនូសសញ្ញាបែងចែកគន្លងផ្លូវ អ្នកបើកបរត្រូវបើកបរកៀកទៅខាងស្តាំលើកលែងតែត្រូវការបត់ឆ្វេង។ អ្នកបើកបរអាចប្រើប្រាស់ទ្រូងផ្លូវខាងឆ្វេងបាននៅពេលដែង ឬឈប់។ ដោយឡែក នៅក្នុងទីប្រជុំជនការប្រើប្រាស់ទ្រូងផ្លូវត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

៥. ការឈប់នៅពេលភ្លើងក្រហម

នៅពេលភ្លើងសញ្ញាចរាចរណ៍បញ្ចេញ**ពន្លឺពណ៌លឿង**ជាសញ្ញាឱ្យប្រុងប្រយ័ត្នត្រៀមឈប់ ឬចេញដំណើរទៅមុខ **ពណ៌បៃតង**ជា សញ្ញាអនុញ្ញាតឱ្យយានជំនិះចេញដំណើរ **ពណ៌ក្រហម**គឺជាសញ្ញាឃាត់ឱ្យឈប់។ នៅពេលភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺក្រហមគឺជាសញ្ញាឃាត់ឱ្យឈប់ អ្នកបើកបរត្រូវឈប់នៅមុខខ្សែបន្ទាត់គំនូសជាប់ពណ៌សកាត់ទទឹងទ្រូងផ្លូវ ឬមុខគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់។ បើគ្មានឧបសគ្គនៅខាងមុខ យានជំនិះខាងស្តាំបំផុតអាចបត់ស្តាំបាននៅត្រង់ចំណុចភ្លើងក្រហមណា ដែលមានសញ្ញាអនុញ្ញាតបត់ស្តាំ[35]។

៦. ការបើកបរទន្ទឹមគ្នា និងបើកបរកាត់ក្បួនដង្ហែផ្សេងៗ

អ្នកបើកបរមិនត្រូវបើកបរទន្ទឹមគ្នានៅលើទ្រូងផ្លូវ ឬ គន្លងផ្លូវតែមួយបានទេ។ អ្នកបើកបរមិនត្រូវបើកបរកាត់ក្បួននយោធា ឬក្បួននគរបាល ឬក្បួនគណៈប្រតិភូ ក្បួនដង្ហែរជាផ្លូវផ្សេង[36]។

៧. ការបើកទ្វាយានជំនិះដើម្បីចុះ ឬ ឡើងធ្វើបានតែពេលណាដែលមិនបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកដ៏ទៃដែលកំពុងប្រើប្រាស់ផ្លូវនោះឡើយ និងត្រូវមានការប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសចំពោះការបើកទ្វាចុះ ឬឡើងនៅទ្វាខាងឆ្វេងយាន[37]។

---

[34] មាត្រា ១០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧។

[35] មាត្រា ១២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧។

[36] មាត្រា ១៤ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧។

[37] មាត្រា ២៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧។

៨. ប្រភេទបណ្ណបើកបរយានយន្ត[38]

បណ្ណបើកបរជាតិ និងអន្តរជាតិសម្រាប់យានយន្តគ្រប់ប្រភេទត្រូវចេញដោយក្រសួងសាធារណការ និង ដឹកជញ្ជូន។ ក្រសួងមហាផ្ទៃ ឬក្រសួងការពារជាតិ ត្រូវចេញបណ្ណបើកបរសម្រាប់អ្នកបើកបរយានយន្តពិសេសបម្រើជំនាញដូចជា រថក្រោះ រថពាសដែក រថយន្តបំពាក់យុទ្ធោបករណ៍ យានយន្តប្រដេញ ម៉ូតូកង់បី ម៉ូតូហែរអម ដែលជាទ្រព្យសម្បត្តិរដ្ឋ។

**ប្រភេទ ឃ:** សម្រាប់រថយន្តដឹកអ្នកដំណើរ :

- ✓ **ឃ១** : សម្រាប់រថយន្តដឹកអ្នកដំណើរចាប់ពី ១០នាក់ ដល់ ២០នាក់ដោយគិតទាំងអ្នកបើកបរ និងអាចមានសណ្ដោងរម៉ កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ តោន។
- ✓ **ឃ២** : សម្រាប់រថយន្តដឹកអ្នកដំណើរលើសពី ២០នាក់ ដោយគិតទាំងអ្នកបើកបរ និងអាចមានសណ្ដោងរម៉ កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥តោន។

- អ្នកលក់សំបុត្រ
  - ➢ សំអាតអនាម័យ និងថែទាំសម្ភារដែលមានក្នុងរថយន្តឱ្យបានល្អ
  - ➢ ត្រូវមានអាកប្បកិរិយាស្លូតបូត សុភាពរាបសារ និងរួសរាយរាក់ទាក់ភ្ញៀវ
  - ➢ ជម្រាបភ្ញៀវឱ្យដាក់ថវិកាចូលក្នុងហិប ឬធុង និងហែកសំបុត្រជូនភ្ញៀវ
  - ➢ ជម្រាបជូនភ្ញៀវឱ្យអង្គុយលើកៅអី ឬកន្លែងគួរសម្យ មុនចេញដំណើរ និងជូនដំណឹងអំពីតម្រាយផ្លូវដែលអាចធ្វើការផ្លាស់ប្ដូរខ្សែ និងទិសដៅដែលត្រូវទៅបន្ត
  - ➢ ធ្វើការទូទាត់កម្រៃសេវាដែលប្រមូលបានពីអតិថិជន ជូនដល់អ្នកបញ្ជារថយន្ត នៅពេលបញ្ចប់ម៉ោងការងាររបស់ខ្លួន
  - ➢ ត្រូវធ្វើការកត់ត្រា និងបូកសរុបស្ថិតិភ្ញៀវ (បង់ប្រាក់ និង មិនបង់ប្រាក់) ដែលជិះរថយន្តប្រចាំថ្ងៃ ជូនដល់អ្នកបញ្ជារថយន្ត

ដើម្បីធានាដល់សណ្ដាប់ធ្នាប់មុនពេលឡើងជិះ ឬ នៅពេលដែលបានឡើងជិះនៅលើរថយន្តនោះរដ្ឋាករក៏បានចេញនូវបទបញ្ជាមួយចំនួនសម្រាប់អ្នកដំណើរផងដែរដូចជា៖

+ បទបញ្ជាផ្ទៃក្នុងរថយន្តក្រុង (City Bus)

[38] មាត្រា ៨០ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧។

1. អ្នកដំណើរត្រូវតម្រៀបជួររង់ចាំនៅចំណតមុនពេលរថយន្តមកដល់ ហើយនៅពេលរថយន្តមកដល់ និងឈប់ស្ងៀមទើបអាចឡើង ឬចុះពីរថយន្តដោយមានរបៀបរៀបរយ (ឡើងតាមទ្វាមុខ ចុះតាមទ្វាក្រោយ)
2. ហាមពិសារបារី
3. សូមរក្សាភាពស្ងៀមស្ងាត់
4. ហាមខាកស្តោះ
5. ហាមបរិភោគចំណីអាហារ និងគ្រឿងស្រវឹង
6. មុនឡើងឡាន ត្រូវត្រៀមលុយ ១,៥០០រៀល
7. សិស្ស និស្សិត គ្រូបង្រៀន កីឡាករ អ្នកកាត់ដេររោងចក្រមុនឡើងឡាន ត្រូវពាក់កាតសម្គាល់ខ្លួន
8. ត្រូវឡើងតាមចំណត និងចុះតាមចំណត
9. សូមចោលសំរាមក្នុងធុងសំរាម
10. សំបុត្ររថយន្តទិញរួចមិនអាចប្តូរយកលុយវិញបានទេ
11. សូមថែរក្សាទ្រព្យសម្បត្តិដោយខ្លួនឯង
12. យើងខ្ញុំមិនទទួលខុសត្រូវចំពោះការបាត់បង់ឡើយ។

## ២.២ ប្រសិទ្ធភាពនៃការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ

ក្នុងខែ កញ្ញា ឆ្នាំ ២០០១ ទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន (JICA) បានចាប់ផ្តើមឱ្យមានគម្រោងសេវាកម្មដឹកជញ្ជូនសាធារណៈផ្នែករថយន្តក្រុង សម្រាប់ធ្វើការសាកល្បងដឹកជញ្ជូនប្រជាពលរដ្ឋ ដោយក្នុងនោះមានចំនួន១ខ្សែសម្រាប់ធ្វើដំណើរគឺខ្សែទី១ ហើយគម្រោងនោះក៏ត្រូវបានរៀបចំឡើងក្នុងរយៈពេល១ខែ។ ក្រោយពេល JICA បានបញ្ចប់គម្រោងរបស់ខ្លួនរួចមកហើយនោះសាលារាជធានីភ្នំពេញបានបញ្ជូនទៅឱ្យមន្ទីរសាធារណការជាអ្នកបន្តនិរន្តរភាពដោយរថយន្តត្រូវបានជូលពីអង្គការ JICA សម្រាប់ផ្តល់នូវសេវាកម្មក្នុងខ្សែដ៏ដែរ ដែលនៅក្នុងនោះមានរថយន្តចំនួន ១០ គ្រឿងតែប៉ុណ្ណោះ។

ក្នុងឆ្នាំ ២០១៤ រដ្ឋាភិបាលបានបង្កើតសេវាកម្មដឹកជញ្ជូនរថយន្តក្រុងសាធារណៈដោយដាក់ឱ្យមានដំណើរការក្នុងនោះគឺចំនួន ៣ ខ្សែ និង បន្តបង្កើតឱ្យមានខ្សែរថយន្តនេះពីមួយឆ្នាំទៅមួយឆ្នាំ។

រហូតមកដល់នៅក្នុងឆ្នាំ ២០១៨ រថយន្តក្រុងបានកើនឡើងរហូតទៅដល់ ៨ ខ្សែ និង ចំណតសរុបមានប្រហែលជា ៦០០ ចំណតដោយពីចំណតមួយទៅកាន់ចំណតមួយទៀតមានគម្លាតពី

៣០០ម ទៅ៥០០ម មូលហេតុដែលចំណតមិនមានភាពស្មើរគ្នាគឺដោយសារតែកន្លែងខ្លះត្រូវបានប៉ះពាល់ទៅដល់ផ្ទះរបស់ប្រជាពលរដ្ឋ។ ហើយនៅក្នុងចំណតនីមួយៗគឺមានស្លាកដែលបញ្ជាក់ពីទីតាំងរបស់ខ្សែរថយន្តដែលត្រូវធ្វើដំណើរទៅដល់តំបន់នីមួយៗ, មានកន្លែងអង្គុយសម្រាប់ផ្តល់ជូនទៅប្រជាពលរដ្ឋដែលរង់ចាំជិះរថយន្ត, មានដំបូល ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះគឺនៅក្នុងចំណតនីមួយៗត្រូវបានបំពាក់ដោយផ្ទាំងកញ្ចក់សូឡា ដោយអាចបញ្ចេញភ្លើងនៅពេលដែលព្រះអាទិត្យលេច វាគឺជារឿងមួយដែលមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋដែលរង់ចាំនៅការប្រើប្រាស់នូវសេវារថយន្តក្រុងនេះ។

**២.២.១ រៀបធៀបខ្សែរថយន្ត (២០១៥-២០១៧)**

ក្នុងឆ្នាំ២០១៥ សេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈត្រូវបានដំណើរការចំនួន៣ខ្សែគឺ ខ្សែទី១, ទី២និងទី៣ ដែលមានរថយន្តក្រុងចំនួន ៥៧គ្រឿង និងមានចំណតចំនួនសរុប ៣៦ចំណត។ លិទ្ធផលសរុបសម្រាប់ប្រចាំឆ្នាំដែលបានមកពីការជិះរថយន្តក្រុងនោះសរុបមានចំនួនប្រហែល ២,២០១,៦១៩,០០ បើគិតជាភាគរយប្រហែលជាង ២៨.៣៩% ដោយគិតជាមធ្យមអាចមានដំណើរជាមធ្យមជាង ៦ពាន់នាក់ធ្វើដំណើរក្នុងមួយថ្ងៃ។ យ៉ាងណាមិញមានរថយន្ត ១៩គ្រឿង ត្រូវបានត្រៀមបម្រុងជំនួសឡានដែលខូចនៅពេលដែលកំពុងប្រត្តិបត្តិការ។ សាលារាជធានីភ្នំពេញ នឹងបន្តខិតខំពង្រឹងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងផ្តល់សេវាឱ្យបានល្អជាងនេះ ជាពិសេសគឺពង្រីកខ្សែរត់បន្ថែមឱ្យដល់ ១០ខ្សែ ដើម្បីផ្តល់ភាពងាយស្រួល សម្រាប់ការធ្វើដំណើររបស់ប្រជាពលរដ្ឋក៏ដូចជាភ្ញៀវទេសចរណ៍ អ្នកដំណើរជាង ២លាននាក់ និងអ្នកដំណើរបង់ប្រាក់មានប្រមាណ ១លាន ៣សែននាក់[39]។

ក្នុងឆ្នាំ ២០១៦ សេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈត្រូវបានដំណើរការចំនួន ៣ខ្សែដ៏ដែរគឺខ្សែទី១, ទី២ និងទី៣។ ប៉ុន្តែអ្វីដែលខុសគឺលិទ្ធផលដែលទទួលបានពីអ្នកដំណើរគឺមានការកើនឡើងគឺមានចំនួនប្រហែល ២,៣៦១,៥១៥,០០ បើគិតជាភាគរយប្រហែលជា ៣០.៤៥% ដោយគិតជាមធ្យមអាចទទួលអ្នកដំណើរជាង ៦ពាន់នាក់ក្នុងមួយថ្ងៃ[40]។ ដោយក្រឡេកមើលទៅក្នុងទិន្នន័យពីឆ្នាំ២០១៥ ដល់២០១៦ អ្នកដំណើរដែលទទួលយកសេវាដឹកជញ្ជូនរថយន្តសាធារណៈមានការកើនឡើង ប៉ុន្តែការកើនឡើងមានកម្រិតទាបនៅឡើយ ដោយសារតែចំនួនខ្សែរថយន្តមិនមានការកើនឡើងទេ ហើយមួយវិញទៀតប្រជាពលរដ្ឋភាគច្រើនមិនទាន់ដឹងថាសេវាដឹកជញ្ជូនរថយន្តក្រុង

[39] យោងតាមគេទំព័ររបស់លោកប៉ា សុជាតិថ្ងៃទី៥ខែកុម្ភៈឆ្នាំ២០១៩។

[40] លោកមាស ម៉េតភក្តីអ្នកនាំពាក្យសាលារាជធានីភ្នំពេញ។

សាធារណៈត្រូវបានកើតឡើងនោះទេ និងមានប្រជាពលរដ្ឋមួយចំនួនដែលដឹងថាមានសេវាកម្មនេះ ហើយប៉ុន្តែពួកគេមិនទាន់បានធ្វើដំណើរ ដោយពួកគាត់មិនទាន់ដឹងពីរបៀបនៃការប្រើប្រាស់,តម្លៃ, នឹងកន្លែងដែលត្រូវចុះនៅឡើយ។

រហូតមកដល់ឆ្នាំ២០១៧អាជ្ញាធររាជធានីភ្នំពេញ បានកែសម្រួលនិងបន្ថែមតម្រាយខ្សែរត់ថ្មី ដល់រថយន្តក្រុងសាធារណៈ នៅភ្នំពេញសរុបមាន ៨ខ្សែរត់។ ក្នុងនោះ ការកែសម្រួលតម្រាយផ្លូវនៃខ្សែ សម្រាប់រថយន្តក្រុងសាធារណៈ នឹងចាប់ផ្តើមពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៧ ហើយមួយទៀតគឺចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៧ រថយន្តក្រុងសាធារណៈរបស់សាលារាជធានីភ្នំពេញ នឹងថែមខ្សែរត់ ៥ខ្សែទៀត។ ការដាក់បន្ថែមនៃរថយន្តនេះគឺមានជំនួយពីរដ្ឋាភិបាលចិន ដែលបានជំនួយមកនូវរថយន្តចំនួន ១០០គ្រឿង ក្នុងនោះមានប្រភេទរថយន្តក្រុងដឹកអ្នកដំណើរធុនធំ ៣៥ កៅអីចំនួន ៦០ គ្រឿង រថយន្ត ២៧ កៅអីចំនួន ៣៨ គ្រឿង និង ប្រភេទរថយន្តស្ទូចចំនួន ២ គ្រឿង ប្រើប្រាស់ដោយការចាក់សាំង ក្រោមជំនួយនេះដែលសាលារាជធានីភ្នំពេញបានសម្ភោធន៍ទទួលនៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៧[41]។

ការបន្ថែមលើខ្សែរថយន្តក្រុងនេះគឺគេមើលឃើញថាមានសន្ទុះកើនឡើងដោយចំនួនអ្នកធ្វើដំណើរមាន៣,១៩១,៧៧០,០០ បើគិតជាភាគរយមានប្រហែលជា៤១.១៦% ដោយគិតជាមធ្យមអាចទទួលអ្នកដំណើរជាមធ្យមជាង ៨ពាន់នាក់ក្នុងមួយថ្ងៃ។ ក្នុងឆ្នាំ២០១៧នេះ អ្នកដំណើរតាមរថយន្តក្រុងសាធារណៈមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារតែប្រជាពលរដ្ឋកាន់តែយល់ច្បាស់ពីរបៀបប្រើប្រាស់សេវាកម្ម, ការបន្ថែមខ្សែរថយន្តមានទៅដល់៨ខ្សែ ដោយការពីឆ្នាំ២០១៦មានតែ ៣ខ្សែតែប៉ុណ្ណោះ ហេតុផលទាំងនេះទើបបណ្តាឱ្យមានការប្រើប្រាស់សេវាមួយនេះកាន់តែច្រើន។

**ចំនួនអតិថិជនប្រើប្រាស់រយន្តក្រុងប្រចាំឆ្នាំ**

| ចំនួនអ្នកជិះ២០១៥ | ចំនួនអ្នកជិះ២០១៦ | ចំនួនអ្នកជិះ២០១៧ | ចំនួនអ្នកជិះសរុប |
|---|---|---|---|
| ២,២០១,៦១៩,០០ | ២,៣៦១,៥១៥,០០ | ៣,១៩១,៧៧០,០០ | ៧,៧៥៤,៩០៤,០០ |

យោងទៅតាមការចុះសើបសួរពីប្រជាពលរដ្ឋដែលកំពុងតែប្រើប្រាស់នាពេលបច្ចុប្បន្នបានឱ្យដឹងថា ប្រជាពលរដ្ឋដែលប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់ពួកគាត់ ដោយយានជំនិះខ្លួនឯងបានងាកមកប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងជាបណ្តើរៗហើយ ដោយសារតែពួក

[41] https://autobodia.com

គាត់យល់ឃើញថាប្រសិនបើពួកគាត់ប្រើប្រាស់សេវាមួយនេះគឺពួកគាត់មានការចំណេញច្រើនណាស់ ដូចជា៖

- កម្លាំងៈ ប្រសិនបើពួកគាត់ប្រើប្រាស់យានជំនិះខ្លួនឯងពួកគាត់ត្រូវចំណាយកម្លាំងទៅលើការបើកបរ ប៉ុន្តែប្រសិនបើពួកគាត់ប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងពួកគាត់មិនចាំបាច់បារម្ភណ៍ទៅលើការបើកបរនោះទេ ពួកគាត់គ្រាន់តែបង់ប្រាក់ ឬ ថវិកាតែ១,៥០០៛ រួចចូលទៅអង្គុយជាការស្រេច
- ថវិកាៈ ពួកគាត់មិនចាំបាច់ចំណាយថវិកាច្រើនសម្រាប់ចាក់សាំង
- ភ្លើង និងស្លាកសញ្ញាចរាចរណ៍ៈ ពួកគាត់មិនចាំបាច់ប្រុងប្រយ័ត្នភ្លើង និងស្លាកសញ្ញាចរាចរណ៍នោះទេ ព្រោះអ្នកបើកបររថយន្តសាធារណៈជាអ្នកដើរតួនាទីនេះ
- គ្រោះថ្នាក់ចរាចរណ៍ៈ ពួកគាត់មិនបាច់មានការព្រួយបារម្ភណ៍ក្នុងការទៅប៉ះទង្គិចជាមួយនរណាម្នាក់ដោយអចេតនានោះទេ
- អារម្មណ៍ៈ ពួកគាត់មិនមានអារម្មណ៍តានតឹងពីការកកស្ទះចរាចរណ៍នោះទេ

នៅមានចំនុចជាច្រើនទៀតដែលបងប្អូនប្រជាពលរដ្ឋងាកមកប្រើប្រាស់សេវាដឹកជញ្ជូនសារធារណៈរថយន្តក្រុងមួយនេះ។

កំណើននៃអ្នកធ្វើដំណើរមានការឡើងក៏ពិតមែនក៏ប៉ុន្តែនៅតែមានចំណុចមួយចំនួនមិនមានការពេញទៅលើសេវាមួយនេះផងដែរ។ នៅខាងក្រោមនេះគឺជាតារាដែលបានចុះទៅសាកសួរប្រជាពលរដ្ឋដែលប្រើប្រាស់សេវាកម្មមួយនេះ៖

- Obs ចំនួនប្រជាជនដែលត្រូវបានសម្ភាស
- Name ឈ្មោះ
- Sex ភេទ
- Age អាយុរបស់ប្រជាជន
- Duration រយៈពេលនៃការរង់ចាំ
- Distance រយៈពេលពីទីតាំងមួយទៅដល់ចំណាត
- Usage ខ្សែរថយន្តដែលបានប្រើប្រាស់

**តារាងតាមការសាកសួរតាមខ្សែនីមួយៗ**

| Obs | Name | Sex | Age | Duration | Distance | Usage |
|---|---|---|---|---|---|---|
| 1 | ជា | ប្រុស | 30 | 15 | 20 | 2 |
| 2 | សី ឡា | ប្រុស | 22 | 1 | 5 | 1 |

| | | | | | | |
|---|---|---|---|---|---|---|
| 3 | ធីតា | ស្រី | 37 | 17 | 80 | 6 |
| 4 | ស័ក្តិ | ប្រុស | 18 | 10 | 12 | 5 |
| 5 | ស្រី រ៉ា | ស្រី | 36 | 7 | 30 | 7 |
| 6 | ស្មើ | ប្រុស | 57 | 10 | 20 | 3 |
| 7 | ប៉ែក អេលីហ្សា | ស្រី | 17 | 17 | 65 | 6 |
| 8 | ប៊ុន ណេ | ប្រុស | 42 | 22 | 100 | 3 |
| 9 | សេង សុខលាប | ប្រុស | 18 | 4 | 300 | 6 |
| 10 | ម៉េង ជាតិ | ប្រុស | 14 | 20 | 210 | 6 |
| 11 | និមល | ស្រី | 17 | 20 | 300 | 6 |
| 12 | រឿន រ៉ានី | ប្រុស | 22 | 20 | 70 | 5 |
| 13 | អ៊ឹម ឡុង | ស្រី | 57 | 15 | 85 | 2 |
| 14 | មាស មិនា | ប្រុស | 30 | 5 | 25 | 4 |
| 15 | ហៀង ប៊ុនថេង | ប្រុស | 43 | 1 | 5 | 7 |
| 16 | អ៊ឹម សុភក្រ្ត | ប្រុស | 28 | 15 | 230 | 6 |
| 17 | ហ៊ុយ គឹមហាវ | ស្រី | 65 | 15 | 30 | 4 |
| 18 | អេង ហៀង | ស្រី | 18 | 2 | 5 | 5 |
| 19 | អ៊ុក ចាន់សីហៈ | ប្រុស | 16 | 3 | 5 | 5 |
| 20 | ផន | ស្រី | 42 | 22 | 55 | 3 |
| 21 | ចាន់ មន្តថា | ស្រី | 52 | 1 | 5 | 5 |
| 22 | ជា ថាវី | ស្រី | 47 | 10 | 20 | 4 |
| 23 | ថន មករា | ប្រុស | 47 | 10 | 20 | 5 |
| 24 | ផល សុភក្រ្ត | ស្រី | 33 | 5 | 5 | 6 |
| 25 | យឹម រី | ស្រី | 54 | 5 | 5 | 1 |
| 26 | តាំង ប៊ុនឡេង | ប្រុស | 28 | 15 | 65 | 2 |
| 27 | ស្រី ពេជ្រ | ស្រី | 28 | 5 | 5 | 5 |
| 28 | កែវ ចាន់ធី | ស្រី | 35 | 15 | 70 | 4 |
| 29 | ប៊ូ សុខា | ស្រី | 50 | 15 | 10 | 2 |
| 30 | ហឿង ស្រី | ស្រី | 45 | 7 | 20 | 2 |
| 31 | ម៉ាក់ ចេង | ស្រី | 62 | 15 | 5 | 4 |
| 32 | ធីម ផារ៉ុង | ប្រុស | 31 | 15 | 70 | 2 |
| 33 | ភារម្យ | ស្រី | 30 | 5 | 5 | 2 |
| 34 | ចាន់ ថា | ប្រុស | 48 | 22 | 25 | 1 |
| 35 | រិន សុកល | ស្រី | 25 | 10 | 25 | 1 |

| | | | | | | |
|---|---|---|---|---|---|---|
| 36 | ឡឹង រ័ត្នសិទ្ធារី | ស្រី | 26 | 12 | 65 | 2 |
| 37 | សូ ភី | ស្រី | 63 | 15 | 5 | 5 |
| 38 | ដម ចាន់ថន | ប្រុស | 25 | 4 | 5 | 6 |
| 39 | នី ថុង | ប្រុស | 22 | 15 | 65 | 6 |
| 40 | ផាន់ សុផាន់ណា | ស្រី | 18 | 15 | 45 | 5 |
| 41 | អ៊ល សារឿន | ស្រី | 20 | 15 | 65 | 5 |
| 42 | រឿន ស្រីណី | ស្រី | 15 | 15 | 45 | 6 |
| 43 | ផល្លា | ប្រុស | 22 | 15 | 65 | 6 |
| 44 | សីហា | ប្រុស | 20 | 10 | 30 | 6 |
| 45 | វណ្ណ ឆេន | ប្រុស | 13 | 10 | 30 | 6 |
| 46 | ផាន់ នាង | ស្រី | 51 | 15 | 10 | 1 |
| 47 | ឈឿន សុផាត | ស្រី | 25 | 5 | 5 | 5 |
| 48 | ឡាយ គីមឡេង | ស្រី | 24 | 15 | 65 | 5 |
| 49 | លឹម ស៊ូធី | ស្រី | 55 | 15 | 10 | 4 |
| 50 | ឡាយ សុជារ័ត្ន | ស្រី | 28 | 15 | 65 | 4 |
| 51 | យឹន ចាន់ពេជ្រ | ប្រុស | 32 | 15 | 70 | 2 |
| 52 | ក្រូច ណារី | ស្រី | 29 | 27 | 90 | 1 |
| 53 | ហាន សុលក្ខិណា | ស្រី | 37 | 15 | 70 | 2 |
| 54 | គ្រី ឬទ្ធិស័ក្តិ | ប្រុស | 13 | 15 | 45 | 3 |
| 55 | លី ប៉ាក់ | ស្រី | 37 | 15 | 70 | 4 |
| 56 | សំ ចាន់នី | ស្រី | 27 | 17 | 80 | 3 |
| 57 | សេត វិសាល | ប្រុស | 22 | 12 | 65 | 4 |
| 58 | ឃុន បញ្ញាវឌ្ឍន៍ | ប្រុស | 17 | 5 | 5 | 6 |
| 59 | ហ៊ឹម បូរ៉ា | ប្រុស | 18 | 17 | 45 | 6 |
| 60 | ស៊ឹម ថនដារ៉ា | ប្រុស | 37 | 3 | 5 | 1 |
| 61 | អ៊ំ វណ្ណី | ស្រី | 32 | 15 | 70 | 5 |
| 62 | ឌុច ពៅ | ស្រី | 43 | 3 | 5 | 5 |
| 63 | ទុំ ស្រីម៉ៅ | ស្រី | 54 | 3 | 5 | 5 |
| 64 | រិទ្ធ | ប្រុស | 45 | 1 | 5 | 2 |
| 65 | ខាត ញឹម | ប្រុស | 83 | 1 | 5 | 1 |
| 66 | លឹម ស៊ុនហុង | ប្រុស | 75 | 1 | 5 | 1 |
| 67 | ស៊ុន ប៊ុនថៃ | ប្រុស | 72 | 5 | 5 | 1 |
| 68 | បញ្ញា | ស្រី | 29 | 10 | 25 | 3 |

| | | | | | | |
|---|---|---|---|---|---|---|
| 69 | រិន ពៅ | ស្រី | 25 | 5 | 5 | 6 |
| 70 | សោម ស្រីមុំ | ស្រី | 30 | 5 | 5 | 4 |
| 71 | សុខ យាន | ស្រី | 62 | 5 | 5 | 1 |
| 72 | ផន គន្ធា | ស្រី | 27 | 5 | 5 | 5 |
| 73 | សុភី | ប្រុស | 27 | 5 | 5 | 1 |
| 74 | មុន្នី | ស្រី | 22 | 10 | 25 | 4 |
| 75 | សីហា | ប្រុស | 18 | 15 | 45 | 5 |
| 76 | អ៊ិន ប៊ុនភឿន | ស្រី | 37 | 10 | 20 | 4 |
| 77 | សា រស់ | ស្រី | 45 | 5 | 5 | 2 |
| 78 | ហ៊ាន សុ | ស្រី | 63 | 5 | 5 | 3 |
| 79 | ដូលី | ស្រី | 73 | 5 | 5 | 1 |
| 80 | មាស ច័ន្ទដារ៉ា | ប្រុស | 32 | 10 | 20 | 4 |
| 81 | សុខ ធី | ប្រុស | 43 | 5 | 5 | 1 |
| 82 | វត្តី | ស្រី | 44 | 5 | 5 | 4 |
| 83 | ឡេង ច័ន្ទភារី | ស្រី | 18 | 15 | 45 | 5 |
| 84 | ហៀង ហេងចេង | ស្រី | 14 | 15 | 45 | 3 |
| 85 | ពេជ្រ | ស្រី | 15 | 15 | 45 | 3 |
| 86 | ស៊ូ យុត្តិ | ប្រុស | 40 | 15 | 70 | 3 |
| 87 | ពន្លិក | ប្រុស | 31 | 10 | 20 | 1 |
| 88 | ចាន់ | ស្រី | 52 | 15 | 10 | 1 |
| 89 | ឡាយ | ស្រី | 19 | 15 | 45 | 4 |
| 90 | ហាង | ស្រី | 63 | 5 | 5 | 2 |
| 91 | លឹម ធីតា | ស្រី | 19 | 12 | 45 | 6 |
| 92 | ឈឹម ចាន់នី | ស្រី | 37 | 5 | 5 | 2 |
| 93 | ញ៉ឹក សារ៉េន | ប្រុស | 58 | 5 | 5 | 3 |
| 94 | នីសា | ស្រី | 21 | 10 | 25 | 1 |
| 95 | សូង សិលា | ស្រី | 23 | 5 | 5 | 4 |
| 96 | ឌី ច័ន្ទតារា | ប្រុស | 16 | 30 | 70 | 5 |
| 97 | អ៊ុក ផន | ប្រុស | 65 | 15 | 5 | 1 |
| 98 | អ៊ុក អៀ | ស្រី | 51 | 15 | 10 | 2 |
| 99 | ចំណាន | ប្រុស | 37 | 5 | 5 | 5 |
| 100 | ស្រី តូច | ស្រី | 30 | 15 | 65 | 3 |
| 101 | កុល គីមនី | ស្រី | 63 | 15 | 5 | 1 |

| | | | | | | |
|---|---|---|---|---|---|---|
| 102 | ថាវី | ស្រី | 25 | 10 | 25 | 5 |
| 103 | អ៊ុក ស្រីមុំ | ស្រី | 35 | 15 | 70 | 1 |
| 104 | សៀន ស្រី | ស្រី | 39 | 10 | 20 | 1 |
| 105 | ហិន ចាន់នី | ស្រី | 32 | 15 | 70 | 6 |
| 106 | ចិន ស្រុក | ស្រី | 36 | 10 | 20 | 5 |
| 107 | ប៉ែន សុខន | ស្រី | 39 | 20 | 70 | 2 |
| 108 | សុត វណ្ណៈ | ប្រុស | 21 | 15 | 65 | 5 |
| 109 | គឹម ណៃគី | ស្រី | 52 | 15 | 10 | 1 |
| 110 | សុត នី | ស្រី | 24 | 15 | 65 | 4 |
| 111 | មន សុខនី | ស្រី | 42 | 20 | 10 | 2 |
| 112 | អុយ គឹមត្រា | ស្រី | 72 | 15 | 5 | 1 |
| 113 | ឈាង ឆៃស្រៀង | ប្រុស | 62 | 5 | 5 | 1 |
| 114 | ព្រាប វិទ្យា | ស្រី | 49 | 10 | 20 | 2 |
| 115 | គិត ណារឿន | ស្រី | 64 | 15 | 5 | 1 |
| 116 | វុទ្ធី | ប្រុស | 36 | 30 | 55 | 1 |
| 117 | ហួង ពិសី | ស្រី | 10 | 5 | 5 | 2 |
| 118 | អានមិនដាច់ | ស្រី | 55 | 7 | 15 | 2 |
| 119 | ញ៉ែម យួន | ប្រុស | 57 | 10 | 15 | 1 |
| 120 | ពេជ ខាវ | ប្រុស | 19 | 15 | 45 | 6 |
| 121 | ជា ដាលីន | ស្រី | 13 | 15 | 45 | 6 |
| 122 | ឃុត សម្បត្តិ | ប្រុស | 12 | 15 | 45 | 6 |
| 123 | ហៀង សិរិបុត្រ | ប្រុស | 13 | 15 | 45 | 6 |
| 124 | ជា សារើន | ស្រី | 19 | 5 | 5 | 6 |
| 125 | នូ ស្ស៊ីសេនី | ស្រី | 17 | 15 | 45 | 6 |
| 126 | ខៀវ ស្រីណុច | ស្រី | 12 | 5 | 5 | 6 |
| 127 | ផល សុគន្ធារី | ស្រី | 12 | 5 | 5 | 6 |
| 128 | ហឿន និតនីតា | ស្រី | 11 | 18 | 45 | 6 |
| 129 | សៅ លិនដា | ស្រី | 13 | 5 | 5 | 6 |
| 130 | ស្រួយ ច័ន្ទមេសា | ប្រុស | 8 | 5 | 5 | 6 |
| 131 | ស្រួយ នារីវឌ្ឍនា | ស្រី | 12 | 5 | 5 | 6 |
| 132 | អានមិនដាច់ | ស្រី | 12 | 5 | 5 | 6 |
| 133 | សុធន សែនវីរៈ | ប្រុស | 25 | 15 | 65 | 4 |
| 134 | ថាន់ ឧប្បលា | ស្រី | 22 | 5 | 5 | 3 |

| | | | | | | |
|---|---|---|---|---|---|---|
| 135 | ពៅ | ស្រី | 36 | 5 | 5 | 4 |
| 136 | ស្រីពេជ្រ | ស្រី | 15 | 15 | 45 | 6 |
| 137 | ចិន្តា | ស្រី | 27 | 12 | 65 | 5 |
| 138 | ឡុង រ៉ាយុទ្ធ | ប្រុស | 16 | 12 | 45 | 4 |
| 139 | ម៉ារ៉ា | ស្រី | 30 | 15 | 65 | 1 |
| 140 | នៅ សុខណា | ស្រី | 14 | 30 | 70 | 6 |
| 141 | គា សុខលាភ | ស្រី | 14 | 15 | 45 | 6 |
| 142 | ស្រីទូច | ស្រី | 32 | 22 | 80 | 1 |
| 143 | ជូ សេងឈាង | ស្រី | 14 | 22 | 70 | 6 |
| 144 | រ៉េត ឧត្តមសត្យា | ប្រុស | 12 | 20 | 120 | 6 |
| 145 | អែម | ស្រី | 54 | 10 | 15 | 2 |
| 146 | ម៉ី សៀវហ៊្កិច | ស្រី | 12 | 15 | 45 | 3 |
| 147 | ហុង ឡេង | ស្រី | 41 | 22 | 55 | 2 |
| 148 | ស៊ីង យ៉ុងហ្វាត | ប្រុស | 14 | 3 | 5 | 6 |
| 149 | ទូច រដ្ឋា | ស្រី | 14 | 15 | 45 | 6 |
| 150 | អ៊ឹង ឆាយប៉ | ប្រុស | 10 | 8 | 30 | 6 |
| 151 | លឹម វណ្ណឈូដា | ប្រុស | 13 | 3 | 5 | 6 |
| 152 | ឡាយ សម្បត្តិវិសាល | ប្រុស | 12 | 15 | 45 | 6 |
| 153 | ស៊ីន ម៉េងគ័ង | ប្រុស | 15 | 15 | 45 | 6 |
| 154 | សាយ ផាន់ណា | ប្រុស | 15 | 15 | 45 | 6 |
| 155 | វ៉ុន ទេពវ៉ាណាន់ | ប្រុស | 14 | 3 | 5 | 6 |
| 156 | កែវ | ស្រី | 20 | 15 | 65 | 7 |
| 157 | អ៊ូជ ចាន់ណូង | ប្រុស | 14 | 20 | 70 | 6 |
| 158 | ស្រីមួយ | ស្រី | 13 | 20 | 70 | 6 |
| 159 | អាំង មួយហ៊ាង | ស្រី | 11 | 20 | 120 | 3 |
| 160 | យ៉ឹន ទៀង | ស្រី | 57 | 5 | 5 | 1 |
| 161 | ឈុំ ផល្លា | ស្រី | 18 | 12 | 45 | 5 |
| 162 | ឡឹង | ស្រី | 52 | 5 | 5 | 1 |
| 163 | លៀង ឆេង | ស្រី | 50 | 15 | 10 | 1 |
| 164 | សុខ ចំរើន | ប្រុស | 30 | 15 | 65 | 3 |
| 165 | នៅ ធុន | ប្រុស | 50 | 30 | 25 | 3 |
| 166 | អ៊ឹង ឆាយហេង | ប្រុស | 12 | 12 | 45 | 4 |
| 167 | ស៊ាង | ប្រុស | 20 | 17 | 65 | 2 |

| | | | | | | |
|---|---|---|---|---|---|---|
| 168 | អូន ស្រីនិច | ស្រី | 22 | 17 | 65 | 5 |
| 169 | សម្បត្តិ ចរិយា | ស្រី | 36 | 25 | 80 | 1 |
| 170 | ធូយ ដេតវណ្ណា | ស្រី | 17 | 10 | 30 | 5 |
| 171 | នៅ ស្រីលក្ខ័ | ស្រី | 31 | 5 | 5 | 2 |
| 172 | ជូ នុតអ៊ឹម | ប្រុស | 33 | 15 | 70 | 1 |
| 173 | ពេជ្រ សុង | ស្រី | 72 | 15 | 5 | 1 |
| 174 | សុផល | ស្រី | 36 | 15 | 70 | 2 |
| 175 | យ៉ាន | ស្រី | 58 | 20 | 10 | 2 |
| 176 | កែវ ម៉ាច | ស្រី | 59 | 12 | 10 | 1 |
| 177 | ប៉ាវ ឡេង | ប្រុស | 70 | 5 | 5 | 1 |
| 178 | វន មារ៉ាន់រី | ស្រី | 30 | 10 | 25 | 4 |
| 179 | វន ចន្ថា | ប្រុស | 25 | 5 | 5 | 5 |
| 180 | អ៊ុក គុណថា | ស្រី | 68 | 20 | 5 | 2 |
| 181 | រ៉ានី | ស្រី | 17 | 20 | 120 | 9 |
| 182 | គង់ ស្រីរ័ត្ន | ស្រី | 13 | 5 | 5 | 9 |
| 183 | ហេង ហាំងឈាង | ប្រុស | 14 | 10 | 30 | 9 |
| 184 | ស្រីពេជ្រ | ស្រី | 15 | 15 | 45 | 9 |
| 185 | សូ បណ្ឌិត | ប្រុស | 12 | 12 | 45 | 9 |
| 186 | ប៊ុន សាមុតជា | ប្រុស | 14 | 12 | 45 | 9 |
| 187 | រិទ្ធី | ប្រុស | 14 | 10 | 30 | 9 |
| 188 | រ៉ា ជុំរុទ្ធី | ប្រុស | 13 | 10 | 30 | 9 |
| 189 | ស្រីមុំ | ស្រី | 27 | 10 | 25 | 5 |
| 190 | អៀម សំអឿន | ស្រី | 60 | 7 | 15 | 1 |
| 191 | កែវ ខួង | ប្រុស | 30 | 6 | 25 | 2 |
| 192 | បា ផា | ស្រី | 67 | 7 | 15 | 1 |
| 193 | បូរី | ប្រុស | 21 | 15 | 65 | 5 |
| 194 | ទេព សំអុល | ប្រុស | 54 | 5 | 5 | 2 |
| 195 | លី មុី | ស្រី | 23 | 11 | 65 | 6 |
| 196 | លី សុវណ្ណរាជ | ប្រុស | 13 | 7 | 30 | 6 |
| 197 | ញ៉ែម ចាន់មុីយ៉ុង | ស្រី | 13 | 11 | 45 | 4 |
| 198 | ធួន ឡៃអី | ស្រី | 31 | 5 | 5 | 5 |
| 199 | រ៉េត បូតី | ស្រី | 10 | 1 | 5 | 2 |
| 200 | ឆេង រ៉ាខេន | ប្រុស | 20 | 5 | 5 | 5 |

តាមការចុះសាកសួរផ្ទាល់ និងប្រមូលរួមជាមួយនិងទិន្នន័យរបស់អង្គភាពស្វយ័តដឹកជញ្ជូនសាធារណៈបានផ្តល់ជូនផងដែលនោះបានឱ្យដឹងថា ប្រជាពលរដ្ឋដែលបានប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងគឺមានការកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំគួរឱ្យកត់សម្គាល់ផងដែរ។ មួយវិញទៀតអ្នកបើកបររថយន្តក្រុងក៏មានការផ្លាស់ប្តូរឥរិយាបទកាន់តែប្រសើរជាងមុន ហើយសម្រាប់ការរង់ចាំរបស់ប្រជាពលរដ្ឋក៏មានការកាត់បន្ថយជាងមុនដែរ។ ពីមុនប្រជាពលរដ្ឋត្រូវរង់ចាំរយៈពេលពី ២០-៣០ នាទីឯនោះទម្រាំតែរថយន្តក្រុងមកដល់ តែឥឡូវនេះប្រជាពលរដ្ឋរង់ចាំត្រឹមតែ ១០-២០នាទីតែប៉ុណ្ណោះ។

នៅពេលដែលដល់រដូវការបុណ្យទានធំៗម្តងៗ ដូចនៅក្នុងឆ្នាំ២០១៨ដែលកន្លងផុតថ្មីៗនេះ យើងមើលឃើញថាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុនសែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា៖ នៅក្នុងឧកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង(City Bus) រាជធានីភ្នំពេញនឹងបម្រើសេវាដឹកជញ្ជូនសាធារណៈក្នុងរាជធានីភ្នំពេញ ជូនបងប្អូនប្រជាពលរដ្ឋទាំងអស់ដោយមិនគិតកម្រៃសេវារយៈពេល៥ថ្ងៃ គឺចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១៨។

ការបែងចែកការប្រើប្រាស់រថយន្តក្រុងចំនួន ៦០គ្រឿង ដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋពីរាជធានីភ្នំពេញ ទៅតាមបណ្តាខេត្តនានាដែលមានដូចជា៖

1. តាមផ្លូវជាតិលេខ១
   - ភ្នំពេញ-ព្រៃវែង មានរថយន្តក្រុងចំនួន៥គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញ៩:០០ព្រឹក, ចេញដំណើរពីភ្នំពេញម៉ោង១៣:០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង១៦:០០ល្ងាច
   - ភ្នំពេញ-កណ្តាល-ស្វាយរៀង មានរថយន្តក្រុងចំនួន ៥គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១០:០០ព្រឹក, ចេញដំណើរពីភ្នំពេញម៉ោង១៤:០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង០៥:០០ព្រឹក
2. ផ្លូវជាតិលេខ៣
   - ភ្នំពេញ-តាកែវ-កំពត មានរថយន្តក្រុងចំនួន ៥គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង១១:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង៩:០០ព្រឹក, ចេញ

ដំណើរពីភ្នំពេញម៉ោង១១:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១៦:០០ល្ងាច

- ភ្នំពេញ-តាកែវ-កែប មានរថយន្តក្រុងចំនួន ៥គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១២:០០ថ្ងៃត្រង់, ចេញដំណើរពីភ្នំពេញម៉ោង១២:០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង១៨:០០ល្ងាច

3. ផ្លូវជាតិលេខ៤
   - ភ្នំពេញ-កំពង់ស្ពឺ មានរថយន្តក្រុងចំនួន ៣គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង៧:៣០ព្រឹក, ចេញដំណើរពីភ្នំពេញម៉ោង១០:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១២:៣០ល្ងាច, និងចេញដំណើរពីភ្នំពេញម៉ោង១៥:០០ល្ងាច និងត្រលប់មកវិញម៉ោង១៧:០០ល្ងាច
   - ភ្នំពេញ-ព្រះសីហនុ មានរថយន្តក្រុងចំនួន ៧គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១៣:០០ព្រឹក, ចេញដំណើរពីភ្នំពេញម៉ោង១៤:០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង២១:០០ល្ងាច
4. ផ្លូវជាតិលេខ៥
   - ភ្នំពេញ-កំពង់ឆ្នាំង មានរថយន្តក្រុងចំនួន ៣គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង០៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង០៩:០០ព្រឹក, ចេញដំណើរពីភ្នំពេញម៉ោង១៣:០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង១៦:០០ល្ងាច
   - ភ្នំពេញ-ពោធិ៍សាត់ មានរថយន្តក្រុងចំនួន ៥គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង០៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១២:០០ថ្ងៃត្រង់, ចេញដំណើរពីភ្នំពេញម៉ោង១២:០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង១៨:០០ល្ងាច
   - ភ្នំពេញ-បាត់ដំបង មានរថយន្តក្រុងចំនួន ៦គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង០៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១៤:០០ល្ងាច,

ចេញដំណើរពីភ្នំពេញម៉ោង១៤:០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង៥:០០ព្រឹក

- ភ្នំពេញ-បន្ទាយមានជ័យ មានរថយន្តក្រុងចំនួន ៦គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង០៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១៧:០០ល្ងាច, ចេញដំណើរពីភ្នំពេញម៉ោង១៤:០០ល្ងាច និង ត្រលប់មកភ្នំពេញវិញម៉ោង០៥:០០ព្រឹក

5. ផ្លូវជាតិលេខ៦

- ភ្នំពេញ-កំពង់ធំ មានរថយន្តក្រុងចំនួន ៥គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង0៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១២:០០ថ្ងៃត្រង់, ចេញដំណើរពីភ្នំពេញម៉ោង១៣.០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង១៩:០០ល្ងាច
- ភ្នំពេញ-សៀមរាប មានរថយន្តក្រុងចំនួន ៥គ្រឿង ដោយចេញដំណើរពីភ្នំពេញម៉ោង0៥:០០ព្រឹក និងត្រលប់មកភ្នំពេញវិញម៉ោង១៥:០០ពីល្ងាច, ចេញដំណើរពីភ្នំពេញម៉ោង១៥:០០ល្ងាច និងត្រលប់មកភ្នំពេញវិញម៉ោង០៥:០០ព្រឹក

គម្រោងនេះបានដំណើរការទៅដោយជោគជ័យ ដែលផ្ដល់នូវសេវាកម្មឡានក្រុងដោយឥតគិតថ្លៃ ដោយដឹកមនុស្សចំនួន ១៤,០០០ នាក់ ទៅកាន់ស្រុកកំណើត និងត្រឡប់មកវិញនៅក្នុងឧកាសបុណ្យចូលឆ្នាំថ្មី។ ក្រោយមកនាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានប្រកាសក្នុងកិច្ចប្រជុំជាមួយនឹងតំណាងមកពីសហជីព និងសមាគមអប់រំ រួមជាសកម្មជនគណបក្សប្រជាជន នៅមជ្ឈមណ្ឌលកោះពេជ្រ សម្ដេចបានប្រកាសថារថយន្តក្រុងសាធារណៈចំនួន ២០០គ្រឿងនឹងត្រូវផ្ដល់ឱ្យប្រជាជនប្រើប្រាស់ដោយឥតគិតថ្លៃនៅក្នុងឧកាសបុណ្យភ្ជុំបិណ្ឌនៅក្នុងខែតុលាខាងមុខនេះ។

### ២.២.២ គុណសម្បត្តិ និង គុណវិបត្តិ

យើងបានស្គាល់ពីរបៀបប្រើប្រាស់សេវារថយន្តក្រុងសាធារណៈ និងនីតិវិធីផ្សេងៗទៀតដូចជា ការប្រើប្រាស់ App តាមទូរស័ព្ទដៃ សណ្ដាប់ធ្នាប់មុនពេលធ្វើដំណើរ និងកំពុងពេលធ្វើដំណើរព្រមទាំងរយៈពេលនៃការរង់ចាំរួចហើយនោះយើងសង្កេតឃើញថា មានមនុស្សជាច្រើនក្នុងរាជធានីភ្នំពេញមានការពេញចិត្ត និងសេវាមួយនេះខ្លាំងណាស់ ព្រោះពួកគាត់គិតថាវាជាចំណែកមួយក្នុងការជួយឱ្យទីក្រុងយើងមើលទៅមានសណ្ដាប់ធ្នាប់ និងមានសោភ័ណភាព។ ទោះជាយ៉ាងនេះក្ដី

គ្រប់សេវាកម្មទាំងអស់តែងតែផ្តល់នូវគុណសម្បត្តិនិងគុណវិបត្តិផងដែរ ដូចគ្នានេះដែលសេវារថយន្តក្រុងសាធារណៈក៏មានគុណសម្បត្តិនិងគុណវិបត្តិមួយចំនួនផងដែរដូចជា៖

**២.២.២.១ គុណសម្បត្តិ**

- ជួយសម្រួលដល់ប្រជាជនមួយចំនួនឱ្យមានភាពងាយស្រួលក្នុងការធ្វើដំណើរ និង ចំណាយថវិកាអស់តិចក្នុងការធ្វើដំណើរ
- ជួយកាត់បន្ថយការប្រើប្រាស់យានយន្តច្រើននៅតាមដងផ្លូវដែលជាហេតុបង្កឱ្យមានការកកស្ទះចរាចរណ៍ និង គ្រោះថ្នាក់ចរាចរណ៍
- ជួយកាត់បន្ថយការឡើងកំដៅ និង ការបំពុលបរិស្ថាន ដែលបង្កឡើងដោយឧស្ម័នដែលចេញពីយានយន្ត និង ទោចក្រយានយន្ត
- ធ្វើឱ្យមានសោភណ័ភាពល្អនៅក្នុងរាជធានីភ្នំពេញ
- គ្មានការរំខានពីសំលេងដែលបង្កដោយយានយន្ត
- ធ្វើឱ្យមនុស្សអាចបង្ហាញពីសុជីវធម៌របស់ខ្លួនដែលមានទៅកាន់អ្នកដ៏ទៃសម្រាប់ទុកធ្វើជាគំរូដល់អ្នកផ្សេងទៀត
- បង្ហាញឱ្យអន្តរជាតិបានដឹងពីភាពរីកចម្រើននៃសេវាកម្មសាធារណៈនៅក្នុងប្រទេស
- មាតាបិតានៃសិស្សមួយចំនួនទទួលបានទំនុបចិត្ត និង ចំណេញពេលវេលាក្នុងការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀតដោយពួកគាត់មិនចាំបាច់បារម្ភពីសុវត្ថិភាពកូនរបស់ពួកគាត់
- ធ្វើឱ្យប្រជាពលរដ្ឋផ្លាស់ប្តូរឥរិយាបថ និង គោរពពេលវេលាបានប្រសើរជាងមុន
- ជួយកាត់បន្ថយការចំណាយពេលធ្វើដំណើររបស់ប្រជាពលរដ្ឋ។

**២.២.២.២ គុណវិបត្តិ**

- ត្រូវចំណាយពេលវេលាយូរក្នុងការរង់ចាំ ដោយសាតែមានយានយន្តច្រើនកំពុងតែចរាចរណ៍នៅតាមដងផ្លូវ
- អាចធ្វើឱ្យបាត់បង់ការងារមួយចំនួនរបស់ប្រជាពលរដ្ឋក្នុងការស្វែររកថវិកាដើម្បីផ្គត់ផ្គង់ជីវភាពដូចជា អ្នករត់ម៉ូតូឌុប កង់បី រម៉ក ជាដើម
- គ្មានការចូលរួមពីម្ចាស់កម្មសិទ្ធិក្នុងការដាក់ចំណតរង់ចាំ
  ឧទាហរណ៍ ការចោលកាក់សំណល់នៅកន្លែងចំណតរថយន្តក្រុងសាធារណៈឬ ការចតយានយន្តដោយគ្មានសណ្តាប់ធ្នាប់នៅកន្លែងចំណត។

## ២.៣ បញ្ហាប្រឈម និងដំណោះស្រាយ

ជាការពិតណាស់គ្រប់សេវាសាធារណៈដែលបង្កើតឡើងទាំងអស់សុទ្ធតែមានបញ្ហាប្រឈម ជានិច្ច តែអ្វីដែលសំខាន់នោះ គឺត្រូវរកដំណោះស្រាយបញ្ហាទាំងនោះដោយវិធីណា។ ខាងក្រោម នេះគឺជាបញ្ហាដែលបានកើតមានឡើងនៅក្នុងសេវាសាធារណៈរថយន្តក្រុងដែលទើបនិងបង្កើតឱ្យ មានឡើង និងដាក់ឱ្យប្រជាពលរដ្ឋបានប្រើប្រាស់ រួមជាមួយនឹងដំណោះស្រាយដែលត្រូវដោះ ស្រាយក្នុងបញ្ហាទាំងនោះផងដែរ។

### ២.៣.១ បញ្ហាប្រឈម

យើងបានដឹងពីអត្ថប្រយោជន៍ជាច្រើននៃសេវារថយន្តក្រុងសាធារណៈ និងកំណើតអ្នកប្រើ ប្រាស់នៃសេវាកម្មរួចមកហើយ យើងឃើញថាមានភាពល្អប្រសើរច្រើន ព្រោះប្រជាពលរដ្ឋដែលមក ចាប់យកសេវាកម្មនេះបានសម្តែងការពេញចិត្ត និងភាពសប្បាយរីករាយរបស់ពួកគេ ហើយថែម ទាំងចង់ឱ្យសេវាមួយនេះមានភាពរីកដុះដាលជាច្រើនកន្លែង និងសំបូរបែបទៀតផង។ ថ្វីត្បិតតែ ប្រជាពលរដ្ឋពេញចិត្តនូវសេវាដឹកជញ្ជូនសាធារណៈនេះជាច្រើនក៏ដោយ ក៏នៅតែមានបញ្ហាចោទ មួយចំនួន ដែលសម្រាប់ពួកគាត់ ហើយបញ្ហាទាំងអស់នោះមានដូចជា៖

- ពួកគាត់បានចំណាយពេលសម្រាប់រង់ចាំនៅក្នុងចំណតរង់ចាំនីមួយៗដោយប្រើរយៈពេល យូរទម្រាំតែរថយន្តក្រុងមកដល់ចំណតម៉្យាងទៀតក្នុងស្លាកនៃចំណតនីមួយៗបានបញ្ជាក់ ថាការរង់ចាំត្រឹមតែ ១០-១៥នាទីតែប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែងពេលខ្លះគឺរថយន្តក្រុងមកដល់ ចំណតក្នុងអំឡុងពេលដែលពួកគាត់រង់ចាំរហូតដល់២០-៣០នាទីឯនោះ។
- ការដឹងពីចំណតឬខ្សែណាមួយគឺអ្នកដំណើរមានភាពពិបាក ដោយពួកគាត់គឺត្រូវទៅសួរអ្នក ដំណើរដូចគ្នា ដែលគាត់ធ្លាប់បានធ្វើដំណើរច្រើនខ្សែកន្លងមកហើយដែរ។
- អ្នកបើកបរមិនបានដឹងពីខ្សែរថយន្តក្រុងឯទៀតឱ្យបានលំអិតនោះទេគឺពួកគាត់ដឹងតែខ្សែ ដែលពួកគាត់បានដឹកអ្នកដំណើរទេ ដូច្នេះអ្នកដំណើរពិបាកនឹងរកខ្សែបន្តទៀតដែលពួក គាត់ចង់ធ្វើដំណើរ។
- សម្រាប់អត្តចរិត និងអាកប្បកិរិយារបស់អ្នកបើកបរ ឬជំនួយការរបស់អ្នកបើកបរ (អ្នកលក់ សំបុត្រ) ពួកគាត់បានប្រើពាក្យសម្តីមិនសមរម្យទៅកាន់អតិថិជនដែលកំពុងតែប្រើប្រាស់ សេវាដឹកជញ្ជូនរថយន្តសាធារណៈនេះ។ ជួនកាលមានការខាកស្តោះដោយគ្មានសណ្តាប់ ធ្នាប់ ដែលធ្វើឱ្យផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្ត ក្រុង។
- គម្លាតនៃការរង់ចាំពីចំណុចមួយទៅចំណុចមួយមានចម្ងាយឆ្ងាយពេក។

- នៅក្នុងចំណតរង់ចាំ មានកន្លែងខ្លះមិនមានកន្លែងសម្រាប់អតិថិជនអង្គុយរង់ចាំនោះទេ។
- ជួនកាលពួកគាត់ខំឈររង់ចាំប៉ុន្តែនៅពេលដែលឡានមកដល់ចំណតហើយបែរជាមិនព្រមឈប់ឱ្យអ្នកដំណើរឡើង។
- ដោយសារតែឡានក្រុងនៅមានចំនួនតិចដូច្នេះធ្វើឱ្យការរង់ចាំរបស់អ្នកដំណើរនៅតាមចំណតមានរយៈពេលយូរ។
- ប្រជាពលរដ្ឋមួយចំនួនបានលើកឡើងថា ការមកដល់របស់រថយន្តក្រុងគឺមិនបានស្របតាមរយៈពេលដែលស្លាកនៅចំណតបានបង្ហាញនោះទេ ជាពិសេសគឺនៅចន្លោះម៉ោង១២-១ថ្ងៃត្រង់ ការរង់ចាំគឺមានរយៈពេលយូរណាស់ទម្រាំតែរថយន្តក្រុងមកដល់ជួនកាលពួកគាត់ត្រូវចាំរហូតទៅដល់៣០នាទីឯនោះ។
- នៅក្នុងចំណតរង់ចាំ មិនមានភ្លើងបំភ្លឺនៅពេលយប់នោះទេ វាជាហេតុបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកដែលប្រើប្រាស់សេវាកម្មនេះនៅពេលយប់ ពីព្រោះថារថយន្តក្រុងសាធារណៈត្រូវបានដឹកអ្នកដំណើររហូតដល់ម៉ោង៨:៣០យប់ឯនោះ។
- នៅក្នុងចំណតមួយចំនួនបានមើលឃើញថា នៅពេលដែលប្រជាពលរដ្ឋបានទៅចាំនៅចំណតនោះគឺមានការដេញចេញពីម្ចាស់ផ្ទះដែលនៅខាងមុខ ដោយពួកគាត់បាននិយាយថាឈរនៅមុខផ្ទះរញ៉េរញ៉ៃធ្វើឱ្យពួកគាត់រកស៊ីមិនបាន។

ក្រៅពីបញ្ហាដែលមានដូចខាងលើនេះហើយ ក៏មានបញ្ហាមួយចំនួនផ្សេងៗទៀតដែលយើងគ្រប់គ្នាគួរតែដឹងដូចជាបញ្ហាទៅលើដាក់ចំណតរង់ចាំ ព្រោះតែគ្មានការចូលរួមពីម្ចាស់ផ្ទះដោយពួកគាត់មិនអនុញ្ញាតឱ្យដាក់ចំណតរង់ចាំនៅមុខផ្ទះគាត់ ហេតុនេះហើយទើបមានកន្លែងខ្លះចំណតរង់ចាំមានចម្ងាយឆ្ងាយជាងគ្នាខ្លាំង។ ថវិកាក៏ជាកត្តាមួយយ៉ាងសំខាន់ដែលសម្រាប់ជំរុញឱ្យសេវាកម្មនេះមានដំណើរការល្អ ប៉ុន្តែផ្ទុយទៅវិញរដ្ឋាករដែលគ្រប់គ្រងលើសេវាកម្មនេះខ្វះថវិកានៅក្នុងដំណើរការនេះ។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋដែលនៅតាមជនបទ គាត់មិនសូវបានដឹងពីរបៀបនៃការប្រើប្រាស់ និងចំណតនៃខ្សែរថយន្តដែលបានដំណើរការនោះទេ។

**២.៣.២ ដំណោះស្រាយ**

គ្រប់សេវាសាធារណៈទាំងអស់យើងតែងតែជួបនូវបញ្ហាដែលកើតឡើងក្នុងដំណើរការ ប៉ុន្តែមិនប្រាកដថាបញ្ហាទាំងអស់នោះគ្មានដំណោះស្រាយនោះទេ។ យ៉ាងណាមិញក្នុងសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងនេះក៏នៅតែមាន បញ្ហាមួយចំនួនដូចដែលបានរៀបរាប់នៅខាងលើនេះដែរ (ក្នុងចំណុច២.៤.១) យើងក៏មានដំណោះស្រាយមួយចំនួនដើម្បីដោះស្រាយលើបញ្ហាទាំងអស់នេះ ហើយដំណោះស្រាយទាំងនោះមានដូចខាងក្រោម៖

- រដ្ឋាភិបាលគួរតែធ្វើការផ្សព្វផ្សាយនៅតាមប្រព័ន្ធផ្សេងៗដូចជា ទូរទស្សន៍ វិទ្យុ ឱ្យបានទូលំទូលាយ ដើម្បីឱ្យប្រជាពលរដ្ឋដែលរស់នៅតាមជនបទបានយល់ដឹងពីរបៀបនៃការប្រើប្រាស់សេវាមួយនេះ ហើយជាពិសេសគឺលើមនុស្សដែលមានវ័យចំណាស់ប្រហែលជាត្រឹមអាយុ៤៥-៧០ឆ្នាំ
- រដ្ឋាភិបាលគួរតែធ្វើការសម្រួលជាមួយប្រជាពលរដ្ឋក្នុងការដាក់ចំណតរង់ចាំ ដោយធ្វើយ៉ាងណាពន្យល់ឱ្យគាត់បានយល់ពីសារៈសំខាន់នៃសេវាកម្មមួយនេះ
- រដ្ឋាករគួរតែលើកយកគម្រោងកញ្ចប់ថវិកាមួយដែលសមស្របទៅតាមទំហំនៃការចំណាយទាំងនោះ
- រដ្ឋាករគួរតែធ្វើការប្រជុំជាមួយបុគ្គលិកដែលបម្រើការងារ(អ្នកបើកបរ និងជំនួយការ) របស់ខ្លួនជុំវិញបញ្ហាក្នុងការនិយាយស្តីទៅកាន់អតិថិជន និងអនុវត្តនូវបទបញ្ជាផ្ទៃក្នុងឱ្យបានទៀងទាត់។

# សេចក្តីសន្និដ្ឋាន

ក្រោយពីយើងបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទមួយស្តីពីការគ្រប់គ្រងសេវាដឹកជញ្ជូនសាធារណៈនៅរាជធានីភ្នំពេញ (រថយន្តក្រុងសាធារណៈ) រួចមកហើយនោះ យើងសង្កេតឃើញថា មានការរៀបចំ និង ការដាក់ខ្សែរត់របស់រថយន្តក្រុងសាធារណៈនៅក្នុងរាជធានីភ្នំពេញបានច្រើនប្រសើរជាងមុនណាស់ទៅហើយ។ ការបង្កើតឱ្យមានសេវាដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងបែបនេះ វាក៏ជាផ្នែកមួយក្នុងការរៀបចំទីក្រុងឱ្យមានសោភ័ណភាពល្អនៅតាមដងផ្លូវធ្វើដំណើរ ហើយជាពិសេសនោះវាបានជួយសម្រួលដល់ការចំណាយថវិកាអស់ច្រើនក្នុងពេលធ្វើដំណើររបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងទៀតផង។ ដូចគ្នានេះដែរ ប្រជាពលរដ្ឋក៏បានចូលរួមយ៉ាងសកម្មក្នុងដំណើរការនេះ ដែលជាផ្នែកមួយក្នុងការជំរុញឱ្យសេវាដឹកជញ្ជូនសាធារណៈនេះបន្តដំណើរទៅមុខបានល្អប្រសើរ ហើយជាងនេះទៅទៀតតាមរយៈសេវាដឹកជញ្ជូនសាធារណៈមួយនេះក៏បានបង្កើតឱ្យមានភាពស៊ីវិល័យ និង ទំនើប ដើម្បីបង្ហាញឱ្យភ្ញៀវជាតិនឹង អន្តរជាតិបានដឹងពីការរីកចម្រើននៃសេវាសាធារណៈនៅក្នុងប្រទេសទៀតផង។ ជាមួយគ្នានេះដែរ ការបង្កើតសេវានេះក៏បានដើរទៅតាមគោលនយោបាយរបស់រដ្ឋាភិបាល(យុទ្ធសាស្ត្រចតុកោណ) ដែលមាននាពេលបច្ចុប្បន្ននេះ។ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងគឺជាស្ថាប័នដែលមានតួនាទីក្នុងការគ្រប់គ្រង និងចាត់ចែងនៃសេវាសាធារណៈនេះបាននឹងកំពុងស្វែងរកយុទ្ធសាស្ត្រល្អៗ និង ដំណោះស្រាយមួយល្អប្រសើរ ដើម្បីពង្រីកសេវាដឹកជញ្ជូនរថយន្តក្រុងសាធារណៈមួយនេះឱ្យរីកដុះដាលពាសពេញទីក្រុង។ ដើម្បីឱ្យសេវានេះដំណើរការបានល្អ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងក៏បានធ្វើការបែងចែកតួនាទីរវាងបុគ្គលិក ដែលបម្រើការទៅតាមផ្នែកផ្សេងៗចៀសវាងមានការងារជាន់គ្នាដែលអាចបង្កឱ្យមានភាពស្មុកស្មាញក្នុងពេលដំណើរការ ហើយរាល់ការចរាចរណ៍របស់រថយន្តក្រុងសាធារណៈទាំងអស់នៅលើដងផ្លូវ គឺត្រូវតែគោរពតាមច្បាប់ចរាចរណ៍ផ្លូវគោកជានិច្ច។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋាករក៏បានសហការជាមួយដៃគូរឯកជនក្នុងការបង្កើតឱ្យមានការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗនៅលើរថយន្តក្រុងថែមទៀត។ ចំពោះការអនុវត្ត បែបនេះបានសរបញ្ជាក់ឱ្យសាធារណៈជនបានដឹងថា ប្រទេសយើងគឺមានភាពរីកចម្រើនច្រើនប្រសើរហើយ មិនត្រឹមតែប៉ុណ្ណោះតាមរយៈសេវានេះក៏បានបង្ហាញពីសុជីវធម៌ និង ការគោរពច្បាប់របស់ប្រជាជនក្នុងសង្គមទៀតផង។

ជាក់ស្តែងការបង្កើតឱ្យមានសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងបានទទួលនូវផលប្រយោជន៍ជាច្រើនជូនទៅប្រជាជន និងសម្រាប់ប្រទេសជាតិ ក្នុងការអភិវឌ្ឍន៍លើវិស័យសេវាសាធារណៈពិតប្រាកដមែន។ ប៉ុន្តែទោះបីជាមានផលប្រយោជន៍ច្រើនក៏ដោយ ក៏នៅតែមានផល

អវិជ្ជមានខ្លះដល់ប្រជាពលរដ្ឋមួយចំនួនដែលប្រកបរបរជាអ្នក រត់ម៉ូតូឌុប រម៉កជាដើម។ ជាងនេះទៅទៀតពួកគាត់អាចនិងខាតបង់ពេលវេលាច្រើនក្នុងការអង្គុយរង់ចាំឡាន ដោយសាតែមានយានយន្តច្រើននៅតាមដងផ្លូវ ពិសេសនោះមានប្រជាពលរដ្ឋមួយចំនួនគាត់មិនបានចូលរួមក្នុងការអភិវឌ្ឍន៍លើវិស័យមួយនេះប៉ុន្មានទេ។

ទោះបីជាយ៉ាងណាក៏ដោយ ការប៉ះពាល់បន្តិចបន្តួចក្នុងការអភិវឌ្ឍន៍លើវិស័យដឹកជញ្ជូនសាធារណៈនេះ ក៏មិនអាចបង្អាក់ដល់ដំណើរការនេះបានដែរ ព្រោះថាជាធម្មតារាល់ការបង្កើតដំបូងរបស់សេវាសាធារណៈទាំងអស់តែងតែមានផលអវិជ្ជមានខ្លះៗសម្រាប់ប្រជាជន។ ទោះបីជាយ៉ាងនេះក្តីក៏រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងនៅតែខិតខំស្វែងរកមធ្យោបាយផ្សេងទៀតដើម្បីដោះស្រាយលើបញ្ហាដែលកើតមានឡើងទាំងអស់នោះ។

សរុបមក តាមរយៈសេវាមួយនេះពិតជាមានផលប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋ និងសង្គមជាតិពិតមែន ពិសេសនោះគឺវាបានធ្វើឱ្យទីក្រុងរបស់ប្រទេសយើងមានសោភ័ណភាពល្អ នឹងសណ្តាប់ធ្នាប់ល្អ។ លើសពីនេះទៅទៀត រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងក៏បានធ្វើការដោះស្រាយលើបញ្ហាដែលកើតមានមួយចំនួននោះរួចជាស្រេចដែលហើយ។

# អនុសាសន៍

ដោយយោងទៅតាមការស្រាវជ្រាវនៅលើប្រធានបទមួយនេះ ក្រុមរបស់នាងខ្ញុំបានធ្វើការស្រាវជ្រាវពីឯកសារនានានៅក្នុងប្រព័ន្ធផ្សព្វផ្សាយ រួមជាមួយនឹងការចុះទៅសម្ភាសផ្ទាល់ជុំវិញបញ្ហានេះនៅក្នុងអង្គភាពដែលទទួលខុសត្រូវលើសេវានេះ នៅតាមចំណតនានា និងប្រជាពលរដ្ឋដែលបានជ្រើសរើសនូវសេវាសាធារណៈរថយន្តក្រុង។ ក្នុងប្រធានបទនេះ ក្រុមរបស់នាងខ្ញុំបានធ្វើការសិក្សាយ៉ាងលម្អិតទៅលើមូលហេតុនៃការបង្កើតសេវាដឹកជញ្ជូនសាធារណៈមួយនេះទៅលើ របៀបនៃការប្រើប្រាស់សេវាកម្ម ហើយនឹងអត្ថប្រយោជន៍ដែលប្រជាពលរដ្ឋទទួលបាន ពិសេសផលចំណេញជាច្រើននៅពេលដែលបានប្រើប្រាស់សេវាសាធារណៈនេះ។ ដោយយោងទៅតាមលទ្ធផលនៃការស្រាវជ្រាវខាងលើនេះ ឃើញថាមានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋបានច្រើនគួរសមណាស់ហើយ ប៉ុន្តែទោះជាយ៉ាងណាក៏នៅមានចំណុចខ្វះចន្លោះតិចតួចផងដែរ ហើយដើម្បីឱ្យសេវានេះកាន់តែប្រសើរជាងនេះទៅទៀតយើងខ្ញុំក៏មានជាយោបល់បន្តិចបន្តួចក្នុងការបម្រើសេវាសាធារណៈនេះដូចខាងក្រោម៖

- រដ្ឋាភិបាលគួរតែបង្កើតឱ្យមានខ្សែរត់ទៅតាមបណ្តាលខេត្តផ្សេងៗ និងពីខេត្តមួយទៅខេត្តដោយតភ្ជាប់មកក្នុងរាជធានីភ្នំពេញ
- រដ្ឋាករគួរតែពង្រីកសេវានេះឱ្យកាន់តែច្រើនឡើងៗ និងមានភាពទូលំទូលាយពាស់ពេញរាជធានីភ្នំពេញ ដើម្បីបំពេញតាមតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងបន្ថែមរថយន្តលើខ្សែរត់ដែលមានសព្វថ្ងៃឱ្យកាន់តែច្រើនដើម្បីជួយបន្ថយនូវគំលាតនៃការរង់ចាំ
- រដ្ឋាករគួរតែចុះត្រួតពិនិត្យនៅតាមចំណតរៀងរាល់ ១ ឬ ២ សប្តាហ៍ម្តងដោយត្រូវត្រួតពិនិត្យលើក្តារព័ត៌មាន បរិស្ថានជុំវិញកន្លែងរង់ចាំ និងធ្វើការសំអាតនៅកន្លែងរង់ចាំនោះឱ្យបានស្អាត ព្រោះថាបើយើងធ្វើជាគំរូល្អក្នុងការថែរក្សាបរិស្ថាននៅបរិវេណកន្លែងរង់ចាំនោះអតិថិជននិងធ្វើតាមយើងដើម្បីថែរក្សាបរិស្ថាននៅកន្លែងរង់ចាំនោះផងដែរ
- សូមឱ្យប្រជាពលរដ្ឋទាំងអស់ចូលរួមសហការក្នុងការថែរក្សាបរិស្ថាន សណ្តាប់ធ្នាប់ ពេលប្រើប្រាស់សេវាសាធារណៈ និងចូលរួមសហការក្នុងការដាក់ចំណតរង់ចាំឱ្យបានគ្រប់ៗគ្នា។

# ឯកសារយោង


- **លិខិតបទដ្ឋានគតិយុត្តិនានា**
  - ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០០៧
  - អនុក្រិតលេខ៣០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុ និង ការប្រព្រឹត្តិទៅនៃរដ្ឋាករខេត្ត
  - លិខិតលេខ ១៦៧៣ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ
- **សៀវភៅ**
  - សៀវភៅយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា
- **វចនានុក្រម**
  - វចនានុក្រមខ្មែរពស.២៥៥៥ គស.២០១១
  - វចនានុក្រមខ្មែរពស.២៥១១ គស.១៩៦៧
- Internet
  - https://HMS-Funtion.com
  - https://History of rail transport
  - https://en.wikipedia.org/wiki/car.History-of-the-car
  - https://en.wikipedia.org/wiki/John_Greennood_(bus_operator)
  - https://en.wikipedia.org/wiki/public_transport_bus_service
  - https://en.wikipedia.org/wiki
  - https://en.wikipedia.org/wiki/Beijingbus
  - https://www.jrailpass.com/wiki/JH_Bus
  - https://en.wikipedia.org/wiki/Bus_transport_in_the_local_bus
  - https://en.wikipedia.org/wiki/Bus_transport_in_singapore
  - https://khmer.cambodiacity.com
  - https://autfbodia.com
  - www.wingmoney.com
  - New.sabay.com.kh/article
  - www.phnompenhcitybus.gov.kh

# តារាងបញ្ជីឧបសម្ព័ន្ធ

| លរ. | ឈ្មោះ |
|---|---|
| | **ឧបសម្ព័ន្ធ ១ លិខិតបទដ្ឋានគតិយុត្តិនានា** |
| ១ | អនុក្រឹតលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុ និងការប្រព្រឹត្តនៃរដ្ឋាកររបស់ខេត្ត ក្រុង |
| ២ | លិខិតលេខ ១៦៧៣ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ |
| ៣ | លិខិតលេខ ៣៥៩១ ហសវ.អទច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៤ | លិខិតលេខ ៧៩៤ សជណ.ផក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ស្តីពីឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីជម្រាបជូនឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ |
| ៥ | សេចក្តីសម្រេចលេខ ៣២៣ សសរ.ផរិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus ) រាជធានីភ្នំពេញ |
| ៦ | សេចក្តីសម្រេចលេខ ៣២៤ សសរ.ផរិ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការតែងតាំងអភិបាល និងអភិបាលរងរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus ) រាជធានីភ្នំពេញ |
| ៧ | សេចក្តីសម្រេចលេខ ៣២៥ សសរ.ផរិ ចុះថ្ងៃទី២០ ខែសីហា ឆ្នា២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការអាជីវកម្មរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus ) រាជធានីភ្នំពេញ |
| ៨ | សេចក្តីសម្រេចលេខ ៣៣៦ សសរ.ផរិ ចុំថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការតែងតាំងប្រធានការិយាល័យចំណុះរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus ) រាជធានីភ្នំពេញ |

| | |
|---|---|
| **៩** | ដីកាលេខ ១១០/១៦ ដក.តត.ធ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការសម្រួលភារកិច្ច និង ប្រគល់ភារកិច្ចបន្ថែមជូនមន្ត្រីរាជការ |
| **១០** | ដីកាលេខ ០៤ ដក.ផវិ.ក្របរ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus) រាជធានីភ្នំពេញ |
| **១១** | កំណត់បែងចែកលេខ ១០៧ ក.ប.ភ រដស ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ស្តីពីភារកិច្ច និងការទទួលខុសត្រូវថ្នាក់ដឹកនាំ និងការិយាល័យនីមួយៗរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ |
| **១២** | កំណត់បែងចែកលេខ ១០៨ ក.ប.ភ រ.ដ.ស ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ស្តីពីភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកបម្រើសេវារបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង |
| **១៣** | បទបញ្ជាផ្ទៃក្នុងលេខ ១០៦ បប.រ.ដ.ស ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង |
| **១៤** | បទបញ្ញត្តិសម្រាប់អ្នកធ្វើដំណើរលេខ ១០៥ បប.រដស ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ |
| **១៥** | សេចក្តីជូនដំណឹងលេខ ០១០/១៨ សជណ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការគេហទំព័រ (Website ) របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus ) រាជធានីភ្នំពេញ |
| **១៦** | សេចក្តីជូនដំណឹងចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ |
| **១៧** | សេចក្តីជូនដំណឹងលេខ ០៥០/១៧ សជណ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ |
| **១៨** | សេចជូនដំណឹងលេខ ០២០/១៨ សជណ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ |
| **១៩** | សេចជូនដំណឹងលេខ ពិសេស ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ |
| **ឧបសម្ព័ន្ធ ២ រូបភាព** | |
| **២០** | កាតពណ៌បៃតង |
| **២១** | កាតពណ៌ខៀវ |
| **២២** | ប្រភេទឡានក្រុង |
| **២៣** | ផែនទីតម្រាយផ្លូវឆ្នាំ ២០១៤<br>• ផែនទីតម្រាយផ្លូវខ្សែរត់ទី ១ (A) |

| | |
|---|---|
| | • ផែនទីតម្រាយផ្លូវខ្សែរត់ទី ២ (B)<br>• ផែទីតម្រាយផ្លូវខ្សែរត់ទី ៣ (C) |
| ២៤ | ផែនទីតម្រាយផ្លូវឆ្នាំ ២០១៧<br>• ផែនទីតម្រាយផ្លូវរថយន្តក្រុងដំណាក់កាលទី ១ ឆ្នាំ ២០១៧<br>• ផែនទីតម្រាយផ្លូវរត់របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ<br>• ផែនទីខ្សែរត់ទី ១<br>• ផែនទីខ្សែរត់ទី២<br>• ផែនទីខ្សែរត់ទី ៣<br>• ផែនទីខ្សែរត់ទី ៤<br>• ផែនទីខ្សែរត់ទី ៥<br>• ផែនទីខ្សែរត់ទី ៦<br>• ផែនទីខ្សែរត់ទី ៧<br>• ផែនទីខ្សែរត់ទី ៨ |

# ឧបសម្ព័ន្ធ ១
# លិខិតបទដ្ឋានគតិយុត្តិ
# នានា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី ២៣ ខែ ៣ ឆ្នាំ ២០១០

ឆ្នាំទី ៧ លេខ ១៤ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៩

# រាជកិច្ច

ថតចម្លង
បណ្ណសារដ្ឋានជាតិ

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

ប្រកាសលុបចោលដីកា លិខិតបទដ្ឋាន ឬ បញ្ឈប់សកម្មភាពនោះជាបន្ទាន់ ហើយចាត់វិធានការណែនាំអោយបានត្រឹមត្រូវឡើងវិញ ។

មាត្រា ៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត ក្រុងត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

***

## អនុក្រឹត្យលេខ ៣០ អនក្រ.បក
## ស្តីពីរបបរដ្ឋបាល ហិរញ្ញវត្ថុ និង ការប្រព្រឹត្តិ
## នៅខែដំបូងរបស់ខេត្ត ក្រុង

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- យោងតាមសំណើរបស់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ
### សំរេច

**មាត្រា ១ .** អនុលោមទៅតាមមាត្រា ២៥ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ ការធ្វើអាជីវកម្មផ្ទាល់នៃសេវាសាធារណៈរបស់ខេត្ត ក្រុង ក្រោមរូបភាពជារដ្ឋាករ ត្រូវស្នើឡើងដោយអភិបាល ខេត្ត ក្រុង ។ ការស្នើនេះត្រូវស្ថិតនៅក្រោមការអនុញ្ញាតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ការអនុញ្ញាត ឬ ការដកហូតការអនុញ្ញាត ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២ .** ក្នុងករណីរដ្ឋាករមិនទាន់មានស្វយ័តភាព ចំណូល និង ចំណាយរបស់រដ្ឋាករ ត្រូវកត់ត្រានៅក្នុងថវិការបស់ខេត្ត ក្រុង ។ គណនេយ្យកររបស់ខេត្ត ក្រុង ត្រូវចុះកិច្ចបញ្ជីការគណនេយ្យនូវចំណូល និងចំណាយរបស់រដ្ឋាករ ដោយអនុលោមទៅតាមបទបញ្ញាជាធរមាន នៅក្នុងគណនេយ្យរបស់ខេត្ត ក្រុង ។

**មាត្រា ៣ .** ក្នុងករណីសេវាសាធារណៈរបស់ខេត្ត ក្រុង ត្រូវបានអនុញ្ញាតអោយធ្វើអាជីវកម្មជារដ្ឋាករមានស្វយ័តភាព របបរដ្ឋបាលនិងហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅនៃរដ្ឋាករស្វយ័តទាំងនោះ ត្រូវគោរពទៅតាមបទបញ្ញត្តិនានានៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## របបរដ្ឋបាលនៃរដ្ឋាករបស់ខេត្ត ក្រុង

**មាត្រា ៤ .** រដ្ឋាកររបស់ខេត្ត ក្រុង ត្រូវគ្រប់គ្រងដោយគណកម្មាធិការអាជីវកម្មមួយ ដែលដឹកនាំអភិបាលខេត្ត ក្រុង ឬ អភិបាលរងម្នាក់ និង មានសមាសភាពដទៃទៀតដូចតទៅ ៖

- អភិបាលរដ្ឋាករម្នាក់ ជួយអភិបាលខេត្ត ក្រុង ក្នុងការគ្រប់គ្រងរដ្ឋាករ ហើយអភិបាលរដ្ឋាករនេះត្រូវបានតែងតាំងដោយអភិបាលខេត្ត ក្រុង ក្នុងចំណោមភ្នាក់ងាររបស់ខេត្ត ក្រុង ។
- មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខេត្ត ក្រុង
- ប្រធានការិយាល័យខេត្ត ក្រុងម្នាក់ ឬ ច្រើននាក់ នៃផ្នែកដែលមានទំនាក់ទំនងការងារជាមួយរដ្ឋាករ ។
- ប្រជាពលរដ្ឋពីរនាក់ ដែលជ្រើសរើសដោយអភិបាលខេត្ត ក្រុង ពីចំណោមអ្នកប្រើប្រាស់ដែលជានីតិជន មានភាពស្មោះត្រង់ត្រឹមត្រូវ និង ជាប្រជាពលរដ្ឋល្អ ដឹងខុសដឹងត្រូវ ។
- សមាជិកនៃគណៈកម្មាធិការអាជីវកម្ម ត្រូវបានចាត់តាំងដោយដីការបស់ខេត្ត ក្រុង។សមាជិកនៃគណៈកម្មាធិការអាជីវកម្មមិនអាចជាសហគ្រិន ឬ ជាអ្នកផ្គត់ផ្គង់នៃសេវាណាមួយ ឬចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនណាមួយ ដែលមានទំនាក់ទំនងការងារជាមួយរដ្ឋាករឡើយ ។

អ្នកដែលត្រូវជ្រើសរើសនិងបញ្ចប់ទាំងនេះ ត្រូវបានប្រកាសដោយផ្អែកលើសំណើរបស់គណៈ កម្មាធិការអាជីវកម្ម ដោយអភិបាលខេត្ត-ក្រុង ។

មាត្រា ៥ .- គណៈកម្មាធិការអាជីវកម្ម ត្រូវធ្វើការប្រជុំតាមការអញ្ជើញរបស់អភិបាលខេត្ត ក្រុង ឬ អភិបាលរងតាមការចាត់តាំង យ៉ាងតិចមួយលើកក្នុងមួយត្រីមាស និង ត្រូវមានសំណេរកំណត់ហេតុរាល់លើក នៃការ ប្រជុំនេះ ។

គណៈកម្មាធិការអាជីវកម្មនេះ ត្រូវពិគ្រោះយោបល់គ្នាលើគោលនៃប្រតិបត្តិកិច្ចការណ៍ដែលស្ថិត នៅក្នុងសកម្មភាពរបស់រដ្ឋាករ ដែលមានជាអាទិ៍ដូចតទៅ ៖

- ទេយ្យទានដំបូងដែលខេត្ត ក្រុង ផ្តល់សំរាប់ការរៀបចំរដ្ឋាករ និង ការកែប្រែជាយថាហេតុ ដែលកើតមានចំពោះទេយ្យទាននេះ ។
- ការវិនិយោគផ្ទាល់ ការលក់ការវិនិយោគទាំងនេះ មិនត្រូវបានហាមឃាត់ដោយច្បាប់ និងបទ បញ្ញត្តិជាធរមានទេ ។
- ថវិកា និង គណនីរបស់រដ្ឋាករ ។
- លទ្ធកម្មកិច្ចសន្យា កិច្ចសន្យាជួល ពាណិជ្ជកម្ម និង រឿងក្តីជាយថាហេតុ ។
- វិធានការដែលត្រូវរៀបចំនៅក្នុងពេលកំពុងអនុវត្ត ឬ នៅពេលបញ្ចប់ បន្ទាប់ពីមានការបញ្ឈប់សកម្មភាព អាជីវកម្មរបស់រដ្ឋាករ ។ វិធានការទាំងនេះ អាចអនុវត្តបានបន្ទាប់ពីមានការយល់ព្រមពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ ។

មាត្រា ៦ .- អភិបាលនៃរដ្ឋាករ ត្រូវធានាអោយការប្រព្រឹត្តទៅរបស់រដ្ឋាករមានដំណើរការល្អ និង ទទួលបន្ទុក ជាអាទិ៍ ៖

- រៀបចំការងាររបស់គណៈកម្មាធិការអាជីវកម្ម និង ទទួលភារៈជាមុខងារជាលេខាធិការនៃការ ប្រជុំនានា ។
- រៀបចំគំរោងថវិការបស់រដ្ឋាករ តាមការផ្តល់សិទ្ធិរបស់អភិបាលខេត្ត ក្រុង និង ជាអាណាប័កផ្ទេរ សិទ្ធិនៃថវិការបស់រដ្ឋាករ ។
- តាមដានសកម្មភាពរបស់រដ្ឋាករប្រចាំថ្ងៃ និង រាយការណ៍អំពីសកម្មភាពនេះជូនអភិបាលខេត្ត ក្រុង ។

## ជំពូកទី ៣

## របបហិរញ្ញវត្ថុនៃរដ្ឋាកររបស់ខេត្ត ក្រុង

មាត្រា ៧ .- ដីការបស់អភិបាលខេត្ត-ក្រុង ស្តីពីការបង្កើតរដ្ឋាករ ត្រូវកំណត់នូវចំនួនទឹកប្រាក់ដែលខេត្ត ក្រុង ត្រូវផ្តល់នូវទេយ្យទានដំបូងសំរាប់ការរៀបចំរដ្ឋាករ ។ ទេយ្យទាននេះ អាចបង្កើនឡើង ឬ បន្ថយចុះ តំរូវការរបស់សេវាដោយដីការបស់អភិបាលខេត្ត ក្រុង បន្ទាប់ពីមានយោបល់ឯកភាពរបស់គណៈកម្មា ធិការ ។

ថតចម្លង
បណ្ណសារជាតិ

ការបង្កើនទាយជ្ជទាន គឺជាការលើកតំលៃទាននៅក្នុងថវិការបស់ខេត្ត ក្រុង ហើយការបន្ថយទាយជ្ជទាន គឺជាការបង់តំណូលដោយរដ្ឋាករក្នុងថវិការបស់ខេត្ត ក្រុង ។

មាត្រា ៨.– គំរោងចំណូល និង ចំណាយថវិកាប្រចាំឆ្នាំរបស់រដ្ឋាករ ត្រូវរៀបចំដោយអភិបាលនៃរដ្ឋាករ តាមយោបល់របស់គណៈកម្មាធិការអាជីវកម្ម និង សំរេចដោយអភិបាលខេត្ត ក្រុង ។ អភិបាលខេត្ត ក្រុង ត្រូវបញ្ជូនគំរោងថវិកានេះ ទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការពិនិត្យសំរេច ស្របពេលជាមួយគ្នានឹងគំរោងថវិការបស់ខេត្ត ក្រុង និង ចំលងមួយច្បាប់ទៅក្រសួងមហាផ្ទៃ ។

ពេលវេលានៃការរៀបចំគំរោងថវិការបស់រដ្ឋាករ ដូចគ្នានឹងពេលវេលានៃការរៀបចំគំរោងថវិការបស់ខេត្ត ក្រុងដែរ ។

ថវិការបស់រដ្ឋាករ ត្រូវបានកែសំរួលនៅក្នុងឆ្នាំកំពុងអនុវត្ត និងត្រូវបានទូទាត់នៅដំណាច់ឆ្នាំដូចថវិការបស់ខេត្ត ក្រុងដែរ ។

មាត្រា ៩.– ថវិការបស់រដ្ឋាករ ត្រូវបង្ហាញនូវចរាចរសម្ព័ន្ធបំពេញ ដែលចែកជាពីរផ្នែកដូចខាងក្រោម ៖

ផ្នែកទី១ ៖ ចំណូល និង ចំណាយអាជីវកម្ម

ចំណូល ៖

- ផលនៃអាជីវកម្ម
- ការកាត់ទុកមុនលើមូលនិធិបំរុង
- ផលផ្សេងៗ និង មិនបានគ្រោងទុក

ចំណាយ ៖

- សោហ៊ុយអាជីវកម្ម និង ថែទាំ
- ប្រាក់បៀវត្ស និង ប្រាក់បំណាច់បុគ្គលិករបស់រដ្ឋាករផ្ទាល់
- ប្រាក់ឈ្នួល និង សោហ៊ុយបន្ទាប់បន្សំនៃធនធានវត្ថុ ដែលបានប្រគល់អោយរដ្ឋាករ ។
- ពន្ធ និង អាករគ្រប់ប្រភេទដែលរដ្ឋាករត្រូវបង់
- ចំណាយផ្សេងៗ ។

ផ្នែកទី២ ៖ ចំណូល និង ចំណាយនៃការអភិវឌ្ឍន៍

ចំណូល ៖

- ទាយជ្ជទាននៃការរៀបចំដំបូង
- ការកាត់ទុកមុនលើមូលនិធិបំរុង
- ធនធានផ្សេងៗទៀតសំរាប់ការវិនិយោគ ។

ចំណាយ ៖

- ចំណាយសំរាប់ការអភិវឌ្ឍន៍បេឡកម្ម
+ ការសាងសង់
+ សំភារៈបរិក្ខា
- ការបង្កើនមូលនិធិចលាចល ។

ថតចម្លង
បណ្ណសារដ្ឋានជាតិ

មាត្រា ១០ ._ អតិរេកសុទ្ធចំណេញនៃចំណូល លើចំណាយនៃផ្នែកទី ១ របស់រោងការដែលមាននៅចុងឆ្នាំនៃការគ្រប់គ្រងនិមួយៗ ត្រូវផ្ទេរទៅគណនីមួយមានឈ្មោះថា " មូលនិធិបំរុង " ដែលបើកនៅក្នុងរតនាគារខេត្ត ក្រុង ។

មូលនិធិបំរុងអាចប្រើប្រាស់បាន ដូចជាត្រូវបង្កើតមូលនិធិកលើការរោងការ ឬ ត្រូវធ្វើហិរញ្ញប្បទានសំរាប់ការអភិវឌ្ឍផ្នែកទី ២ របស់រោងការ ។ ចំនួនប្រាក់ដែលនៅសល់មិនប្រើប្រាស់នៃមូលនិធិបំរុង អាចផ្ទេរទៅជាចំណូលថវិការបស់ខេត្ត ក្រុង ។

មាត្រា ១១ ._ មុខងារនៃភ្នាក់ងារគណនេយ្យរបស់រោងការ ត្រូវបានបំពេញដោយភ្នាក់ងាររតនាគារខេត្ត ក្រុង ម្នាក់ ដែលបានតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ១២ ._ គណនីហិរញ្ញវត្ថុរបស់រោងការ ត្រូវរៀបចំឡើងដោយភ្នាក់ងារគណនេយ្យរបស់រោងការ និង ត្រូវចុះទិដ្ឋាការដោយអភិបាលរោងការ ដើម្បីអោយស៊ីសង្វាក់គ្នាជាមួយនឹងគណនីរដ្ឋបាល ដែលត្រូវបានពិនិត្យដោយគណៈកម្មាធិការអាជីវកម្ម និង ត្រូវយល់ព្រមដោយអភិបាលខេត្ត ក្រុង ។

ឯកសារនេះ ត្រូវផ្ញើរអោយបញ្ជាក់ជាអាទិ៍ទៅស្ថាប័នគណនេយ្យ " [illegible] " ។

មាត្រា ១៣ ._ នៅពេលណាពិនិត្យឃើញថា អាជីវកម្មរបស់រោងការមានឱនភាពនោះ អភិបាលខេត្ត ក្រុង ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីចាត់វិធានការចាំបាច់ សំរាប់ធ្វើអោយមានតុល្យភាពឡើងវិញ ។

ករណីនៅតែមានឱនភាពតទៅទៀតនោះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចសំរេចដកហូតការអនុញ្ញាតធ្វើអាជីវកម្មនៃរោងការ និង អោយរៀបចំការគ្រប់គ្រងម្តងទៀត បន្ទាប់ពីមានការឯកភាពពីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤

## ការរំលាយរបស់រោងការខេត្ត ក្រុង

មាត្រា ១៤ ._ ការធ្វើអាជីវកម្មរបស់រោងការខេត្ត ក្រុង ត្រូវបញ្ឈប់ដោយការដកហូតការអនុញ្ញាត តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៥ ._ ប្រកាសស្តីពីការដកហូតការអនុញ្ញាត ត្រូវកំណត់កាលបរិច្ឆេទ ដែលត្រូវបញ្ឈប់កិច្ចប្រតិបត្តិការរបស់រោងការ ។ គណនីហិរញ្ញវត្ថុដែលមានចែងនូវមាត្រា ១២ ខាងលើ ក៏ត្រូវបញ្ឈប់ក្នុងកាលបរិច្ឆេទនោះដែរ ។

មាត្រា ១៦ ._ អភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកជាអ្នកជំរះបញ្ជី រៀបចំនីតិវិធីក្នុងកិច្ចប្រតិបត្តិការជំរះបញ្ជី ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

លទ្ធផលជំរះបញ្ជី ត្រូវកត់ត្រាក្នុងគណនីមួយ ដែលត្រូវបើកនៅក្នុងសៀវភៅបញ្ជីរបស់រតនាគារខេត្ត ក្រុង ក្នុងករណីដែលទ្រព្យសកម្មរបស់រោងការ មានមិនគ្រប់គ្រាន់សំរាប់ជំរះបញ្ជីនោះ គឺត្រូវយកថវិការបស់ខេត្ត ក្រុង ធ្វើការទូទាត់ជំនួស ។

មាត្រា ១៧ ._ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលគ្រប់ខេត្ត ក្រុង ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

មាត្រា ១៨ .- បទបញ្ញត្តិទាំងឡាយពាក់ព័ន្ធទៅនឹងរបបរដ្ឋបាល ហិរញ្ញវត្ថុ និង ការប្រព្រឹត្តិទៅនៃរដ្ឋាករបស់ខេត្ត ក្រុង ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបសម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

***

## អនុក្រឹត្យលេខ ៣១ អនក្រ.បក

## ស្តីពីការផ្ទេរឥណទាន

***

ថតចម្លង
បណ្ណសារដ្ឋានជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ៧៤៤ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**

**កម្មវត្ថុ** : *ករណីសំណើសុំគោលការណ៍បង្កើត«ផ្នាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)» នៅរាជធានីភ្នំពេញ។*

**យោង** : *- លិខិតលេខ ៥៧ លស.គរម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤ របស់សាលារាជធានីភ្នំពេញ*

*- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ* **ហ៊ុន សែន** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤។*

*សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចយល់ព្រមឱ្យសាលារាជធានីភ្នំពេញបង្កើត«ផ្នាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)» នៅរាជធានីភ្នំពេញ តាមសំណើ។*

*សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។*

9750

02 SEP 2015

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**អគ្គលេខាធិការ**

**ស៊ុ តិរិទ្ធ**

**លឹម_ទិចិត្រ**

**ចម្លងជូន:**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ១៤៧៣ ...

**ន. វែនការ និងវិនិយោគ**

ចូល ថ្ងៃ ១៣.០៨.១៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤

ចូល លេខ ក្រស ២៣៤៦ ថ្ងៃទី១៣.០៨.១៤ ម៉ោង ១៤:៣

## ជំរាបជូន

## ឯកឧត្តម អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

**កម្មវត្ថុ:** ស្តីពីសំណើសុំបង្កើត "រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)" នៅរាជធានីភ្នំពេញ។

**យោង:** លិខិតលេខ ១៨២ លស.ជវិ.ក្រមជ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ របស់សាលារាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងមហាផ្ទៃ សូមជំរាបជូន **ឯកឧត្តម** មេត្តាជ្រាបថា: ដោយពិនិត្យឃើញអត្ថប្រយោជន៍ជាច្រើន នៃការបង្កើតអោយមានសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៅរាជធានីភ្នំពេញ ក្នុងគោលបំណងដោះស្រាយបញ្ហាប្រឈមជាច្រើនដូចជា កាត់បន្ថយការកកស្ទះចរាចរណ៍ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ការពារបរិស្ថានជាអាទិ៍ និងដោយសេវាបែបនេះមានបរិវេតិចតួច ឬមិនទាន់ដំណើរការជាប់លាប់នោះ ក្រសួងមហាផ្ទៃយល់ព្រមតាមសំណើរបស់សាលារាជធានីភ្នំពេញ ដើម្បីបង្កើត "រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)" រាជធានីភ្នំពេញ ដោយអនុវត្តត្រឹមត្រូវតាមអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ១៩៩៩។

អាស្រ័យដូចបានជំរាបជូនខាងលើ **សូមឯកឧត្តម** ជ្រាប និងអនុវត្តចាត់ចែងតាមការគួរ ។

02 SEP 2015

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**លឹម_ទិចិត្រ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៥៨១ សហវ.អសហ

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥

គោរពជូន

ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

**កម្មវត្ថុ:** ករណីសំណើសុំគោលការណ៍បង្កើត "រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)" នៅរាជធានីភ្នំពេញ។

**យោង:**
- អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាល ហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅនៃរដ្ឋាកររបស់ខេត្ត ក្រុង
- លិខិតលេខ ១៣៣ លស.ជរ.ក្រ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ របស់សាលារាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ មេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍តាមការស្នើសុំរបស់សាលារាជធានីភ្នំពេញ លើការបង្កើតរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) សម្រាប់ធ្វើអាជីវកម្មផ្ទាល់នៃសេវាសាធារណៈនៅរាជធានីភ្នំពេញ ក្រោមរូបភាពជារដ្ឋាករស្វយ័ត សម្រាប់រយៈពេល ០៣ (បី) ឆ្នាំ គិតចាប់ពីការបង្កើតរដ្ឋាករស្វយ័តនេះ ។ បន្ទាប់មក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាលារាជធានីភ្នំពេញ នឹងធ្វើការពិនិត្យ និងពិភាក្សារួមគ្នា ដើម្បីប្រែក្លាយរដ្ឋាករស្វយ័តនេះ ទៅជាសហគ្រាសសាធារណៈ មានទម្រង់ជាក្រុមហ៊ុនរដ្ឋ ឬ ក្រុមហ៊ុនចំរុះ ។ ក្នុងដំណាក់ការជារដ្ឋាករស្វយ័ត ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាជ្រាប និងទទួលចាត់ចែងអនុវត្តតាមការគួរ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន

"ដើម្បី" ជូនជ្រាប"
- ឯកសារ

[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ
លេខ: ៣៤៣ សសរ.៥រ

## សេចក្តីសម្រេច
## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
## រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ

## អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៨៥ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ ស្តីពីការគ្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៨៣១ អនក្រ.តត ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ស្តីពីការតែងតាំងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅនៃរដ្ឋាករខេត្ត ក្រុង
- យោងលិខិតលេខ ៣៥៨ សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៥៧ លស.តរម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤ របស់សាលារាជធានីភ្នំពេញ
- យោងលិខិតលេខ ៧៨៥ សជណ.ឥក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ១៦៧៣ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ៣៥៩១ សហវ.អទប ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងភារកិច្ចចាំបាច់ចំពោះមុខ

## សម្រេច

**ប្រការ ១.-**

តែងតាំង លោក **គីម សេត** អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) ។

**ប្រការ ២.-**

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានសិទ្ធិចូលរួមរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការអាជីវកម្ម ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសម្លេងអនុម័តឡើយ ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

...ហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៥ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh, Email: info@phnompenh.gov.kh

**ប្រការ ៤ .**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ប្រធានរតនាគាររាជធានីភ្នំពេញ អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) រាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៥

អភិបាលរាជធានីភ្នំពេញ

**ប៉ា សុជាតិវង្ស**

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- «ដើម្បីជូនជ្រាប»
- ដូចប្រការ៤
- «ដើម្បីសហការ និងអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

លេខ: 9352.. រ.ប

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

រាជធានីភ្នំពេញ, ថ្ងៃទី 02 SEP 2015

ត.ប អភិបាល នាយករដ្ឋបាលសាលារាជធានីភ្នំពេញ

**លឹម_ធិបិត្រ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ
លេខ: ៣៤៤ សសរ.ជរ

325 ... 21.08.15 9:30

### សេចក្តីសម្រេច
### ស្តីពីការតែងតាំងអភិបាល និងអភិបាលរង
### រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ

### អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៥ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៨៣១ អនក្រ.តត ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ស្តីពីការតែងតាំងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុ និងការប្រព្រឹត្តិទៅនៃរដ្ឋាករខេត្ត ក្រុង
- យោងលិខិតលេខ ៣៥៨ សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៥៧ លស.តរម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់សាលារាជធានីភ្នំពេញ
- យោងលិខិតលេខ ៧៨៨ សជណ.ផក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ១៦៧៣ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ៣៥៩១ សហវ.អទច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងភារកិច្ចចាំបាច់ចំពោះមុខ

### សម្រេច

**ប្រការ ១.**

ត្រូវបានតែងតាំងអភិបាល និងអភិបាលរង រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) ដែលមានសមាសភាពខាងក្រោម ៖

| | |
|---|---|
| ១- លោក អ៊ិន សុឃីម | អភិបាល |
| ២- លោក អៀ ភារិទ្ធ | អភិបាលរង |
| ៣- លោក ណាក តាណារុឌ | អភិបាលរង |

**ប្រការ ២.**

អភិបាល អភិបាលរង រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) មានតួនាទី និងភារកិច្ចដូចតទៅ ៖

- រៀបចំការប្រជុំគណៈកម្មាធិការអាជីវកម្ម និងទទួលការងារលេខាធិការកិច្ចរាល់ការប្រជុំរបស់គណៈកម្មាធិការអាជីវកម្ម
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេច និងគោលការណ៍របស់គណៈកម្មាធិការអាជីវកម្ម និងសាលារាជ-ធានីភ្នំពេញ

- រៀបចំគម្រោងការងារ គម្រោងថវិកាប្រចាំឆ្នាំ របាយការណ៍ប្រចាំឆ្នាំ អំពីសកម្មភាព និងគុណភាពហិរញ្ញវត្ថុ ដើម្បីដាក់ជូនគណៈកម្មាធិការអាជីវកម្មអនុម័ត
- ទទួលបន្ទុកដឹកនាំរដ្ឋបាល បច្ចេកទេស ហិរញ្ញវត្ថុ និងគ្រប់គ្រងអាជីវកម្ម
- ទទួលខុសត្រូវលើទ្រព្យសម្បត្តិរបស់រដ្ឋាករ ចលនទ្រព្យ និងអចលនទ្រព្យ
- រៀបចំសំណើ ជ្រើសរើស តែងតាំង ដកហូតអំណាច ឬបញ្ឈប់ការងារមន្ត្រីគ្រប់រូបដែលជានិយោជិតរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) ដោយផ្អែកលើបទបញ្ជាផ្ទៃក្នុង និងច្បាប់ជាធរមានព្រមទាំងការសម្រេចរបស់គណៈកម្មាធិការអាជីវកម្ម និងសាលារាជធានីភ្នំពេញ
- អភិបាល និងអភិបាលរង រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) ត្រូវមានគណនេយ្យភាពចំពោះគណៈកម្មាធិការអាជីវកម្ម ។

**ប្រការ ៣..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤..**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ប្រធានរតនាគាររាជធានីភ្នំពេញ អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) រាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥

**អភិបាលរាជធានីភ្នំពេញ**

**ប៉ា សុជាតិវង្ស**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

"<u>ដើម្បីជូនជ្រាប</u>"
- ដូចប្រការ៤

"<u>ដើម្បីសហការ និងអនុវត្ត</u>"
- ឯកសារ - កាលប្បវត្តិ

៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh, Email info@phnompenh.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ
លេខ: ៣៤៦ សសរ.ជំ

ចូល
លេខ 325 សសរ.ជំ
ថ្ងៃ 01.08.15 ម៉ោង 9:30
ពេទ្យ ... គន់ ពិស ស្រីណាល

## សេចក្តីសម្រេច

## ស្តីពីការតែងតាំងគណៈកម្មាធិការអាជីវកម្មរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៅរាជធានីភ្នំពេញ

---

## អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការប្រោសប្រណីបង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៤៣១ អនក្រ ត.ត ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ស្តីពីតែងតាំងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅនៃរដ្ឋាករខេត្ត ក្រុង
- យោងលិខិតលេខ ៣៥៨ សជណ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតឱ្យរៀបចំប្រព័ន្ធដឹកជញ្ជូនសាធារណៈដោយរថយន្តក្រុង (City Bus) ក្នុងរាជធានីភ្នំពេញ
- យោងលិខិតលេខ ៥៧ លស.គរម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤ របស់សាលារាជធានីភ្នំពេញ
- យោងលិខិតលេខ ៧៤៤ សជណ.ផក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ១៦៧៣ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ៣៥៩១ សហវ.អទច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងភារកិច្ចចាំបាច់ចំពោះមុខ

## សម្រេច

**ប្រការ ១.**

ត្រូវបានតែងតាំងគណៈកម្មាធិការអាជីវកម្មរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) ដែលមានសមាសភាពខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ប៉ា សុជាតិវង្ស** | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | **ប្រធាន** |
| ២- ឯកឧត្តម | អៀង អូនឌី | អភិបាលរងរាជធានីភ្នំពេញ | អនុប្រធាន |
| ៣- លោក | មាន ចាន់យ៉ាដា | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ៤- លោក | ហួត ហៃ | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ៥- លោក | យុត ឡុងឌី | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ៦- លោក | វ៉ា សុធា | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ | សមាជិក |

| | | | |
|---|---|---|---|
| | | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ | |
| ៧- លោក | សាំ ពិសិដ្ឋ | | សមាជិក |
| ៨- លោក | ជូ ម៉េងចាន់ | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ៩- លោក | អ៊ុក សុផល | នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១០- លោក | ស៊ុន បូណ៌មី | នាយកទីចាត់ការរៀបចំក្រុង | សមាជិក ✓ |
| ១១- លោក | អ៊ាន សុឃឹម | អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង | សមាជិក |
| ១០- លោក | សេង រតនៈ | ប្រជាពលរដ្ឋល្អ | |

**ប្រការ ២.**

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដូចតទៅ ៖

- កំណត់គម្រោងអភិវឌ្ឍន៍តាមសំណើរបស់ អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) ដោយអនុលោមតាមទិសដៅកំណត់ របស់សាលារាជធានីភ្នំពេញ
- កំណត់គម្រោងថវិកាប្រចាំឆ្នាំ និងកម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបម្រុង សម្រាប់សម្រេចកម្មវិធីវិនិយោគ
- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ
- កំណត់នូវរចនាសម្ព័ន្ធចាត់តាំង ចំនួនក្របខ័ណ្ឌ ការបែងចែកមុខងារទូទៅ និងប្រាក់បៀវត្សរបស់និយោជិតតាមសំណើរបស់អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus )
- អនុញ្ញាតឱ្យទិញអចលនវត្ថុគ្រប់ប្រភេទ ដោយគោរពតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈ
- សម្រេចយល់ព្រមលើកិច្ចសន្យា និងអនុស្សរណៈផ្សេងៗ ដោយមានការយល់ព្រមពីសាលារាជធានីភ្នំពេញ
- ធ្វើការត្រួតពិនិត្យក្នុងចន្លោះពេលទៀងទាត់មួយលើទិសដៅដែលបានកំណត់ និងលើកឡើងនូវបណ្ដាវិធានការកែសម្រួល
- លើកសំណើសុំកែប្រែគម្រោង ឬវិធានការដែលលើកឡើងដោយរដ្ឋាករ ។

**ប្រការ ៣.**

សមាជិក គណៈកម្មាធិការអាជីវកម្មរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ប្រធានរតនាគាររាជធានីភ្នំពេញ អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ និងសាម៉ីខ្លួន ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៥

អភិបាលរាជធានីភ្នំពេញ

ប៉ា សុជាតិវង្ស

កន្លែងទទួល ៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - ដើម្បីជូនជ្រាប -
- ដូចប្រការ៥
  - ដើម្បីសហការ និងអនុវត្ត -
- ឯកសារ - កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ
លេខ: ៣៣៦ សសរ.ជវ

# សេចក្តីសម្រេច
## ស្តីពីការតែងតាំងប្រធានការិយាល័យចំណុះ
## រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ

## អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៨៥ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុ និងការប្រព្រឹត្តិទៅនៃរដ្ឋាករខេត្ត ក្រុង
- យោងលិខិតលេខ ៣៥៨ សជណ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៥៧ លស.គរម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤ របស់សាលារាជធានីភ្នំពេញ
- យោងលិខិតលេខ ៧៤៤ សជណ.ជក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ១៦៧៣ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ៣៥៩១ សហវ.អទច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងភារកិច្ចចាំបាច់ចំពោះមុខ

## សម្រេច

**ប្រការ ១..**

ត្រូវបានតែងតាំងមន្ត្រីចំនួន ០៤រូប ជាប្រធានការិយាល័យ ចំណុះរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- លោក ឃ្លី នរៈ | ប្រធានការិយាល័យរដ្ឋបាល |
| ២- លោក ឡាយ សុខរស្មី | ប្រធានការិយាល័យអធិការកិច្ច និងដោះស្រាយវិវាទ |
| ៣- លោក ដាញ់ ដារិទ្ធ | ប្រធានការិយាល័យគណនេយ្យ |
| ៤- លោក ម៉ិល សារិត | ប្រធានការិយាល័យបច្ចេកទេស |

**ប្រការ ២..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣..**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ប្រធានរតនាគាររាជធានីភ្នំពេញ អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) រាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥

អភិបាលរាជធានីភ្នំពេញ

ប៉ា សុជាតិវង្ស

<u>កន្លែងទទួល ៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - <u>ដើម្បីជូនជ្រាប</u> -
- ដូចប្រការ៣
  - <u>ដើម្បីសហការ និងអនុវត្ត</u> -
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

លេខ: ១១០/១៦ ស.ក.ភ.ជ

# ដីកា

## ស្តីពី

## ការសម្រួលភារកិច្ច និងប្រគល់ភារកិច្ចបន្ថែមជូនមន្ត្រីរាជការ

### អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ
- យោងសេចក្តីសម្រេចលេខ ៣២៥ សសរ.ផរ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការអាជីវកម្មរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)នៅរាជធានីភ្នំពេញ
- យោងសេចក្តីសម្រេចលេខ ៣២៤ សសរ.ផរ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការតែងតាំងអភិបាល និងអភិបាលរងរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ
- យោងតាមសំណូមពរចាំបាច់ នៃភារកិច្ចចំពោះមុខ

### សម្រេច

**ប្រការ ១.-**

ត្រូវបានសម្រួលភារកិច្ចលោក **ណាក តាណាឌុង** ពីអភិបាលរងរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) ឱ្យមកបម្រើការងារនៅសាលារាជធានីភ្នំពេញ ។

**ប្រការ ២.-**

ត្រូវបានប្រគល់ភារកិច្ចបន្ថែមជូនលោក **ស ឌុន្នី** បច្ចុប្បន្នអនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ជាអភិបាលរងរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងដីកានេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានមន្ទីរមុខងារសាធារណៈ ប្រធានរតនាគាររាជធានីភ្នំពេញ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ នាយកទីចាត់ការ ប្រធានអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើ ត្រូវអនុវត្តដីកានេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**អភិបាលរាជធានីភ្នំពេញ។-**

**ប៉ា សុជាតិវង្ស**

**កន្លែងទទួល:**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ក្រុមប្រឹក្សារាជធានីភ្នំពេញ
- គណៈកម្មាធិការអាជីវកម្មរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus)
  "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ

លេខ : ០៤ ផក.ជំរ.ក្រប

# ដីកា

## ស្តីពីការបង្កើតរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៅរាជធានីភ្នំពេញ

## ក្រុមប្រឹក្សារាជធានីភ្នំពេញ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦៤៩ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានីភ្នំពេញ ក្នុងអាណត្តិទី២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅនៃរដ្ឋាករខេត្ត ក្រុង
- បានឃើញអនុក្រឹត្យលេខ ២៨៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីជ្រើសរើសការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ
- យោងលិខិតលេខ ៣៥៨ សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៧៤៤ សជណ.ផក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ១៦៧៣ សជណ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ៣៥៩១ សហវ.អទច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងកិច្ចប្រជុំសាមញ្ញលើកទី ១៦ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥

## សម្រេច

**ប្រការ ១ ..**

បង្កើតរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៅរាជធានីភ្នំពេញ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងគោលបំណងបង្កភាពងាយស្រួល និងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋរួមមាន ៖ បង្កភាពងាយស្រួលក្នុងការធ្វើដំណើរ ធានាប្រសិទ្ធភាព ផាសុកភាព សន្សំសំចៃពេល/

៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣ ៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០
www.phnompenh.gov.kh Email info@phnompenh.gov.kh

វេលា ប្រាក់កាស កាត់បន្ថយការកកស្ទះចរាចរ គ្រោះថ្នាក់ចរាចរ ការប្រើប្រាស់ថាមពលខ្ជះខ្ជាយ ឧស្ម័នបំពុលបរិស្ថាន និងផលប៉ះពាល់សុខុមាលភាពប្រជាពលរដ្ឋក្នុងរាជធានី ។

រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) មានអាសយដ្ឋាន (បណ្ដោះអាសន្ន) នៅក្នុងបរិវេណមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ដែលស្ថិតនៅសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

**ប្រការ ២..**

រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) មានភារកិច្ច ៖

១- ធ្វើអាជីវកម្មសេវាដឹកជញ្ជូនសាធារណៈដោយរថយន្តក្រុង (City Bus) និងមធ្យោបាយសាធារណៈផ្សេងៗទៀតនៅរាជធានីភ្នំពេញ

២- គ្រប់គ្រងយានយន្ត បណ្ដាញខ្សែរត់ ចំណតរង់ចាំ ថ្លៃសំបុត្រជិះរថយន្ត ម៉ោងពេលប្រតិបត្តិការដឹកជញ្ជូន និងចំណតរថយន្តដឹកជញ្ជូនសាធារណៈ (City Bus) ។ល។

៣- គ្រប់គ្រងកិច្ចប្រតិបត្តិការដឹកជញ្ជូនសាធារណៈ សន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាពអ្នកដំណើរ

៤- រៀបចំបទប្បញ្ញត្តិផ្សេងៗ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) នៅរាជធានីភ្នំពេញ

៥- ជួសជុល ថែទាំយានយន្ត អនាម័យ បរិស្ថាន យានដ្ឋាន និងការងារថែទាំសំណង់អគារ ជាដើម ។ល។

៦- ប្រមូលប្រាក់កម្រៃបម្រើសេវាដឹកជញ្ជូន និងការងារផ្សេងៗទៀតពាក់ព័ន្ធទៅនឹងការងារដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) ។

**ប្រការ ៣ ..**

ក្នុងករណីដែលមិនបានអនុវត្តទៅតាមលក្ខន្តិកៈ តួនាទីភារកិច្ច និងបទប្បញ្ញត្តិជាធរមាន រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីភ្នំពេញ ។

**ប្រការ ៤ ..**

គណៈអភិបាលរាជធានីភ្នំពេញ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១២ ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ ប្រធានគណៈកម្មាធិការអាជីវកម្មរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) និងអភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) មានភារកិច្ចអនុវត្តដីកានេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥

ក្រុមប្រឹក្សារាជធានីភ្នំពេញ

ប្រធាន

[ត្រា និងហត្ថលេខា]

**មប់ សារិន**

កន្លែងទទួល ៖

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន

« ដើម្បីជូនជ្រាប »

ដូចប្រការ៤

« ដើម្បីសហការ និងអនុវត្ត »

ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

—

**រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ**
**រថយន្តក្រុង** (City Bus) **រាជធានីភ្នំពេញ**
លេខ : ១០៧ ក.ប.ភ.រដស

## កំណត់បែងចែក
## ភារកិច្ច និងការទទួលខុសត្រូវថ្នាក់ដឹកនាំ
## និងការិយាល័យនីមួយៗ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង

**យោង:** -លក្ខន្តិកៈលេខ ០០១ សហរ. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៦ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( CITY BUS ) ។

-សៀវភៅបន្ទុកលេខ ០៥៦ សហរ. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៦ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( CITY BUS ) ។

-ដីកាលេខ ០៤ ដក.ផវ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥ របស់រដ្ឋបាលរាជធានីភ្នំពេញ ។

-សេចក្តីសម្រេចលេខ ៣២៤ សសរ.ផវ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៥ របស់រដ្ឋបាលរាជធានីភ្នំពេញ ។

ដើម្បីធានាដល់ការដឹកនាំមួយមានប្រសិទ្ធភាព និងការទទួលខុសត្រូវ តាមភារកិច្ចរៀងៗខ្លួន អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង បានដាក់ចេញនូវកំណត់បែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងការិយាល័យនីមួយៗ ដូចខាងក្រោមៈ

### ១. អភិបាលរដ្ឋាករ

អភិបាលរដ្ឋាករ គឺជាថ្នាក់ដឹកនាំរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងត្រូវដឹកនាំ និងគ្រប់គ្រង និងមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំការប្រជុំគណៈកម្មាធិការអាជីវកម្ម និងទទួលការងារជាលេខាធិការ រាល់ការប្រជុំរបស់គណៈកម្មាធិការអាជីវកម្ម ។
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេច និងគោលការណ៍របស់គណៈកម្មាធិការអាជីវកម្ម និងសាលារាជធានីភ្នំពេញ ។
- ទទួលខុសត្រូវលើចំណូល-ចំណាយទាំងអស់របស់រដ្ឋាករ និងការចុះហត្ថលេខាដកថវិកាពីធនាគារ សំរាប់ចាត់ចែង និងប្រើប្រាស់ក្នុងរដ្ឋាករ ។
- រៀបចំគម្រោងការងារ គម្រោងថវិកាប្រចាំឆ្នាំ របាយការណ៍ប្រចាំឆ្នាំ អំពីសកម្មភាព និងគុណ្យការហិរញ្ញវត្ថុ ដើម្បីដាក់ជូនគណៈកម្មាធិការអាជីវកម្មពិនិត្យ និងអនុម័ត ។
- ទទួលបន្ទុកដឹកនាំបុគ្គលិក រដ្ឋបាល បច្ចេកទេស ហិរញ្ញវត្ថុ និងគ្រប់គ្រងអាជីវកម្ម ។
- ទទួលខុសត្រូវលើទ្រព្យសម្បត្តិរបស់រដ្ឋាករ ចលនទ្រព្យ និងអចលនទ្រព្យ ។

- សំណើជ្រើសរើស តែងតាំង ដកហូតអំណាច ឬ បញ្ឈប់ការងារបុគ្គលិកគ្រប់រូប ដែលជានិយោជិត "**រ.ជ.ស**" ដោយផ្អែកលើបទបញ្ជាផ្ទៃក្នុង និងច្បាប់ជាធរមាន ព្រមទាំងការសម្រេចរបស់គណៈកម្មាធិការអាជីវកម្ម និងសាលារាជធានីភ្នំពេញ។
- ផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅឲ្យអភិបាលរង ឬមន្ត្រីនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយគណៈកម្មាធិការអាជីវកម្ម ។
- រៀបចំ និងចុះហត្ថលេខាលើកិច្ចសន្យា ឬ អនុស្សារណៈផ្សេងៗ ស្របតាមការសម្រេចរបស់គណៈកម្មាធិការអាជីវកម្ម ក្រោយពីមានការផ្ទេរសិទ្ធិពីអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។
- អភិបាលអាចលាលែងពីតំណែងរបស់ខ្លួនបាន តែត្រូវជូនដំណឹងយ៉ាងតិច៣ខែមុន ដោយមានការយល់ព្រមពីគណៈកម្មាធិការអាជីវកម្ម និងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ។
- ដឹកនាំអង្គប្រជុំ និងធ្វើរបាយការណ៍ស្តីពី ស្ថានភាពចំណូល-ចំណាយថវិកា និងសកម្មភាពការងាររបស់រដ្ឋាករប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ ជូនគណៈកម្មការអាជីវកម្មបានជ្រាប និងសុំមតិដឹកនាំបន្ត ។

**២.អភិបាលរងរដ្ឋាករ**

អភិបាលរងរដ្ឋាករ គឺជាជំនួយការរបស់អភិបាលរដ្ឋាករ មានភារកិច្ចជួយការងារអភិបាលរដ្ឋាករក្នុងការពិនិត្យ និងផ្តល់យោបល់ចំពោះឯកសារនានា មុនដាក់ជូនអភិបាលរដ្ឋាករពិនិត្យ និងសំរេច ។

**៣.ការិយាល័យរដ្ឋបាល**

ការិយាល័យរដ្ឋបាល មានពីរផ្នែក គឺផ្នែករដ្ឋបាល និងទំនាក់ទំនងសាធារណៈ និងផ្នែកគ្រប់គ្រងធនធានមនុស្ស មានភារកិច្ចដូចតទៅៈ

**ក.ផ្នែករដ្ឋបាល និងទំនាក់ទំនងសាធារណៈ**

- ទទួលលិខិតរដ្ឋបាលផ្លូវការចេញ-ចូលគ្រប់ប្រភេទ និងចាត់ចែងលិខិតទៅតាមការិយាល័យជំនាញនីមួយៗ ។
- ទទួលបដិសណ្ឋារកិច្ចភ្ញៀវ និងអតិថិជន ដែលមកទំនាក់ទំនងការងារជាមួយរដ្ឋាករ និងការរៀបចំពិធីផ្សេងៗ ។
- រៀបចំទុកដាក់ឯកសារគ្រប់ប្រភេទ ដែលពាក់ព័ន្ធនឹងរដ្ឋាករឱ្យបានត្រឹមត្រូវ និងមានរបៀបរៀបរយល្អ ។
- ធ្វើរបាយការណ៍ ស្តីពី សកម្មភាពការងាររបស់រដ្ឋាករប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំជូនអភិបាលរដ្ឋាករ និងគណៈកម្មការអាជីវកម្មជ្រាប ។
- ធ្វើសេចក្តីផ្សព្វផ្សាយព័ត៌មានផ្សេងៗ ដែលមានផលប្រយោជន៍ដល់រដ្ឋាករ ។
- រក្សាអនាម័យ និងបរិស្ថានល្អ នៅកន្លែងធ្វើការក្នុងរដ្ឋាករ និងបរិវេណជុំវិញ ។
- បែងចែកវេនប្រចាំការ ២៤ម៉ោង លើ ២៤ម៉ោង ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយល្អនៅក្នុងរដ្ឋាករ ។

- នីតិវិធី នៃការបញ្ចូលប្រាក់ នៅក្នុងគណនីធនាគារ និងការដកប្រាក់ចេញពីធនាគារ ត្រូវមានការឯកភាពពីអភិបាលរដ្ឋាករ ។
- រៀបចំតំរោងថែទាំ ការជួសជុល ការសាងសង់ទីស្នាក់ការ មធ្យោបាយដឹកជញ្ជូន និងសម្ភារៈប្រើប្រាស់ផ្សេងៗ ។
- ថែរក្សា និងទុកដាក់សម្ភារៈប្រើប្រាស់របស់រដ្ឋាករដូចជា ឯកសណ្ឋានបុគ្គលិក អាយកូម និងបរិក្ខាបំពាក់ផ្សេងៗ ឱ្យបានល្អ ។
- ធ្វើរបាយការណ៍ ស្តីពី ស្ថានភាពហិរញ្ញវត្ថុ តារាងតុល្យភាពគណនេយ្យចំណូល-ចំណាយ ដោយមានសក្ខីប័ត្រ ឬឯកសារសំអាងផ្សេងៗ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ ជូនគណៈកម្មាធិការអាជីវកម្មជ្រាប ។
- និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលរដ្ឋាករ ។

**៥.ការិយាល័យបច្ចេកទេស**

- គ្រប់គ្រងយានយន្ត ជួសជុល និងថែទាំរថយន្ត នៅតាមយានដ្ឋាន និងនៅតាមខ្សែនីមួយ ៗ ។
- ធ្វើការតាមដាន និងត្រួតពិនិត្យអំពីការជួសជុល និងថែទាំរថយន្ត ។
- ធ្វើការបែងចែកម៉ោងពេលចេញ-ចូលរថយន្ត តាមលំដាប់ និងវេន។
- គ្រប់គ្រងស្ថានីយ៍ចំណតរថយន្តដើមទី ចុងទី យានដ្ឋានជួសជុលរថយន្ត កន្លែងលាងរថយន្ត និងចំណតរង់ចាំតាមខ្សែនីមួយៗ ។
- សិក្សាគំរោងប្លង់ខ្សែរត់ និងធ្វើចំណតរង់ចាំ សំរាប់ខ្សែរត់រថយន្តក្រុងថ្មី ។
- រៀបចំកាលវិភាគកំណត់ម៉ោងពេលចេញដំណើរឬមកដល់នៃរថយន្តនីមួយៗនៅតាមបណ្តាស្ថានីយ៍ ឬចំណតរង់ចាំ ឲ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែង គឺយ៉ាងច្រើន ១០នាទី ទៅ ១៥នាទី ក្នុងមួយវេន ក្នុងម៉ោងមមាញឹក និង១៥នាទី ទៅ ២០នាទី ក្នុងមួយវេន ក្នុងម៉ោងធម្មតា ។
- គ្រប់គ្រងការផ្សព្វផ្សាយពាណិជ្ជកម្មតាមរថយន្ត និងតាមចំណតរង់ចាំទាំងអស់ ។
- និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលរដ្ឋាករ ។

**៦.ការិយាល័យអធិការកិច្ច និងដោះស្រាយវិវាទ**

ការិយាល័យអធិការកិច្ច និងដោះស្រាយវិវាទ មានភារកិច្ចដូចតទៅ:

- ធ្វើការតាមដាន ត្រួតពិនិត្យម៉ោងពេលការងាររបស់បុគ្គលិកនៅតាមគោលដៅនីមួយៗ និងនៅតាមរថយន្ត ដើម្បីពង្រឹងការងារឲ្យមានប្រសិទ្ធភាព ។
- ត្រួតពិនិត្យ និងតាមដានរាល់កំហុសឆ្គងរបស់បុគ្គលិកទាំងអស់ និងធ្វើការអប់រំ ណែនាំ ដោយត្រូវធ្វើកិច្ចសន្យាព្រមាន ។
- ចុះអន្តរាគមន៍បន្ទាន់ និងសហការជាមួយកំលាំងមានសមត្ថកិច្ច ករណីមានបាតុភាព គ្រោះថ្នាក់ចរាចរណ៍ និងវិវាទកើតឡើងនៅតាមគោលដៅ និងខ្សែរត់រថយន្តក្រុង ។
- ត្រួតពិនិត្យ និងតាមដានការគេងប្រវញ្ចប្រាក់របស់បុគ្គលិកអ្នកលក់សំបុត្រ ។

- សម្របសម្រួល និងដោះស្រាយបញ្ហាវិវាទគ្រប់ប្រភេទ ទាំងវិវាទការងាររវាងរដ្ឋាករ និងបុគ្គលិក និងវិវាទកិច្ចសន្យារវាងរដ្ឋាករ ជាមួយអតិថិជន ។
- ធ្វើបទបញ្ជា សេចក្តីសំរេច លិខិតបទដ្ឋាននិងអនុស្សារណៈសំរាប់ប្រើប្រាស់នៅក្នុងរដ្ឋាករ។
- និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលរដ្ឋាករ និងគណៈកម្មការអាជីវកម្ម ។

កំណត់បែងចែកភារកិច្ចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានី[illegible] ខែឧសភាឆ្នាំ២០១៦

អភិបាលរដ្ឋាករ

អ៊ាន សុឃីម

លេខ: [illegible]

**បានឃើញ និងឯកភាព**

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ប៉ា សុជាតិវង្ស**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

—

រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ
រថយន្តក្រុង (City Bus) រាជធានីភ្នំពេញ
លេខ : ១០៨ ក.ប.ភ រដស

# កំណត់បែងចែក
## ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកបម្រើសេវា
## របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង

**យោង:** -លក្ខន្តិកៈលេខ ០០១ សហរ. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៦ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (CITY BUS) ។
-សៀវភៅបន្ទុកលេខ ០៥៦ សហរ. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៦ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (CITY BUS) ។
-ដីកាលេខ ០៨ ដក.ផវ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥ របស់រដ្ឋបាលរាជធានីភ្នំពេញ ។
-សេចក្តីសម្រេចលេខ ៣២៨ សសរ.ផវ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៥ របស់រដ្ឋបាលរាជធានីភ្នំពេញ ។

ដើម្បីឲ្យដំណើរការ នៃការបម្រើសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងជូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញអោយបានរលូន និងមានប្រសិទ្ធភាព អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ដាក់ចេញនូវកំណត់បែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកបម្រើសេវាតាមផ្នែកនីមួយៗ ដូចខាងក្រោម:

**១- ប្រធានខ្សែ**

- ដឹកនាំ និងគ្រប់គ្រងការងាររួម នៅតាមខ្សែរត់រថយន្តក្រុង ។
- ធ្វើការបូកសរុបសភាពការណ៍ដែលកើតមានឡើងនៅក្នុងខ្សែរបស់ខ្លួន និងបូកសរុបស្ថិតិអតិថិជនដែលជិះរថយន្តប្រចាំថ្ងៃ រួចរាយការណ៍មករដ្ឋាករជាប្រចាំថ្ងៃ ។
- ដោះស្រាយបឋមនូវករណីវិវាទបុគ្គលិក និងបុគ្គលិក និងករណីគ្រោះថ្នាក់ចរាចរណ៍ ។
- ធ្វើការវាយតម្លៃ និងពិនិត្យលក្ខណៈសម្បត្តិរបស់បុគ្គលិក ដើម្បីស្នើសុំការលើកទឹកចិត្តពីរដ្ឋាករ (លិខិតសរសើរ ប័ណ្ណសរសើរ និងប្រាក់ឧបត្ថម្ភលើកទឹកចិត្ត) ។
- ត្រូវចូលរួមប្រជុំប្រចាំខែ ឆមាស និងឆ្នាំ តាមការអញ្ជើញរបស់រដ្ឋាករ ។
- និងការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់អភិបាលរដ្ឋាករ ។

**២- ប្រធានក្រុមអ្នកបើកបរ**

- គ្រប់គ្រង និងបណ្តុះបណ្តាលជំនាញបច្ចេកទេសបើកបរបន្ថែម ដល់អ្នកបើកបរ ។
- គ្រប់គ្រង និងថែទាំរថយន្ត នៅតាមខ្សែដែលខ្លួនទទួលខុសត្រូវ ។
- ផ្តល់ព័ត៌មានអំពីរថយន្តខូច ទៅដល់ការិយាល័យបច្ចេកទេស ដើម្បីធ្វើការជួសជុល ។
- ធ្វើរបាយការណ៍អំពីស្ថានភាពរថយន្ត (រថយន្តខូច រថយន្តត្រូវប្តូរប្រេងម៉ាស៊ីន និងគ្រឿងបន្លាស់ផ្សេងៗ) ជាប្រចាំថ្ងៃ ដល់ប្រធានខ្សែ ។
- បើករថយន្តជំនួស អ្នកបើកបរដែលបានសុំច្បាប់ និងត្រូវ DAY OFF ។
- សហការជាមួយក្រុមជាង និងបុគ្គលិកបច្ចេកទេស ក្នុងការជួសជុលរថយន្តខូច និងថែទាំរថយន្ត ។
- ចូលរួមសហការជាមួយអ្នកបើកបរក្នុងការដោះស្រាយវិវាទផ្សេងៗ ។

**៣- អ្នកបញ្ជារថយន្ត**

- ធ្វើការស្រង់អវត្តមាន បុគ្គលិកទាំងអស់នៅតាមគោលដៅ និងវេនរបស់ខ្លួន ។
- ធ្វើការចាត់ចែងបញ្ជារថយន្តអោយចេញដំណើរ ក្នុងរយៈពេល ១០-១៥នាទីម្តង តាមស្ថានភាពជាក់ស្តែង ។
- ធ្វើការកត់ត្រាម៉ោងពេលនៃការ ចេញ-ចូល រថយន្ត អោយបានហ្មត់ចត់ ។
- ប្រមូលកម្រៃសេវា ពីអ្នកលក់សំបុត្រ រួចប្រគល់ជូនដល់បុគ្គលិកប្រមូលកម្រៃសេវា ។
- ផ្តល់សំបុត្រដល់អ្នកលក់សំបុត្រ និងកត់ត្រាពីចំនួនសំបុត្រអោយច្បាស់លាស់ ។
- ធ្វើការបូកសរុបស្ថិតិអតិថិជនដែលជិះរថយន្តតាមគោលដៅរបស់ខ្លួន រួចផ្ញើទៅប្រធានខ្សែ ដើម្បីធ្វើការបូកសរុបរួម ។

**៤- អ្នកបើកបរ**

- មកដល់កន្លែងឱ្យបានមុន ១៥នាទី រួចត្រួតពិនិត្យរថយន្តមុនពេលចេញដំណើរ ដូចជាម៉ាស៊ីនរថយន្ត ប្រព័ន្ធភ្លើង ប្រព័ន្ធទឹក ប្រព័ន្ធបង្ហិល ប្រព័ន្ធចង្កូត និងតួរថយន្ត ។
- មុនពេលចេញដំណើរត្រូវបញ្ឆេះម៉ាស៊ីន ៥នាទី ដើម្បីធានាថា រថយន្តអាចដំណើរការបាន
- ត្រូវបើកបរចូលចំណតរង់ចាំនីមួយៗ ដោយរក្សាល្បឿនក្រោម ៥km និងត្រូវផ្តល់ភ្លើងសញ្ញាមុនចូលចំណត ។
- បើកទ្វាររថយន្តរង់ចាំអ្នកធ្វើដំណើរឡើងជិះ ៣នាទី មុនពេលចេញពីស្ថានីយ៍ចំណត ។
- បើកបរត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ជានិច្ច និងការយោគយល់គ្នាទៅវិញទៅមក។
- បើកបរត្រូវគោរពច្បាប់ចរាចរណ៍ និងធានាសុវត្ថិភាពដល់អ្នកដំណើរ ទាំងពេលឡើងជិះ ពេលធ្វើដំណើរ និងពេលចុះពីរថយន្ត ។
- ធ្វើការសម្របសម្រួលដោះស្រាយរាល់បាតុភាពដែលកើតមាននៅក្នុងរថយន្ត រួមទាំងករណីគ្រោះថ្នាក់ចរាចរណ៍ផង ។

**៥- អ្នកលក់សំបុត្រ**

- សំអាតអនាម័យ និងថែទាំសំភារៈដែលមានក្នុងរថយន្តអោយបានល្អ ។
- ត្រូវមានអកប្បកិរិយាស្លូតបូត សុភាពរាបសារ និងរួសរាយរាក់ទាក់ភ្ញៀវ ។
- ជម្រាបភ្ញៀវអោយដាក់ថវិកាចូលក្នុងហិប ឬធុង និងហែកសំបុត្រជូនភ្ញៀវ ។
- ជម្រាបជូនភ្ញៀវអោយអង្គុយកៅអី ឬកន្លែងគួរសម្ប មុនចេញដំណើរ និងជូនដំណឹងអំពីតម្រាយផ្លូវដែលអាចធ្វើការផ្លាស់ប្តូរខ្សែ និងទិសដៅដែលត្រូវទៅបន្ត ។
- ធ្វើការទូទាត់កម្រៃសេវាដែលប្រមូលបានពីអតិថិជន ជូនដល់អ្នកបញ្ជារថយន្ត នៅពេលបញ្ចប់ម៉ោងការងាររបស់ខ្លួន ។
- ត្រូវធ្វើការកត់ត្រា និងបូកសរុបស្ថិតិភ្ញៀវ (បង់ប្រាក់ និងមិនបង់ប្រាក់) ដែលជិះរថយន្តប្រចាំថ្ងៃ ជូនដល់អ្នកបញ្ជារថយន្ត ។

កំណត់បែងចែកភារកិច្ចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែឧសភា ឆ្នាំ២០១៦

[illegible]

[illegible]

លេខ.១០៦/១៦.ហស

**បានឃើញ និងឯកភាព**

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ប៉ា សុជាតិវង្ស**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ
រថយន្តក្រុង (City Bus) រាជធានីភ្នំពេញ
លេខ : ១០៥ បប.រដស

## បទបញ្ញត្តិសម្រាប់អ្នកដំណើរ

ដើម្បីធានាសណ្តាប់ធ្នាប់ របៀបរៀបរយល្អក្នុងការធ្វើដំណើរ អ្នកដំណើរទាំងអស់ត្រូវគោរពនូវបទបញ្ញត្តិមួយចំនួនដូចខាងក្រោម ៖

- អ្នកដំណើរត្រូវតម្រៀបជួររង់ចាំនៅចំណតមុនពេលរថយន្តមកដល់ ។ នៅពេលរថយន្តមកដល់ និងឈប់ស្ងៀម ទើបអាចឡើង ឬចុះពីរថយន្តដោយមានរបៀបរៀបរយ ( បើនៅខាងស្តាំរថយន្តមានទ្វារតែមួយ ត្រូវចុះមុន ទើបឡើងក្រោយ បើនៅខាងស្តាំមានទ្វារពីរ ត្រូវឡើងតាមទ្វារមុខ ចុះតាមទ្វារក្រោយ បើនៅខាងស្តាំ មានទ្វារបី គឺឡើងតាមទ្វារមុខ ចុះតាមទ្វារកណ្តាល និងទ្វារក្រោយ ) ។
- អ្នកដំណើរមិនត្រូវឡើងជិះរថយន្តដោយបង្ខំ ហើយហាមផ្តាច់មិនឱ្យបិទ បើកទ្វាររថយន្តតាមតែចិត្តចង់ ។
- អ្នកដំណើរមិនអនុញ្ញាតឱ្យប៉ះពាល់ ឬ ធ្វើឱ្យខូចគ្រឿងបំពាក់ នៃរថយន្ត និងសម្ភារបំរើសេវា ។
- មុននឹងទៅដល់ចំណត អ្នកដំណើរដែលត្រូវចុះនៅចំណតខាងមុខត្រូវរៀបចំជាមុន និងខិតទៅក្បែរទ្វាររថយន្តដែលត្រូវចុះ ហើយប្រុងប្រយត្ន័ចាំស្តាប់ការប្រកាសចំណត ជៀសវាងការចុះខុសចំណត ។ នៅពេលចុះពីលើរថយន្តត្រូវផ្តល់អាទិភាពទៅវិញទៅមក មិនត្រូវប្រជ្រៀតគ្នា ឬស្រែកឡូឡាបង្កជម្លោះ ។
- អ្នកដំណើរត្រូវបង្ហាញសំបុត្រ ឬបង់ប្រាក់នៅពេលឡើងជិះរថយន្តដល់អ្នកបើកបរ ឬ ភ្នាក់ងារបំរើសេវានៅលើរថយន្ត ឬ ឆូតកាតតាមប្រពន្ធ័អេឡិកត្រូនិក ។
- ករណីមានបណ្ណ័ជិះរថយន្តដោយមិនគិតថ្លៃ អ្នកជិះត្រូវបង្ហាញលិខិតស្នាមដែលពាក់ពន្ធ័ ។ ករណីមានការក្លែងបន្លំ កោសកែបណ្ណ័ ឬ កាន់បណ្ណ័អ្នកដ៏ទៃ អ្នកបើកបរ ឬ ភ្នាក់ងារបំរើសេវា នៃរថយន្តនឹងមិនអនុញ្ញាតអោយឡើងជិះ ព្រមទាំងត្រូវរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ។
- សំបុត្រដែលលក់ចេញ ឬ កាតដែលបានឆូត គឺមិនអាចបង្វិលប្រាក់ត្រលប់វិញបានឡើយ។ ករណីមានការកកស្ទះចរាចរ ឬ មានឧបសគ្គ ឬមានហេតុការណ៍ណាមួយកើតឡើង អ្នកដំណើរត្រូវគោរពតាមការរៀបចំរបស់អ្នកបើកបរ ដើម្បីសាងទៅរថយន្តផ្សេងដែលមានគោលដៅដូចគ្នា ចំពោះថ្លៃជិះរថយន្តដែលបានបង់រួចនៅមានប្រសិទ្ធិភាព ។
- កៅអីនៅលើរថយន្តត្រូវផ្តល់អាទិភាពដល់ជនជរា ជនសុខភាពខ្សោយ ជនពិការ អ្នកមានផ្ទៃពោះ ឬ មានពរកូនតូច ។
- អ្នកជិះរថយន្តទាំងឡាយត្រូវមានសុជីវធម៌ដោយមិនត្រូវយកកៅអីលើស ឬ យកជើងជាន់កៅអី ឬ ស្រែកឡូឡារំខានដល់អ្នកដ៏ទៃ។
- នៅពេលរថយន្តកំពុងធ្វើដំណើរ អ្នកដំណើរមិនអាចលូកដៃ ឬជើងចេញក្រៅរថយន្ត ឬរំខានអ្នកដ៏ទៃឡើយ។
- មុនពេលរថយន្តត្រៀមឈប់ អ្នកជិះរថយន្តមិនត្រូវហក់ឡើង ឬលោតចុះពីរថយន្ត។
- អ្នកជិះរថយន្តមិនត្រូវជក់បារី មិនត្រូវសរសេរ ឬ ខាកស្តោះ ឬ ចោលសំរាម ខាងក្នុង ឬ ខាងក្រៅរថយន្ត ។

- ហាមយកឡើងរថយន្តនូវអាវុធជាតិផ្ទុះ (លើកលែងភ្នាក់ងារមានសមត្ថកិច្ច ) វត្ថុងាយឆេះ ងាយបែក ជាតិពុល របស់គ្រោះថ្នាក់ ឬ របស់មុតស្រួចដែលគ្មានការវេចខ្ចប់ត្រឹមត្រូវ ឬ របស់ធ្វើអោយប៉ះពាល់សុខភាពអ្នកដទៃ។
- អ្នកជិះរថយន្តត្រូវទទួលខុសត្រូវសម្ភារផ្ទាល់ខ្លួនដោយខ្លួនឯង ។
- អ្នកជិះរថយន្តត្រូវសងរាល់ការខូចខាតសម្ភាររថយន្តដែលបង្កដោយសាមីខ្លួនបង្កឡើង ។
- បើមានសភាពដូចខាងក្រោមអ្នកបើកបរ ឬអ្នកបំរើសេវាអាចមិនអនុញ្ញាតឱ្យជិះរថយន្តៈ
    - អ្នកគ្មានសម្លៀកបំពាក់ កុមារក្រោមអាយុ៦ឆ្នាំ ដែលគ្មានអាណាព្យាបាលនៅជាមួយ និងអ្នកវិកលចរិត ដែលគ្មានអ្នកថែទាំ ។
    - អ្នកនាំសត្វចិញ្ចឹម ឬ សត្វរស់ ឬ សាច់ឆៅផ្សេងៗដែលគ្មានការវេចខ្ចប់ឡើងរថយន្ត។
    - អ្នកនាំអីវ៉ាន់ដែលមានទទឹងស្មើមនុស្ស២នាក់ ឬ មានប្រវែងលើស២ម៉ែត្រ ឬ គ្រឿងម៉ាស៊ីនដែលមានទំហំធំហួសកំណត់ ។
    - អ្នកជិះរថយន្តគ្មានឯកសារបញ្ជាក់ ឬសំបុត្រ ឬ បង់ប្រាក់ ឬ ឆូតកាតអេឡិចត្រូនិច ។
- អ្នកដំណើរមានសិទ្ធិប្តឹង ឬរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ចរាល់ទង្វើខុសឆ្គង ដែលអ្នកបើកបរ ឬភ្នាក់ងារបំរើសេវាបានប្រព្រឹត្ត ។
- អ្នកបើកបរ និងអ្នកបំរើសេវាត្រូវរក្សាទុករាល់សម្ភាររបស់អ្នកដំណើរ ដែលភ្លេចនៅលើរថយន្ត និងត្រូវប្រគល់សម្ភារទាំងនោះទៅរដ្ឋាករង់ចាំការដោះស្រាយ ។
- នៅចំណតចុងក្រោយបង្អស់ អ្នកដំណើរត្រូវចុះពីរថយន្ត។
- អ្នកបើកបរ ឬអ្នកបំរើសេវាមានសិទ្ធិឃាត់រាល់ទង្វើទាំងឡាយណាដែលផ្ទុយនឹងវិន័យខាងលើ។

រាជធានី[illegible] ថ្ងៃទី[illegible] ខែឧសភា ឆ្នាំ២០១៦

[illegible]

[illegible]

លេខ ៦០៣/១៦.ឃស

**បានឃើញ និងឯកភាព**

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ប៉ា សុជាតិវង្ស**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈ
រថយន្តក្រុង (City Bus) រាជធានីភ្នំពេញ
លេខ: ១០៦ បប.រ.ដ.ស

## បទបញ្ជាផ្ទៃក្នុង
## របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង

ដើម្បីធានាបាននូវវិន័យ សណ្តាប់ធ្នាប់ របៀបរៀបរយ ក្នុងការអនុវត្តការងារនៅរដ្ឋាករឲ្យបានល្អប្រសើរ និងមានប្រសិទ្ធិភាព អភិបាលរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង សូមដាក់ចេញនូវបទបញ្ជាផ្ទៃក្នុង សំរាប់អនុវត្តដូចតទៅ:

**ប្រការ១:** អំពីម៉ោងពេលក្នុងការបំពេញការងារ :

- បុគ្គលិកការិយាល័យ ត្រូវមកបំពេញការងារ ០៥ថ្ងៃ ក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ និងបំពេញការងារ ០៨ម៉ោង ក្នុងមួយថ្ងៃ :
  - ពេលព្រឹកចាប់ពីម៉ោង ៧.០០នាទី ដល់ម៉ោង ១១.៣០ នាទី ។
  - ពេលល្ងាចចាប់ពីម៉ោង ១៤.០០ ដល់ម៉ោង ១៧.៣០ នាទី ។
- បុគ្គលិកបម្រើសេវា ត្រូវមកបំពេញការងារ ០៧ថ្ងៃ ក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ រួមទាំងថ្ងៃឈប់សំរាកបុណ្យជាតិ លើកលែងតែត្រូវចំថ្ងៃ DAY OFF និងបំពេញការងារ ០៨ម៉ោង ក្នុងមួយថ្ងៃ ចែកចេញជាពីរវេន :
  - វេនព្រឹក ចាប់ពីម៉ោង ៥.០០នាទី ដល់ម៉ោង ១៣.០០ នាទី ។
  - វេនល្ងាច ចាប់ពីម៉ោង ១២.៣០ ដល់ម៉ោង ២០.៣០ នាទី ។

**ប្រការ២:** ក្នុងពេលបំពេញការងារ បុគ្គលិកទាំងអស់ ត្រូវចុះវត្តមានទាំងពេលព្រឹក និងពេលរសៀល ហើយត្រូវចូលបំរើការងារតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៣:** ក្នុងម៉ោងបំពេញការងារ បុគ្គលិកទាំងអស់ត្រូវពាក់ប័ណ្ណសម្គាល់ខ្លួន និងស្លៀកសំលៀកបំពាក់សមរម្យ ឬឯកសណ្ឋានរបស់រដ្ឋាករ។

**ប្រការ៤:** ក្នុងម៉ោងបំពេញការងារ បុគ្គលិកទាំងអស់ មិនត្រូវសេពគ្រឿងញៀន និងគ្រឿងស្រវឹងគ្រប់ប្រភេទ ។

**ប្រការ៥:** មធ្យោបាយធ្វើដំណើរគ្រប់ប្រភេទរបស់បុគ្គលិក ក្នុងនោះ រថយន្តត្រូវមានស្លាកអនុញ្ញាតចេញ-ចូល ម៉ូតូត្រូវមានគ្រប់លក្ខណៈបច្ចេកទេស (កញ្ចក់មើលក្រោយ និងមួកសុវត្ថិភាព) និងត្រូវចតឲ្យមានរបៀបរៀបរយទៅតាមទីកន្លែងកំណត់ ។

**ប្រការ៦:** នៅថ្ងៃឈប់សំរាកផ្លូវការ បុគ្គលិកការិយាល័យ ត្រូវបានប្រគល់ភារកិច្ចបន្ថែមឲ្យនៅប្រចាំការ ២៤ម៉ោង លើ ២៤ម៉ោង ដើម្បីទទួលដោះស្រាយសំណូមពរចាំបាច់បន្ទាន់នានារបស់រដ្ឋាករ ។

**ប្រការ៧:** រាល់ការឈប់សំរាក លើកលែងតែថ្ងៃ DAY OFF បុគ្គលិកទាំងអស់ត្រូវសុំច្បាប់អនុញ្ញាតឲ្យបានត្រឹមត្រូវ ដោយមានការយល់ព្រមពីអភិបាលរដ្ឋាករ ។ ប៉ុន្តែក្នុងករណីសុំច្បាប់ ឬ អវត្តមានរដ្ឋាករនឹងមិនផ្តល់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃជូនឡើយ ។ ការឈប់សំរាកដោយគ្មានការអនុញ្ញាតពី ០១ ទៅ ០២ដង ក្នុងមួយខែ នឹងត្រូវទទួលការស្តីបន្ទោស និងអប់រំ ណែនាំកែលំអ ដោយផ្ទាល់មាត់ពីថ្នាក់ដឹកនាំរដ្ឋាករ ។ ករណីនៅតែប្រព្រឹត្តខុសទៀត ហើយមិនស្តាប់តាមការណែនាំកែលំអខាងលើ នឹងត្រូវទទួលការស្តីបន្ទោសពីក្រុមប្រឹក្សាវិន័យរបស់រដ្ឋាករ ដោយមានកំណត់ហេតុជាលាយល័ក្ខអក្សរ ។ ករណីមិនរាងចាល រដ្ឋាករនឹងបញ្ឈប់ពីការងារ ដោយគ្មានការតវ៉ាអ្វីទាំងអស់ ។

**ប្រការ៨:** បុគ្គលិកទាំងអស់ត្រូវគោរពវិន័យ មានសេចក្តីថ្លៃថ្នូរ មានសីលធម៌រស់នៅល្អ ហ្មឹងម៉ាត់នឹងការងារចេះស្រឡាញ់រាប់អានបុគ្គលិករួមការងារជាមួយគ្នា ដោយរក្សាបាននូវចំណងសាមគ្គីភាព និងទំនាក់ទំនងល្អ រវាងថ្នាក់ដឹកនាំ និងបុគ្គលិកផ្សេងៗទៀត សំដៅធ្វើយ៉ាងណាឲ្យរដ្ឋាករមានកិត្យានុភាពល្អ និងមានជំនឿទុកចិត្តពីអតិថិជន ។

**ប្រការ៩:** បុគ្គលិកទាំងអស់ មិនត្រូវប្រើពាក្យអសុរស ប្រមាថមើលងាយដល់អតិថិជន ឬបុគ្គលិកផ្សេងទៀតឡើយ ។ បុគ្គលិកណាប្រើពាក្យសម្តីអសុរស ឬប្រមាថមើលងាយដល់ជនណាម្នាក់ នឹងត្រូវទទួលការស្តីបន្ទោលពីក្រុមប្រឹក្សាវិន័យរបស់រដ្ឋាករ ដោយមានកំណត់ហេតុជាលាយល័ក្ខអក្សរ ។ ករណីមិនរាងចាល រដ្ឋាករនឹងបញ្ឈប់ពីការងារដោយគ្មានការតវ៉ាអ្វីទាំងអស់ ។

**ប្រការ១០:** បុគ្គលិកទាំងអស់ មិនត្រូវប្រព្រឹត្តសកម្មភាពដូចខាងក្រោម ៖

- ចូលរួមក្នុងសកម្មភាពតវ៉ា ទាមទារ ឬធ្វើបាតុកម្ម របស់គណបក្សនយោបាយណាមួយឡើយ ។
- ធ្វើសកម្មភាពណាមួយដែលមានចេតនារារាំង បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងផលប្រយោជន៍របស់រដ្ឋាករ ។
- កេងប្រវ័ញ្ចប្រាក់របស់រដ្ឋាករ ។
- ប្រើអំពើហិង្សាលើបុគ្គលិកដូចគ្នា និងអតិថិជន ។
- ប្រើប្រាស់សំភារៈរបស់រដ្ឋាករធ្វើជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសផ្សេងៗ ។

- អនុវត្តផ្ទុយពីការណែនាំ គោលការណ៍ និងសេចក្ដីសម្រេចនានា របស់សាលារាជធានីភ្នំពេញ និងរដ្ឋាករ ក្នុងចេតនាបង្កភាពចលាចលក្នុងអង្គភាព ។
- ប្រាប់ការសម្ងាត់ ឬផ្ដល់ឯកសារផ្សេងៗរបស់រដ្ឋាករ ដល់ជនដទៃ ឬនីតិបុគ្គលណាមួយ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ការដឹកនាំ និងកិត្តិយសរបស់រដ្ឋាករ ។

**ប្រការ១១:** បុគ្គលិកដែលបានប្រព្រឹត្តខុសឆ្គងនូវចំណុចណាមួយ ដូចក្នុងប្រការ១០ខាងលើ នឹងត្រូវបញ្ឈប់ការងារពីរដ្ឋាករ ក្នុងករណីធ្ងន់ធ្ងរត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

**ប្រការ១២:** បុគ្គលិករដ្ឋាករទាំងអស់នឹងត្រូវទទួលបានការលើកទឹកចិត្តចំពោះបុគ្គលិកណាដែលបានយកចិត្តទុកដាក់បំពេញការងារ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុង របស់រដ្ឋាករបានល្អ ។

**ប្រការ១៣:** ករណីបុគ្គលិកទាំងអស់អនុវត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងនេះ នឹងត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋាករ និងច្បាប់ជាធរមាន ។៚

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែឧសភា ឆ្នាំ២០១៦

[illegible]ដ្ឋាករ

វ៉ែន សុឃីម

លេខ ១០៤/១៦ ឋន

**បានឃើញ និងឯកភាព**

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ប៉ា សុជាតិវង្ស**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
លេខ: ០១០/១៨/ សជណ

ថ្ងៃអាទិត្យ ៣ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការគេហទំព័រ (Website) របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យជ្រាបថា ដើម្បីមានភាពងាយស្រួល ក្នុងការទទួលសំណើ សំណូមពរ មតិយោបល់នានា និងការផ្តល់ព័ត៌មាន នៃសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុងជូនបងប្អូនប្រជាពលរដ្ឋ ព្រះសង្ឃ ចាស់ជរា ជនពិការ កុមារ សិស្ស និស្សិត កីឡាករ កីឡាការិនី គ្រូបង្រៀន និងបងប្អូនកម្មករ កម្មការិនីទាំងអស់ រដ្ឋបាលរាជធានីភ្នំពេញ នឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការគេហទំព័រ ( Website ) របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ដែលមានឈ្មោះថា " www.phnompenhcitybus.gov.kh " ចាប់ពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៨ តទៅ ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ ព្រះសង្ឃ ចាស់ជរា ជនពិការ កុមារ សិស្ស និស្សិត កីឡាករ កីឡាការិនី គ្រូបង្រៀន និងបងប្អូនកម្មករ កម្មការិនីទាំងអស់ មេត្តាជ្រាប និងចូលរួមប្រើប្រាស់គេហទំព័រ ( Website ) ខាងលើដើម្បីទទួលព័ត៌មានអំពីសេវាកម្ម និងដំណឹងផ្សេងៗបានទាន់ពេលវេលារបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ។

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គណៈកម្មាធិការសម្របសម្រួលរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- សាលាខណ្ឌទាំង១២
- គ្រប់ស្ថានីយវិទ្យុ និងទូរទស្សន៍
  "ដើម្បីចូលរួមផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

ឃួង ស្រេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ

# សេចក្តីជូនដំណឹង

សាលារាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីបន្តនិរន្តភាព នៃការបំពេញសេវាដឹកជញ្ជូនសាធារណៈជូនប្រជាពលរដ្ឋ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរបស់សាលារាជធានីភ្នំពេញ នឹងដាក់ឲ្យដំណើរការបំរើសេវាដឹកជញ្ជូន ជូនប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ តាមកាលបរិច្ឆេទ និងបណ្តាញខ្សែរត់ ដូចខាងក្រោម ៖

១. **ខ្សែទី១** ចាប់ផ្តើមនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ ពីម៉ោង ០៥:៣០នាទី ដល់ម៉ោង ២០:៣០នាទី ដោយចេញដំណើរពីចំណតគីឡូម៉ែត្រលេខ៩ តាមផ្លូវជាតិលេខ៥ រង្វង់មូលស្ពានចាស់ មហាវិថីព្រះមុនីវង្ស ស្ពានព្រះមុនីវង្ស ឆ្ពោះទៅផ្លូវជាតិលេខ១ រហូតដល់ចំណតរថយន្តបឹងឈូក រួចត្រឡប់មកវិញ ។ នៅខ្សែទី១នេះ បានកំណត់ចំណតរថយន្តក្រុងឈប់ (Bus Stop) ចំនួន ៦៧ ចំណត។

២. **ខ្សែទី២** ចាប់ផ្តើមនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៤ ពីម៉ោង ០៥:៣០នាទី ដល់ម៉ោង ២០:៣០នាទី ដោយចេញដំណើរពីចំណតផ្សាររាត្រី វិថីព្រះស៊ីសុវត្ថិ ស្ពានជ្រោយចង្វារ រង្វង់មូលស្ពានចាស់ ផ្លូវលេខ៧០ ផ្លូវលេខ២៧៣ អង់តែនទួលគោក មហាវិថីគីមអ៊ីលស៊ុង មហាវិថីម៉ៅសេទុង ភ្លើងស្តុបឬកគោ មហាវិថីព្រះមុនីវង្ស ឆ្ពោះទៅផ្លូវជាតិលេខ២ រហូតដល់រង្វង់មូលតាខ្មៅ រួចត្រឡប់មកវិញ។ នៅខ្សែទី២នេះ បានកំណត់ចំណតរថយន្តក្រុងឈប់ (Bus Stop) ចំនួន ៦៨ ចំណត។

៣. **ខ្សែទី៣** ចាប់ផ្តើមនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ ពីម៉ោង ០៥:៣០នាទី ដល់ម៉ោង ២០:៣០នាទី ដោយចេញដំណើរពីចំណតផ្សាររាត្រី ផ្លូវលេខ១០៦ តាមវិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី មហាវិថីកម្ពុជាក្រោម ក្រោមស្ពានអាកាស៧មករា មហាវិថីសហព័ន្ធរុស្ស៊ី ព្រលានយន្តហោះអន្តរជាតិភ្នំពេញ រហូតដល់រង្វង់មូលចោមចៅ រួចត្រលប់មកវិញ។ នៅខ្សែទី៣នេះ បានកំណត់ចំណតរថយន្តក្រុងឈប់ (Bus Stop) ចំនួន ៥៩ ចំណត។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមសាធារណៈជនទាំងអស់មេត្តាជ្រាប និងចូលរួមធ្វើដំណើរឲ្យបានច្រើនកុះករតាមរថយន្តក្រុងរបស់លោកអ្នកប្រកបដោយផាសុខភាព និងសុវត្ថិភាព ដើម្បីចូលរួមកាត់បន្ថយនូវការកកស្ទះចរាចរណ៍ ការគ្រោះថ្នាក់ចរាចរណ៍ និងការបំពុលបរិស្ថាន ក្នុងរាជធានីភ្នំពេញ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៤

**សាលារាជធានីភ្នំពេញ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- សាលាខណ្ឌទាំង១២
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ

"ដើម្បីអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

"ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ២២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
លេខ ០៤០/១៧ សជណ

រាជធានីភ្នំពេញ , ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

-យោងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ ។

រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់បងប្អូនកម្មករ កម្មការិនីទាំងអស់អោយបានជ្រាបថា ដើម្បីជួយសម្រួលដល់ការចំណាយលើមធ្យោបាយធ្វើដំណើរប្រចាំថ្ងៃ សំដៅលើកកម្ពស់ជីវភាពប្រចាំថ្ងៃរបស់បងប្អូននោះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** អនុញ្ញាតឱ្យបងប្អូនកម្មករ កម្មការិនីទាំងអស់ ជិះរថយន្តក្រុងគ្រប់ខ្សែរត់ក្នុងរាជធានីភ្នំពេញ របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ដោយមិនគិតតម្លៃសេវា ( Free ) រយៈពេល ០២ឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៧ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ដោយគ្រាន់តែបង្ហាញកាតធ្វើការងារនឹងទទួលបានសេវានេះភ្លាម ។

ទន្ទឹមនឹងនេះ ដើម្បីឆ្លើយតបនឹងសំណូមពរ ក៏ដូចជាសេចក្តីត្រូវការលើសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង របស់ប្រជាពលរដ្ឋ ព្រះសង្ឃ ចាស់ជរា ជនពិការ កុមារ សិស្ស និស្សិត និងបងប្អូនកម្មករ កម្មការិនីទាំងអស់ រដ្ឋបាលរាជធានីភ្នំពេញនឹងកែសម្រួលគម្រោយផ្លូវ នៃខ្សែរត់ចាស់ ព្រមទាំងដាក់អោយដំណើរការខ្សែរត់ថ្មីរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ដូចខាងក្រោម ៖

**១-ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៧**

ក-<u>ការកែសម្រួលគម្រោយផ្លូវ នៃខ្សែរត់ចាស់</u> :

- **ខ្សែរត់ទី២** : ចេញពីចំណតរថយន្តផ្សារអ៊ីអន២ តាមផ្លូវឧកញ៉ាម៉ុងឬទ្ធី រង្វង់មូលកាំកូស៊ីធី រង្វង់មូលអង់តែនទួលគោក ផ្លូវលេខ៧០ រង្វង់មូលក្បាលថ្នល់ ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ស្ពានអាកាសក្បាលថ្នល់ ផ្លូវជាតិលេខ២ ដល់ក្រុងតាខ្មៅ ខេត្តកណ្តាល ។
- **ខ្សែរត់ទី៣** : ចេញពីចំណតសួនច្បារឬស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលក្បាលកាណុង ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី មហាវិថីកម្ពុជាក្រោម ស្ពានអាកាស៧មករា មហាវិថីសហព័ន្ធរុស្ស៊ី រង្វង់មូលចោមចៅ ផ្លូវជាតិលេខ៣ ដល់ចំណតបុរីសន្តិភាព២ ។

ខ-<u>ដាក់អោយដំណើរការគម្រោយផ្លូវថ្មី</u> :

- **ខ្សែរត់ទី៤A** : ចេញពីចំណតសួនច្បារឬស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលក្បាលកាណុង ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក វិថីព្រះមុនីវង្ស កាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវវែងស្រេង ស្តុបអាងទឹកកាណាឌីយ៉ា ផ្សារទួលពង្រ ដល់ចំណតបុរីសន្តិភាព២ ។
- **ខ្សែរត់ទី៤B** : ចេញពីចំណតសួនច្បារឬស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលក្បាលកាណុង ផ្លូវលេខ៤៧ វត្តភ្នំ វិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក វិថីព្រះមុនីវង្ស កាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវវែងស្រេង រង្វង់មូលចោមចៅ ផ្លូវជាតិលេខ៤ ដល់តំបន់សេដ្ឋកិច្ចពិសេស ។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៩ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- **ខ្សែរត់ទី៥** : ចេញពីចំណុចផ្សារអ៊ីអន២ តាមផ្លូវលេខ១០០៣ បត់ឆ្វេងតាមផ្លូវលេខ១៩៦៦ ឆ្ពោះទៅផ្លូវលេខ៥៩៨ ផ្លូវលេខ៣៣៧ បត់ស្ដាំតាមផ្លូវលេខ៥៦៦ សាលាបឋមសិក្សាពៅអ៊ុំ ទួលគោក វិថីគីមអ៊ីលស៊ុង កាត់ក្រោមស្ពានអាកាស៧មករា មហាវិថីម៉ៅសេទុង ស្តុបឬកគោ ស្តុបផលផល វិថីសុធារស ដល់ចំណុចផ្សារអ៊ីអន១ ។

**២-ថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៧** :

- **ខ្សែរត់ទី៦** : ចេញពីចំណុចផ្សារបុរីរុងរឿង ផ្លូវជាតិលេខ៦ ស្ពានជ្រោយចង្វារ រង្វង់មូលក្បាលកាណុង ផ្លូវលេខ៧០ រង្វង់មូលអង់តែនទួលគោក រង្វង់មូលកាំកូស៊ីធី ផ្លូវឧកញ៉ាម៉ុងឬទ្ធី ផ្លូវសម្ដេច ជា ស៊ីម បត់ឆ្វេងតាមផ្លូវឧកញ៉ា ទ្រី ហេង ដល់មហាវិថីសហព័ន្ធរុស្ស៊ី បត់ឆ្វេងឆ្ពោះទៅដល់ចំណុចផ្សារសេនជូវីផ្លាហ្សា ។
- **ខ្សែរត់ទី៧A** : ចេញពីចំណុចគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ផ្លូវលេខ៥៩៨ ស្ពានអាកាស៧មករា ផ្លូវលេខ២៧១ បត់តាមស្ពានអាកាសស្ទឹងមានជ័យ វិថីព្រះមុនីវ៉េត វិថីព្រះសីហនុ វិថីព្រះសុធារស ដល់ចំណុចផ្សារអ៊ីអន១ ។
- **ខ្សែរត់ទី៧B** : ចេញពីចំណុចគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ ផ្លូវលេខ៥៩៨ ស្ពានអាកាស៧មករា ផ្លូវលេខ២៧១ កាត់ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវលេខ២៧១ ស្តុបក្បាលថ្នល់ ឆ្លងកាត់ស្ពានព្រះមុនីវង្ស ដល់ចំណុចច្បារអំពៅ ។
- **ខ្សែរត់ទី៨** : ចេញពីចំណុចគីឡូម៉ែត្រលេខ៩ ផ្លូវជាតិលេខ៥ កាត់ស្ពានព្រែកព្នៅ ផ្លូវឧកញ៉ាលី យ៉ុងផាត់ ផ្លូវជាតិលេខ៦អា ដល់ចំណុចផ្សារបុរីរុងរឿង ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ ព្រះសង្ឃ ចាស់ជរា ជនពិការ កុមារ សិស្ស និស្សិត និងបងប្អូនកម្មករ កម្មការិនីទាំងអស់ជ្រាប និងចូលរួមជិះរថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ នៃរដ្ឋបាលរាជធានីភ្នំពេញ ប្រកបដោយសុវត្ថិភាព និងផាសុកភាព ។

ទទួលបានសេចក្ដីជូនដំណឹងនេះ រដ្ឋបាលខណ្ឌទាំង១២ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង និងមន្ទីរ អង្គភាពពាក់ព័ន្ធត្រូវអនុវត្តសេចក្ដីជូនដំណឹងនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**<u>កន្លែងទទួល</u>**:

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
"ដើម្បីជូនជ្រាប"
-គ្រប់ស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយ
"ដើម្បីជួយផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
លេខ: ០៤០ ២៨ សជណ

# សេចក្ដីជូនដំណឹង

អនុវត្តតាមប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា៖ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលនឹងឈានចូលមកដល់នាពេលខាងមុខនេះ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) រាជធានីភ្នំពេញ នឹងបម្រើសេវាដឹកជញ្ជូនសាធារណៈក្នុងរាជធានីភ្នំពេញ តាមខ្សែរត់ដែលមានស្រាប់ ចំនួន ០៨ខ្សែ ជូនបងប្អូនប្រជាពលរដ្ឋទាំងអស់ដោយមិនគិតកម្រៃសេវា រយៈពេលបីថ្ងៃ គឺចាប់ពីថ្ងៃទី១៤-១៥-១៦ ខែមេសា ឆ្នាំ២០១៨។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ជ្រាប និងចូលរួមធ្វើដំណើរតាមរថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង ( City Bus ) រាជធានីភ្នំពេញ ប្រកបដោយសុវត្ថិភាព និងផាសុខភាព។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៨
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
-គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
"ដើម្បីផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
លេខ: ៣៤៧៨

# សេចក្តីជូនដំណឹង

អនុវត្តតាមប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា៖ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលនឹងឈានចូលមកដល់នាពេលខាងមុខនេះ រដ្ឋបាលរាជធានីភ្នំពេញ នឹងរៀបចំរថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ដែលមានស្លាកសញ្ញា "រាជធានីភ្នំពេញ" ចំនួន ៦០គ្រឿង ដើម្បីបម្រើសេវាដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋពីរាជធានីភ្នំពេញ ទៅតាមបណ្តាខេត្តមួយចំនួន **ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨** ***ដោយមិនបង់ប្រាក់***។

ចំពោះកន្លែងរថយន្តក្រុងចេញដំណើរ រដ្ឋបាលរាជធានីភ្នំពេញនឹងរៀបចំជូនបងប្អូនប្រជាពលរដ្ឋ ចំនួន ០៣ទីតាំង ដូចខាងក្រោម៖

- **ទីតាំងទី១** : នៅមហាវិថី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** (ផ្លូវ៦០ម៉ែត្រ) ទល់មុខក្រុមហ៊ុន ម៉ែកស៊ីដែស បិន (Mercedes Benz) ដោយចូលតាមផ្លូវមុខវត្តចាក់អង្រែក្រោម ចំងាយប្រមាណ ៧០០ម៉ែត្រ ឬចូល តាមមហាវិថីព្រះមុនីវង្ស ទៅមហាវិថី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមាណ ១.៥០០ម៉ែត្រ សម្រាប់បងប្អូនប្រជាពលរដ្ឋដែលត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ១ ឆ្ពោះទៅខេត្ត កណ្តាល ព្រៃវែង និង ខេត្តស្វាយរៀង។
- **ទីតាំងទី២** : នៅចំណតសួនឫស្សីកែវ (ទីលានប្រជាធិបតេយ្យថ្មី) ផ្លូវជាតិលេខ៥ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ សម្រាប់បងប្អូនប្រជាពលរដ្ឋ ដែលត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៥ ឆ្ពោះទៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ ។
- **ទីតាំងទី៣** : នៅចំណុចប្រសព្វរវាងផ្លូវជាតិលេខ៤ និងមហាវិថីឈ្នះឈ្នះ (កប់ស្រូវ) សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ សម្រាប់បងប្អូនប្រជាពលរដ្ឋ ដែលត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៥ ឆ្ពោះទៅខេត្ត កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាប និងចូលរួមធ្វើដំណើរតាមរថយន្តក្រុងរបស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ ប្រកបដោយសុវត្ថិភាព និងជាសុភភាព។

ថ្ងៃ អាទិត្យ ១៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៨
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

ឃួង ស្រេង

**កន្លែងទទួល៖**
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
"ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ២

# រូបភាព

## កាតពណ៌បៃតង




## កាតពណ៌ខៀវ



# ប្រភេទឡានក្រុង






# ផែនទីបង្ហាញផ្លូវឆ្នាំ
# ២០១៨

# ផែនទីគំរាយផ្លូវខ្សែរត់ទី១(A)

ខ្សែA (ខ្សែបៃតង)៖ចាប់ផ្តើមពីចំណតគីឡូម៉ែតលេខ៩ កាត់តាមផ្លូវជាតិលេខ៥, មហាវិថីព្រះមុនីវង្ស, កាត់តាមផ្លូវជាតិលេខ១រហូតដល់វត្តភ្នំតាកុយ ហើយត្រលប់មកវិញ

០១/០៩/២០១៩




រាជធានី ភ្នំពេញ

https://www.facebook.com/ppcityhall

# ផែនទីតំរាយផ្លូវខ្សែរត់ទី២(B)




ខ្សែ(B) (ខ្សែក្រហម)៖ចាប់ផ្តើមពីផ្សាររាត្រី បត់ក្រោមស្ពានជ្រោយចង្វា ឆ្ពោះទៅអង់តែនទួលគោកតាមផ្លូវទំនប់ទួលគោក កាត់ផ្លូវលេខ២៨៩,កាត់តាមមហាវិថីម៉ៅ សេទុងដល់ស្តុបបូកគោ ,បត់តាមវិថីព្រះមុនីវង្ស,កាត់តាមផ្លូវជាតិលេខ២ ឆ្ពោះទៅតាខ្មៅហើយត្រលប់មកវិញ


Page: រាជធានី ភ្នំពេញ
https://www.facebook.com/ppcityhall

# ផែនទីគំរាយផ្លូវខ្សែរត់ទី៣(C)

ខ្សែC (ខ្សែខៀវ)៖ចាប់ផ្ដើមពីផ្សាររាត្រី បត់តាមផ្លូវលេខ១០៦, បត់តាមវិថីព្រះនរោត្តម,កាត់តាមផ្លូវលេខ១៣០,កាត់តាមផ្លូវកម្ពុជាក្រោម,ឆ្ពោះទៅមហាវិថីសហព័ន្ធរុស្ស៊ី,ឆ្ពោះទៅរង្វង់មូលចោមចៅ ហើយត្រលប់មកវិញ





Page: រាជធានី ភ្នំពេញ
https://www.facebook.com/ppcityhall

# ផែនទីបង្ហាញផ្លូវឆ្នាំ
# ២០១៧

# ផែនទីគម្រោងផ្លូវរថយន្តក្រុង ដំណាក់កាលទី១ ឆ្នាំ ២០១៧




បានឃើញ និងបញ្ជូនមក ឯកឧត្តម
អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ មេត្តាពិនិត្យ និងសំរេច។
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ សីហា ឆ្នាំ ២០១៧
ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
សំ ពិសិដ្ឋ

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ សីហា ឆ្នាំ ២០១៧
អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ
ឃួង ស្រេង

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ សីហា ឆ្នាំ ២០១៧
អភិបាលរង
ទិន_សុឃើម

# ផែនទី តម្រាយផ្លូវរត់របស់រថយន្តដឹកជញ្ជូនសាធារណៈ
# រថយន្តក្រុងរាជធានីភ្នំពេញ





ផែនទីខ្សែទី ១
G01 គីឡូម៉ែត្រលេខ៩
Kilometer N°9
G02 សាលាបឋមសិក្សាតេជោសែនច្រាំងចំរេះ
Hun Sen Chrang Chamreh Primary School
G03
G04 សាលាខណ្ឌឫស្សីកែវ
Salar Khan Rusey Keo
G05
G06 មណ្ឌលសុខភាពសម្តេចឪ
Samdach Ouv Health Center
G07 មណ្ឌលសុខភាពសម្តេចឪ
Samdach Ouv Health Center
G08 វិទ្យាល័យឫស្សីកែវ
Russey Keo Secondary School
G09 វិទ្យាល័យឫស្សីកែវ
G10 សួនច្បារឃ្លាំងសូគីមិច
Sokimix Park
G11 សួនច្បារឃ្លាំងសូគីមិច
G12 គ្លីនិចរ៉ាក Clinic Rak
G13 គ្លីនិចរ៉ាក
G14 ភូមិសាមគ្គី Samaki Village
G15 ភូមិសាមគ្គី
Samaki Village
G16 សាលាបឋមសិក្សាពញាក្រែក
Ponheakaek Primary School
G17 សាលាបឋមសិក្សាពញាក្រែក
G18 មណ្ឌលសុខភាពដូនពេញ
Donpenh Health Center
G19 មណ្ឌលសុខភាពដូនពេញ
G20 រង្វង់មូលស្តាតចាស់ Old Stadium roundabout
G21 រង្វង់មូលស្តាតចាស់
G22 ពេទ្យកាល់ម៉ែត Callemet Hospital
G23 ពេទ្យកាល់ម៉ែត
G24 ក្រសួងពត៌មាន
G25 ក្រសួងពត៌មាន
Ministry of Information
G26 សាលាពេទ្យ Medical University
G27 សាលាពេទ្យ
G28 ស្តុបឃរកាសBKC
G29 ស្តុបឃរកាសBKC
BKC Intersection
G30 ផ្សារធំថ្មី Central Market
G31 ផ្សារធំថ្មី
G32 ស្តុបសណ្ឋាគារស White Hotel
G33 ស្តុបសណ្ឋាគារស White Hotel
G34 វត្តកោះ
G35 វត្តកោះ Wat Koh
G36 ស្តុបផ្លូវអាចារ្យស្វា Monivong\Road 214
G37 ស្តុបផ្លូវអាចារ្យស្វា
G38 ស្តុបពេទ្យចិន Monivong\Sihanouk
G39 ស្តុបពេទ្យចិន
G40 ផ្លូវមុនីវង្សកែងផ្លូវ២៩៤ Monivong\Road 294
G41 ផ្លូវមុនីវង្សកែងផ្លូវ២៩៤
G42 ស្តុបមេភ្លើង Monivong\Road 360
G43 ស្តុបមេភ្លើង
G44 ស្តុបបូកគោ Monivong\Mao Tse Tong
G45 ស្តុបបូកគោ
G46 ក្រសួងរៀបចំដែនដី
Ministry of Land Management
G47 ក្រសួងរៀបចំដែនដី
G48 សាលាច្បាប់ Law University
G49 សាលាច្បាប់
G50 សាលាបឹងត្របែក
Boeung Trabek Highschool
G51 សាលាបឹងត្របែក
Boeung Trabek Highschool
G52 ស្ថានីយ៍ឧតុនិយម
G53 ស្ថានីយ៍ឧតុនិយម
Meteology Station
G54
G55 ស្ពានអាកាសក្បាលថ្នល់
Monivong Flyover
G56
G57
G58
G59
G60
G61 វិទ្យាល័យហ៊ុន សែនច្បារអំពៅ
Hun Sen Chbar Ampov Secondary School
G62
G63 ប៊ូរីប៉េង ហួត
G64
G65 មន្ទីរពេទ្យ ចោង
G66
ចំណតយានយន្ត ឧញ៉ា ស៊ុយ សុផាន
ផ្សារច្បារអំពៅ
Chbar Ampov
ស្ថានីយប្រេងកាល់តិច



ផែនទីខ្សែទី ២
01 Aeon 2 Super Market
03 Borey New World
02 Borey New World
05 St. Oknha Mong Rithy/St.1003
04 St. Oknha Mong Rithy/1003
07 08
10 Japan Institute
06
09 11
12 Camko city Roundabout
13
15
14 Toul Kok TVK Station
17
18 Beijing International Academy
16 Toul Kok 2 Pumping Station
19 21
20 Old Stadium
22 Ministry of Women affair
23 Ministry of Women affair
24 National Maternal and Child Health Center
25 National Maternal and Child Health Center
26
27 Kantha Bopha IV Children's Hospital
28 Central Market
29 Central Market
30 ANTI-CORRUPTION UNIT
31 ANTI-CORRUPTION UNIT
32 Chaktomuk Secondary School
33 Chaktomuk Secondary School
34 National Institute of Education
35 National Institute of Education
36 Red Cross Stop
37 Red Cross Stop
38 Mong Riththy Group
39 Mong Reththy Group
40 Thann Pagoda
41 Thann Pagoda
42 Ministry of Agriculture Forestry and Fisheries
43 Ministry of Agriculture Forestry and Fisheries
44 Ministry of Interior
45 Ministry of Interior
46 Ministry of Culture and Fine Arts
47 Ministry of Culture and Fine Arts
48 Kbar Tnol Maket
49
50 Chakangreleour Pagoda
51
52 CPAC
53 CPAC CPAC Concrete Plant
54
55
56 Hun Sen Chakangre Secondary School
57
58 HC University
59
60 Rokar Village
61 Rokar Village
62 Chakangre Krom Electricity
63
64 Chakangre Krom
65
66 Chakangre Krom Center
67
68 Preah Norcay Roundabout
69
R70 Department of Public Works of Kandal Province
71 Takmao Municipality
72 Takmao Brigde
73 Takmao Market
74 Takmao Culture Department
75 Takmao Roundabout



ផែនទីខ្សែទី ៣
Rusey Keo Garden
01
02 Clinic Rak
03 Clinic Rak
04 Modern 5
05 Modern 5
06
07 Ponheakaek Primary School
08
09 Donpenh Health Center
10 Old Stadium roundabout
11
12 Ministry of Women affair
13
14
15
16 Kantha Bopha IV Children's Hospital
17 Kantha Bopha IV Children's Hospital
18
19 Ang Duong Hospital
20 Central Market
21 Central Market
22 Kampuchea Krom Intersection
23
24 Sydney Super Market
25
Nam Ching Intersection 27
26 Nam Ching Intersection
DN Intersection 28
29 DN Intersection
Le President Hotel 30
31 Le President Hotel
Santhor Muk Primary School 32
33 Santhor Muk Primary School
261 Intersection 34
35 261 Intersection
7Makara Over Fly 36
37 7Makara Over Fly
Boyoung Town 38
39 Boyoung Town
Phnom Penh Water Park 40
41 Phnom Penh Water Park
Tuek Thla Pagoda 42
43 Tuek Thla Pagoda
Hun Sen Baurei 100 Khnang Primary School 44
45 Hun Sen Baurei 100 Khnang Primary School
46
47 Pochentong Restaurant
Hun Sen Pochentong Primary School 48
49 Hun Sen Pochentong Primary School
Plaza Market 51
50 Plaza Market
Sangkat Kakab 53
52 Sangkat Kakab
Pochentong International Airport 55
54 Pochentong International Airport
Prince Town 57
56 Prince Town
58 Dong Nangkol
Dong Nangkol 59
Sophea Khun Pagoda 60
61 Sophea Khun Pagoda
62 Chom Chav Roundabout
Chom Chav Roundabout 63
64
65
66
M.K Steel Factory 67
68
Koma Vision Center 69
70
Chunlung Malu Pagoda 71
72
73
74

# ផែនទីខ្សែទី ៤


01 Rusey Keo Garden
02 Clinic Rak
03 Clinic Rak
04 Modern 5
05 Modern 5
06
07 Ponheakaek Primary School
08
09 Donpenh Health Center
10 Old Stadium roundabout
11
12 Ministry of Women affair
13
14
15
16
17 Kantha Bopha IV Children's Hospital
18
19 Ang Duong Hospital
20 Central Market
21 Central Market
22 Soriya Cinima
23 Soriya Cinima
24 Angkor Cinima
25 Angkor Cinima
26 Orussey Market
27 Orussey Market
28 Preah Puth Mean Bon Pagada
29 Preah Puth Mean Bon Pagada
30 City Mall
31 City Mall
32 Leang Heng Bookshop
33 Beltei International School
34 International Olympic School
35 International Olympic School
36 Intercontinental Hotel
37 Chenla Theatre
38 Steung Meanchey Sky Bridge
39
40 Steung Meanchey Pagada
41 Steung Meanchey Primary School
42 Steung Meanchey Market
43
44 National Institute of Business
45 Nonmony Pagoda
46 Monor Rom Restaurant
47
48
49
50 Aek Reach III Market
51 Ekreach III Market
52 Vattanac Bank Stung Meanchey Branch
53 Vattanac Bank Stung Meanchey Branch
54 Canadia Market
55 Canadia Market
56 Canadia Water Supply
57 Canadia Water Supply
58 Garment Factory Quality Textile Co,. Lte
59 Borey New World
60 6 Floors Factory
61 Tuol Pongro Market
62 Canacity Market
63 Borey SJSI
64 Phum Chrey Kaong
65 Phum Chrey Kaong
65 Kampaeng Pagoda
66
67 Preah Thom Trai Pagoda
68 Chom Chao Market
69 Chom Chao Market
69 General Fatory
70 Son Ti Pheap II Bus Terminal
70
71
72
73 Hun Sen Champuvoin High School
74 Tech Srun Dry Port
75 Tech Srun Dry Port
76 Road Construction Center
77 Road Construction Center
78 Odem Primary School
79 Odem Primary School
80 Odem New Town
81 Odem New Town
82
83 Extraordinary Chambers in the Courts of Cambodia
84 Kambol Pagoda
85 Konthok Primary School
86 Royal Gendarmerie School



ផែនទីខ្សែទី ៥
01 Aeon 2 Supper Market
02 Borey New World
03 Borey New World
04 Borey New World Intersection
05 Borey New World Intersection
06 K Mart
07 K Mart
08 Western Stadium
09
10 Eagle Coffee
11
12
13 Borey Sun World
14
15 Western International School
16 Zaman International Primary School
17 Zaman International Primary School
18 National Institute of Public Health
19 National Institute of Public Health
20 Institute of Technology
21 Institute of Technology
22 Santhor Muk Primary School
23 Santhor Muk Primary School
24 Mondial Center
25 Mondial Center
26 Daeum Kor Market
27 Daeum Kor Market
28 Sunsimexco Company
29 Sunsimexco Company
30 Vannda Institute
31 Vannda Institute
32 American Intercon Institute
33 American Intercon Institute
34 Tuol Tompoung Pagoda
35 Tuol Tompoung Pagoda
36 Bokor Stop
37 Bokor Stop
38 Eton House International School
39 Eton House International School
40 Ministry of Agriculture Forestry and Fisheries
41
42
43 Hotel Sofitel Phnom Penh Phokeethra
44 Aeon Mall 1



ផែនទីខ្សែទី ៦
Borey Rung Roeung
01
02
03 Guest house Heng Mohasal
04 Guest house Khsach Meas
05 Guest house Khsach Meas
06 Pizza Company
07 Pizza Company
08 Vivo
09 Vivo
10 Kado Restaurant
11 Amret Microfinance
12 Asia Pacific International School
13 Asia Pacific International School
14 Kean Khlang Pagoda
15 Kean Khlang Pagoda
16 ATIKER Company
17 ATIKER Company
18 JVC Technical School & Workshop
19 JVC Technical School & Workshop
រង្វង់មូលស្តាតចាស់ 20
Old Stadium Roundabout
21 រង្វង់មូលស្តាតចាស់
Old Stadium Roundabout
22 Beijing International School
23 Beijing International School
24 Toul Kok Pump Station
25 Toul Kok Pump Station
26 Toul Kok TVK Station
27 Toul Kok TVK Station
28 Camko City Roundabout
29 Camko City Roundabout
30 Japan International Institute by LACP
31 Japan International Institute by LACP
32 Borey Peng Huot
33 Borey Peng Huot
34 Brown Cafe
35 Brown Cafe
36 Secondary School of Fine Arts
37 Secondary School of Fine Arts
38 Borey Chip Mong Land
39 Borey Chip Mong Land
40 Ly Heang Gas Station
41 Ly Heang Gas Station
42 Green Feed Group
43 Green Feed Group
44 Borey Thai Chhun Kry
45 Borey Thai Chhun Kry
46 Jinh Fu Restuarant
47
48 Phnom Penh Municipal Health Department
49
KTV 50
51 Borey Varina
Borey New world 52
53 Borey New world
LHR Gas Station LHR 54
55 LHR LHR Gas Station
Relax Club 56
57
58 Century Plazza Market



ផែនទីខ្សែទី ៧
01 Kilometer N°9
02 K.M 9 Islamic Church
04 Tela 598
06 Peng Huot Str. 598
GENERAL DEPARTMENT OF PUBLIC WORK AND TRANSPORT
12 Happy Garage II
13 Happy Garage II
14 LHR Petrol station
15 LHR Petrol station
16 The Terrace Restaurant
17 The Terrace The Terrace Restaurant
18 K-fix Company
19 K-fix Company
20 TV 3
21 TV 3
22 Tela Rithy Petrol Station
23 Tela Rithy Petrol Station
24 GOGO International School
25 GOGO International School
Bodamic Company 26
27 Bodamic Company
Borey Peng Huot Head Office 28
29 Borey Peng Huot Head Office
30 RooY7 Sport Club and Minibare
31 Freshen Mall
LG Company 32
33 LG Company
34 Best Star KTV
35 Best Star KTV
36 Korean School (KLC)
37 Hun Sen Library
38 7Makara Skyway
39
40 Arunreas Hospital
42 Cambodian Mekong University
44 General Department of Agriculture
46 Chea Sim Samki High School
48 Steung Meanchey Sky Bridge Str. 271
50 Sovanna Supper market
51 Sovanna Supper market
Khmer Soviet Friendship Hospital 52
AMK Micro Finance 54
55 AMK Micro Finance
Phnom Penh Sport Club 56
57 Phnom Penh Sport Club
58 Dubai KTV
59 Dubai KTV
60 British Cambodian International School
Hun Neang Primary School 62
64
Monivong Flyover
66
67
68 Chbar Ampov Bus Terminal
Khmer Nation Law Group
Samaky Kindergaten
Depo Market
Preah Puth Mean Bon Pagoda
Str. Tep Phon/Str. 167
Orussey market
Monivong/Str. 214
Monivong/Sihanouk
Kasikorn Bank 60
62
DFDL 64
KTV X2 67
65 DFDL Copany
66 KTV X2
68 Aeon Mall
Monivong/Str. 214
Monivong/Sihanouk
Kasikorn Bank
National Institute of Education


ផែនទីខ្សែទី ៩
56 ច្រកចូលខាងមុខតំបន់សេដ្ឋកិច្ចពិសេស (ផ្លូវជាតិលេខ៤)
Special Economic Zone Entrance/ National Road 4
ធនាគារអេស៊ីលីដា 55
Acleda Bank
54 ធនាគារអេស៊ីលីដា
Acleda Bank
ក្រុមហ៊ុនដេនសូ 53
Denso (Cambodia) Co., Ltd
52 ក្រុមហ៊ុនដេនសូ
Denso (Cambodia) Co., Ltd
ការិយាល័យរដ្ឋបាល 51
តំបន់សេដ្ឋកិច្ចពិសេស
Special Economic Zone Office
50 ការិយាល័យរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស
Special Economic Zone Office
ក្រុមហ៊ុនមេឌីប្រូ 49
Medipro (Cambodia) Co., Ltd
48 ក្រុមហ៊ុនមេឌីប្រូ
Medipro (Cambodia) Co., Ltd
ក្រុមហ៊ុនរ៉ុកកូភីនិច 47
Rokko Phoenix Co., Ltd
46 ក្រុមហ៊ុនរ៉ុកកូភីនិច
Rokko Phoenix Co., Ltd
ក្រុមហ៊ុនយូរ៉ូស្តារ ដាយម៉ុន 45
Eurostar Diamonds
(Cambodia) Co., Ltd
44 ក្រុមហ៊ុនយូរ៉ូស្តារ ដាយម៉ុន
Eurostar Diamonds
(Cambodia) Co., Ltd
ក្រុមហ៊ុនមេហ្គាឡេបល ស្ទីកឃ័រ 43
Mega Labels & Stickers
(Cambodia) Co., Ltd
42 ក្រុមហ៊ុនមេហ្គាឡេបល ស្ទីកឃ័រ
Mega Labels & Stickers
(Cambodia) Co., Ltd
ក្រុមហ៊ុននិក្កូ គីនហ្សូកូ 41
Nikko-Kinzoku
(Cambodia) Co., Ltd
40 ក្រុមហ៊ុននិក្កូ គីនហ្សូកូ
Nikko-Kinzoku
(Cambodia) Co., Ltd
ក្រុមហ៊ុនវីនសាន់ 39
Winsun (Cambodia) Co., Ltd
38 ក្រុមហ៊ុនវីនសាន់
Winsun (Cambodia) Co., Ltd
ក្រុមហ៊ុនហៃកូអាស៊ី 37
Heiko Asia (Cambodia) Co., Ltd
36
ប៉ុស្តិ៍សន្តិសុខខាងក្រោយ 35
S.E.Z Security Guard Post
34
33 Prateah Lang Primary School
32
31 Princess Park
30
29 Phea Village
28 Phea Village
27 Tang Neam Pagoda
26
25
24
ច្រកចូលបុរីសន្តិភាព២ 06
National Road 3/ Borey
Son Ti Pheap II Entrance
07 ច្រកចូលបុរីសន្តិភាព២
National Road 3/ Borey
Son Ti Pheap II Entrance
04
02
01 បុរីសន្តិភាព២
03
05
សាលាបឋមសិក្សាទួលគី 08
Toul Kei Primary School
09 សាលាបឋមសិក្សាទួលគី
Toul Kei Primary School
រោងចក្រស៊ីកូ 10
Sheico Factory
11 រោងចក្រស៊ីកូ
Sheico Factory
វត្តគោកខ្សាច់ 12
Kok Ksach Pagoda
13 វត្តគោកខ្សាច់
Kok Ksach Pagoda
វិទ្យាស្ថានស្រាវជ្រាវ និង
អភិវឌ្ឍន៍កសិកម្មកម្ពុជា
14
15 វិទ្យាស្ថានស្រាវជ្រាវ និង
អភិវឌ្ឍន៍កសិកម្មកម្ពុជា
វិទ្យាល័យពងទឹក 16
17 វិទ្យាល័យពងទឹក
Pong Teok High School
18
19 វត្តស្លែង
Slaeng Pagoda
20
21 សួនវឌ្ឍនៈ ច្រកចូលខាងជើង
Vattanac Industal Entrance 1
22
23 សួនវឌ្ឍនៈ ច្រកចូលខាងត្បូង
Vattanac Industal Entrance 2